ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 20-Jun-2016, 15:24
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦**

**ម៉ោង ០៩:០១នាទី**

**សវនាការលើកទី៤០៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី
*(Ms.Maddalena Ghezzi)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង លាង

លោក ត្រាវីស ហ្វារ *(Mr. Travis FARR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

លោក លីវ សុវណ្ណា

លោកស្រី ដូរីន ជិន *(Mrs. Doreen CHEN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក វ៉ែន ពៅ

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ត្រាវីស ហ្វារ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ហ៊ឹម ហ៊ុយ ហៅ ហ៊ឹម ហ៊ុយ (2-TCW-906) | ខ្មែរ |
| លោក ម៉ម រិទ្ធា | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ហ៊ីម ហ៊ុយ ហៅ ហ៊ឹម ហ៊ុយ** (2-TCW-906)

សួរបន្តដោយលោក ត្រាវីស ហ្វារ ផ្តើមពី៖ ........ ទំព័រ ២
សួរដោយចៅក្រម ក្លូឌា ហ្វេនស៍ ផ្តើមពី៖ ........ ទំព័រ ៣៨
សួរដោយលោក ត្រាវីស ហ្វារ ផ្តើមពី៖ ........ ទំព័រ ៤០
សួរដោយលោក ពេជ អង្គ ផ្តើមពី៖ ........ ទំព័រ ៤៧
សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្តើមពី៖ ........ ទំព័រ ៥៩
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី៖ ........ ទំព័រ ៦៥
សួរដោយលោក រ៉ិចទ័រ កូប៉េ ផ្តើមពី៖ ........ ទំព័រ ៧៤

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៤៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សក្ខីកម្ម ហ៊ីម ហ៊ុយ។ ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយសាក្សីដែលត្រូវមកផ្ដល់សក្ខីកម្មបន្តនៅថ្ងៃនេះ គឺលោក ហ៊ីម ហ៊ុយ។ លោក និងមេធាវីប្រឹក្សា លោក ម៉ម រិទ្ធា មានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការ ហើយនៅថ្ងៃនេះមិនមានសាក្សីបម្រុងនោះទេ។ សូមអរគុណលោកប្រធាន។

[០៩:០៣:០២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ លោកស្រី សែ កុលវុឌ្ឍី។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះ ថាអាការៈឈឺចង្កេះ វិលមុខ ពេលធ្វើចលនា មិនអាចអង្គុយយូរបាន និងបានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ស្ថិតនៅខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្តទៅនេះ ផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

[០៩:០៤:៤៦]

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម សហការីទាំងអស់។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក ត្រាវីស ហ្វារ៖**

**ស៖** ជម្រាបសួរលោកសាក្សី។ ឥឡូវនេះ ខ្ញុំសូមចូលទៅប្រធានបទនិយាយអំពីការសិក្សាអំពីនយោបាយ នៅពេលដែលលោកនៅស-២១នោះ តើលោកមានដែលបានចូលរៀនវគ្គនយោបាយណាមួយដែរទេ? ហើយបើសិនណាជាលោកធ្លាប់បានចូល តើ<នរណាជាអ្នកបង្រៀន>? ហើយលោកសិក្សារៀនសូត្រនយោបាយពីប្រធានបទអ្វីដែរ?

**លោក ហ៊ឹម ហ៊ុយ៖**

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោក ពេលមកនៅស-២១ហ្នឹង គឺគេឲ្យរៀនសូត្រនយោបាយ ឲ្យ

ស្គាល់ខ្មាំង ស្គាល់សត្រូវ។ មួយទៀត ពិសេសគឺយាម កុំឲ្យខ្មាំងរត់រួច កុំឲ្យខ្មាំងតដៃ។ ហើយមួយទៀត ឲ្យស្គាល់ថា អ្នកដែលចាប់មក គឺជាខ្មាំងរបស់អង្គការ កុំឲ្យថា មិនមែនខ្មាំង។ ពេលដែលប្រជុំហ្នឹង គឺ ហៅតាំងពីអ្នកធ្វើការនៅព្រៃស អ្នកការពារ អ្នកសួរចម្លើយទាំងអស់ រៀនសូត្រ បាទ។

[០៩:០៦:១៥]

**សៈ** លោកទើបតែនិយាយថា លោក<ត្រូវតែ>ទទួលយល់ស្របថា អ្នកណាក៏ដោយ ឲ្យតែអង្គការចាប់ខ្លួន គឺជាខ្មាំងហើយ។ តើ<ត្រូវអនុវត្តបែបនេះចំពោះអ្នកដែលអង្គការចាប់ខ្លួនទាំងអស់ឬ>? <តើនរណាក៏ដោយ ឲ្យតែអង្គការចាប់ខ្លួន គឺជាសត្រូវទាំងអស់>ឬ?

**ឆៈ** បាទ ខ្ញុំដូចចាប់ពួក៧០៣ អង្គភាពពួកខ្ញុំអ៊ីចឹង គឺខ្ញុំថា មិនមែនខ្មាំង។ តែយើងភ័យខ្លួនដែរ ថាបើចាប់មក ពួកធ្លាប់នៅជាមួយគ្នាពីមុនមក គឺមិនមែនចូល សេ.អ៊ី.អា ណា មិនចូលភ្នាក់ងារយួនណា ទេ គឺសុទ្ធតែអ្នកល្អទាំងអស់ ហេតុអីបានគេចាប់យកមកដាក់គុកអ៊ីចឹង។ ហើយគេចោទថា អ្នកណា ដែលអង្គការចាប់មក គឺជាខ្មាំងរបស់អង្គការ។

**សៈ** ហើយលោកក៏បានឆ្លើយថា គេបានប្រាប់លោកថា លោកត្រូវតែដាច់ខាត មានជំហរដាច់ខាត។ តើក្នុងនាមជាអ្នកយាម ក្នុងនាមជាអ្នក<សួរចម្លើយ> តើពាក្យថា "ជំហរដាច់ខាត" នេះ មាន ន័យថាដូចម្តេចដែរ?

**ឆៈ** បាទ ខ្ញុំសូមជម្រាបថា ចំណែកខ្ញុំគឺនៅតែឆ្ងល់ ហើយមិនទុកចិត្តទៀត។ ព្រោះហេតុអីបាន ជាគេចាប់ទាំងខ្សែៗ? អ្នកណានៅកងណា អ្នកណាឆ្លើយដាក់ណា គឺគេចាប់។ ដូចខ្ញុំអ៊ីចឹង នៅធ្វើការនៅ ស-២១ អ៊ីចឹង តែចាប់ពួកខ្ញុំ ឆ្លើយដាក់ គឺចាប់បន្តគ្នារហូត។ នេះអយុត្តិធម៌ក្នុងការចាប់មនុស្ស។ វាខុស ទាំងអស់ បាទ។

**សៈ** ខ្ញុំសូមផ្តោតតែពាក្យថា "ដាច់ខាត" ទេ ពីព្រោះថាគេបានប្រាប់លោកថា លោកត្រូវតែ ប្រកាន់ជំហរដាច់ខាត។ សម្រាប់លោកហ្នឹង លោកយល់ថាដូចម្តេច?

[០៩:០៨:១១]

**ឆៈ** បាទ ពេលដែលនៅកន្លែងហ្នឹង គឺគេឲ្យមនុស្សម្នាក់តាមដានម្នាក់។ ប្រជុំរាល់ថ្ងៃ បើអ្នក ណាមិនដាច់ខាត មានសិទ្ធិរាយការណ៍ជូនអង្គការគេនៅកន្លែងហ្នឹងទាំងអស់។ អ៊ីចឹងម្នាក់ៗ គឺពង្រឹង ជំហរធ្វើតាមគេ។ បើកាលណា យើងមិនធ្វើតាមគេ គឺគេនឹងតាមដានដឹង គឺនឹងចាប់ខ្លួនទៀត។

**សៈ** អ្នកណាជាអ្នកបើកវគ្គរៀនសូត្រ<ដែលលោកបានចូលរួមនោះ>? អ្នកណាជាអ្នកបង្រៀន

01297752



ជាអ្នកឧទ្ទេសនាមក្នុងវគ្គនោះ?

**ឆ៖** បាទ គឺមាន តាហ៊ ហើយ តាឌុច ហ្នឹង។ ពិសេសជាងគេគឺ តាឌុច ដែលអ្នកបង្រៀនផ្ទាល់។

**ស៖** តើគេមានប្រាប់លោកឲ្យបានជាក់លាក់ពាក់ព័ន្ធទៅនឹងអ្នកទោសនៅស-២១ដែរទេ? តើអ្នកទោសទាំងអស់នៅស-២១ សុទ្ធតែជាខ្មាំងទាំងអស់ ឬខ្លះគឺជាខ្មាំង ខ្លះមិនមែនជាខ្មាំង គេប្រាប់លោកថាម៉េចដែរ?

**ឆ៖** ខ្ញុំសូមជម្រាបថា ខ្ញុំមិនដឹងថា អ្នកណាខ្មាំង អ្នកណាអីទេ។ គ្រាន់តែថា ដូចចាប់ពួកខ្ញុំអ៊ីចឹងយកចូលទៅ ពួកខ្ញុំអត់មានទៅចូលដៃជើងណា។ បានខ្ញុំថា ចាប់អយុត្តិធម៌ អត់មានខុសអី ចាប់។ ដោយសារឆ្លើយដាក់ម្នាក់ តម្នាក់ បាទ។

**ស៖** ខ្ញុំសូមសួរបញ្ជាក់ឲ្យបានច្បាស់ឡើងវិញ ខ្ញុំមិននិយាយអំពីជំនឿរបស់លោកដែលថា ពិតជាមានអ្នកប្រព្រឹត្តខុសអីនោះទេ។ ប៉ុន្តែថាតើ ឌុច ឬក៏ ហ៊ បានប្រាប់លោកដូចម្ដេចខ្លះដែរអំពីអ្នកទោសនៅស-២១ហ្នឹង? តើពួកគេមានប្រាប់លោកថា អ្នកទោសនៅស-២១ហ្នឹង សុទ្ធតែជាខ្មាំងដែរឬទេ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា ពេលរៀនសូត្រហ្នឹង គឺថាអ្នកណាដែលអង្គការចាប់យកមកហើយគឺជាខ្មាំងរបស់អង្គការ បាទ។

[០៩:១០:៣៦]

**ស៖** តើគេមានប្រាប់លោកថា នឹងត្រូវធ្វើយ៉ាងដូចម្ដេច ឬក៏តើនឹងមានអ្វីកើតឡើងចំពោះអ្នកទោសទាំងនេះទេ ដោយសារថាគេថាអ្នកទាំងនោះ គឺជាខ្មាំង?

**ឆ៖** បាទ គឺខ្ញុំអត់បានដឹងដែររឿងអស់ហ្នឹង ប៉ុន្តែគ្រាន់ថា ឃើញគេបណ្ដើរយកទៅសួរចម្លើយសួរអី។ ក្រោយមកទៀត គេបញ្ចប់សួរចម្លើយហ្នឹង ក៏ដូចថា សួរបានច្រើន ជិត៨០នាក់អ៊ីចឹងទៅ គេឲ្យដឹកយកចេញទៅ យកទៅសម្លាប់ទៅ។

**ស៖** តើលោកមានបានដឹងថា មានអ្នកទោសណាម្នាក់នោះ ត្រូវបានគេដោះលែងឲ្យរួចខ្លួនពីស-២១ដែរទេ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា ខ្ញុំអត់បានដឹងទេ។

**ស៖** ឥឡូវនេះខ្ញុំសូមសួរ<ពាក់ព័ន្ធនឹង>ចម្លើយរបស់លោកដែលឆ្លើយក្នុងសំណុំរឿង០០១គឺ E3/7461 ក្រោយពីម៉ោង១១:២៩នាទី គេបានសួរសំណួរដូចគ្នាទៅកាន់លោកថា៖ “តើមានគេដោះ

លែងអ្នកណាម្នាក់ដែរទេ? លោកឆ្លើយថា សូមដកស្រង់៖ ខ្ញុំមិនដែលឃើញអ្នកណាដែលគេចាប់ខ្លួនហើយ<បញ្ជូនមកស-២១> ត្រូវបានដោះលែងទៅវិញនោះទេ ពីព្រោះថាអ្នកណាក៏ដោយ កាលណាតែចាប់ខ្លួន<បញ្ជូន>មក<ទីនោះ>ហើយ គឺថាត្រូវតែស្លាប់ហើយ។" បញ្ចប់ការដកស្រង់។ ដូច្នេះសំណួររបស់ខ្ញុំថាពិតទេថា អ្នកដែលគេបញ្ជូនទៅស-២១ គឺប្រាកដជាជួបនឹងជោគវាសនាស្លាប់ហើយ? តើនេះគឺជាអ្វីដែល<លោកបានសង្កេត ឬក៏ជាអ្វីដែល>គេប្រាប់លោក<ថា>ជាគោលនយោបាយដែល ឌុច ឬក៏ ហ៊ឺ <ឬអ្នកណាផ្សេងទៀត>បានប្រាប់លោក ឬក៏យ៉ាងណា?

[០៩:១២:៣៨]

**ឆ៖** បាទ គឺអ្នកអប់រំច្បាស់ជាងគេគឺ តាឌុច ហ្នឹង។ អ្នកដែលចូលមកកន្លែងទួលស្លែងហ្នឹង គឺមិនអាចវិលត្រឡប់ទៅវិញបានទេ គឺគេត្រូវតែសម្លាប់ចោលទាំងអស់។

**ស៖** ដូច្នេះលោកកំពុងតែឆ្លើយថា លោកស្តាប់ឮមកពី ឌុច។ តើមានអ្នកណាផ្សេងទៀត ក្រៅពី ឌុច និយាយរឿងនេះប្រាប់លោកទេ ដែលថាអ្នកដែលគេចាប់ខ្លួនទៅស-២១ហើយ ត្រូវតែសម្លាប់ចោលហើយ?

**ឆ៖** បាទ គឺគ្មានអ្នកណាក្រៅពី តាឌុច ទេ ព្រោះ តាឌុច បង្រៀនសូត្រនៅសាលានយោបាយខាងត្បូងផ្ទះគាត់ហ្នឹង។

**ស៖** ក្នុងពេលដែលលោកធ្វើការនៅស-២១ <មិនថា>នៅក្នុងវគ្គរៀនសូត្រ<ទាំងអស់នេះ ឬក៏នៅកន្លែង>ណាមួយក្តី តើលោកធ្លាប់ឮសូរឃ្លាមួយដែលគេនិយាយថា "បើដកស្មៅ ត្រូវតែដកទាំងឫស" លោកធ្លាប់ឮឃ្លានេះទេ?

**ឆ៖** បាទ ខ្ញុំធ្លាប់ឮ ព្រោះ តាឌុច អ្នកបង្រៀនឲ្យដកស្មៅ ដកទាំងឫស។ អ៊ីចឹងបានសេចក្តីថា គឺគេចាប់ជាខ្សែហើយ បាទ។

**ស៖** លោកបាននិយាយថា <មនុស្សមានទំនាក់ទំនងគ្នាជា>ខ្សែ<>។ <តើនរណាដែលគេត្រូវរាប់បញ្ចូលថាជាខ្សែនោះ? តើអ្នកណា>ជាប់ជំពាក់ជាខ្សែរយៈនេះ?

**ឆ៖** បាទ ដូច៧០៣អ៊ីចឹង បើចាប់មេដឹកនាំពីកងពល៧០៣មកសួរចម្លើយ ដូចពួកខ្ញុំចេញពី៧០៣មក មកធ្វើការនៅកន្លែងហ្នឹង បើខាងនោះឆ្លើយដាក់មក គឺពួកខ្ញុំក៏ត្រូវគេចាប់ខ្លួនដែរ។

[០៩:១៤:៥៤]

**ស៖** ចុះសមាជិកគ្រួសាររបស់អ្នកដែលត្រូវគេចាប់ខ្លួននោះ តើសមាជិកគ្រួសាររបស់អ្នកដែល

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ត្រូវបានគេចាប់ខ្លួន ត្រូវចាត់ទុកថាជាខ្សែដែរទេ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា តាឌុច អ្នកបង្រៀនពួកខ្ញុំទាំងអស់ថា ចាប់ៗជាខ្សែបាទ ចាប់ជាខ្សែមានការពាក់ព័ន្ធអ្នកណាមួយ គឺត្រូវចាប់ជាខ្សែ ប្ដីប្រពន្ធក៏ដោយ ម៉ែឪក៏ដោយ គឺចាប់ជាខ្សែយកមក។

**លោក គ្រាវីស ហ្វារ៖**

លោកប្រធាន យើងខ្ញុំសុំការអនុញ្ញាតចាក់បញ្ចាំងខ្សែវីដេអូខ្លីមួយគឺ E3/536R ពីនាទី២៧:០៥ វិនាទី <ទៅដល់នាទី ២៧:២២វិនាទី>។ នេះជា*ឃ្លីប*វីដេអូខ្លីមួយពាក់ព័ន្ធទៅនឹងការសម្ភាសសាក្សីរូបនេះតែម្ដង។ ដូច្នេះយើងខ្ញុំសូមការអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ ហើយផ្នែកខាងសោតទស្សន៍ចាក់ផ្សាយផ្នែកវីដេអូ*ឃ្លីប*ដែលតាមសំណើសុំរបស់សហព្រះរាជអាជ្ញារងអន្តរជាតិអំម្បាញ់មិញនេះ។

[០៩:១៦:២៨]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"...គឺខ្ញុំ ហើយជាមួយនឹងអ្នកការពារដែលយកទៅហ្នឹង គឺលើកដាក់នៅលើឡាន។ ហើយខ្ញុំកត់តែឈ្មោះ ឱ្យពួកគេហ្នឹង..."*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

**លោក គ្រាវីស ហ្វារ៖**

លោកប្រធាន ខ្ញុំយល់ឃើញថា*ឃ្លីប*ត្រង់នេះមិនចំចំណុចវាទេ។

**ប្រធានអង្គជំនុំ៖**

លោកបានរៀបចំឱ្យខាងផ្នែកខាងសោតទស្សន៍មុនទេ ពីចំណុចនេះ។

**លោក គ្រាវីស ហ្វារ៖**

ខ្ញុំបានរៀបចំហើយ គឺយើងហៅថា *ឃ្លីប*លេខ២។ ខ្ញុំសុំមើលពិនិត្យបន្តិចសិន ដើម្បីកុំឱ្យច្រឡំ។

*(សម្រាករយៈពេលខ្លី)*

[០៩:១៩:១២]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"...ចាប់ទាំងខ្សែ សម្លាប់ចោលទាំងខ្សែតែម្ដង។ ទាំងប្ដីទាំងអីទាំងអស់ សូម្បីតែបងប្អូនក៏វា*

*ចាប់។...”*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** ដូច្នេះលោក ហ៊ឹម ហ៊ុយ នៅត្រង់នេះ យើងបានស្ដាប់ឮលោកនិយាយ ថាសមាជិកគ្រួសារទាំងអស់ហ្នឹង គឺជាខ្មែរក្បត់ហើយ។ <>លោក<ក៏បានប្រាប់យើងដែរថា លោកបានទទួលការណែនាំនេះ ឬក៏ថា គេប្រាប់លោក>ថានេះគឺជាគោលនយោបាយ<ដែលដាក់ចេញដោយ> ឌុច។ <>តើលោកបានឃើញថា គោលនយោបាយនេះ <ត្រូវបាន>គេបានយកមកអនុវត្តទេ? <និយាយម្យ៉ាងទៀត>ថា <តើលោកបានឃើញថា>គ្រួសារ<របស់អ្នកទោស ត្រូវបានគេចាប់មកជាមួយអ្នកទោសដែរទេ>?

**លោក ហ៊ឹម ហ៊ុយ៖**

**ឆ៖** បាទសូម ខ្ញុំសូមជម្រាបថា ដូចបានខ្ញុំជម្រាបអ៊ីចឹង គឺថាគេចាប់ទាំងខ្សែ ប្រពន្ធកូនក៏ដោយ បងប្អូនណាក៏ដោយ ក៏គេចាប់ទាំងខ្សែ។ ឲ្យតែគេចាប់ម្នាក់យកមកចូលគុកហើយ គឺគេតាមស្រាវជ្រាវចាប់ទាំងខ្សែមកទៀត។

**ស៖** តើចំណុចនេះ លោកបានឃើញគេអនុវត្តដោយផ្ទាល់បន្ថែមទៅលើអ្វីដែលលោកបានឮ <អំពីគោលនយោបាយនោះ តើ>ត្រឹមត្រូវដែរទេ?

**ឆ៖** បាទខ្ញុំមិនបានដឹងដែរ ប៉ុន្តែដឹងច្បាស់ជាងគេ គឺបងហ៊ុយ នៅស្រែមួយ គឺចាប់ទាំងប្ដីទាំងប្រពន្ធ ទាំងប្អូន ទាំងកូនអីទាំងអស់។

[០៩:២១:១០]

**ស៖** សម្រាប់ឯកសារយោង សំណួរបន្ទាប់មកទៀតនេះគឺយោងទៅលើឯកសារ E3/1693 អង់គ្លេសគឺ 00192723, បារាំង 00357310, ខ្មែរ 00191879។ លោកសាក្សី ខ្ញុំនឹងសួរទិសស្លោកមួយទៀត។ ពេលលោកនៅស-២១ <តើ>លោកដែលឮសួរទិសស្លោកមួយនិយាយថា “សូវចាប់មនុស្សច្រឡំ ១០នាក់ ប្រសើរជាជាងការលែងមនុស្សម្នាក់ច្រឡំ” ដែលឮទិសស្លោកនេះទេ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា ពាក្យស្លោកនេះគឺ តាឌុច អ្នកបង្រៀននយោបាយនៅអ្នកធ្វើការទួលស្លែងហ្នឹង គឺសុខចិត្តចាប់មនុស្ស១០ កុំឲ្យច្រឡំមនុស្សម្នាក់។ បាទ គឺគាត់និយាយពិតប្រាកដមែន។

**ស៖** នៅក្នុងវគ្គសិក្សារៀនសូត្រ ដែលលោកបានចូលរួមនេះ តើគេមានបានពន្យល់ប្រាប់លោក <ទេ ថាមាន>ទំនាក់ទំនង<យ៉ាងម៉េច>រវាងអង្គការ និងប្រជាជនដូចជារូបលោក ដែលធ្វើការនៅស-

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

២១ នេះ<>? តើរវាងលោកនិងអង្គការវាមានទំនាក់ទំនងគ្នាយ៉ាងដូចម្ដេចដែរ?

**ឆ៖** បាទ ខ្ញុំអត់ដឹងដែរ ព្រោះពេលដែលគេហៅទៅរៀនសូត្រ អាហ្នឹងទៅរៀនសូត្រទៅ។ មកវិញមិនដឹងទំនាក់ទំនងម៉េច។

**ស៖** ខ្ញុំសូមសួរលោកពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់លោកក្នុងសំណុំរឿង០០១។ នេះគឺឯកសារ E3/7462 ក្រោយម៉ោង១១:៣៨ព្រឹក នេះគឺអ្វីដែលលោកបានឆ្លើយ សូមដកស្រង់៖ "យើងជាកូនរបស់អង្គការ ជាកូនរបស់បក្ស យើងមិនមែនជាកូនរបស់ម៉ែឪយើងទេ។ ដូច្នេះពេលដែលយើងបំពេញការងារត្រូវតែគោរពអង្គការ គោរពគ្រប់សកម្មភាពទាំងពេលដេក ដើរ ឈរ អង្គុយ។ ហើយអ្នកណាក៏ដោយតែកាលណាមិនអនុវត្តបានទេ នោះនឹងត្រូវចាត់ទុកថាជាខ្មាំង ហើយនិងត្រូវបានគេចាប់ខ្លួន និងយកទៅឃុំឃាំងខ្លួន។" បញ្ចប់ការដកស្រង់។ តើលោកនៅចាំទេ ថា<គេបានប្រាប់លោកពីរឿងនេះ ថា>លោកគឺជាកូនរបស់អង្គការ ហើយត្រូវគោរពអង្គការនៅគ្រប់កិច្ចការទាំងអស់?

[០៩:២៤:០៦]

**ឆ៖** បាទ ខ្ញុំសូមជម្រាប ខ្ញុំនឹកឃើញ ព្រោះគេបង្រៀនសូត្រនេះ ក៏បង្រៀនតែខ្ញុំមួយដែរ គឺបង្រៀនទាំងអស់គ្នា។ ម្នាក់ៗជាកូនអង្គការ មិនមែនកូនម៉ែឪយើងទេ ម៉ែឪយើងគឺថាគ្រាន់បានតែបង្កើតយើងប៉ុណ្ណឹង តែគុណគឺមានតែអង្គការទេ ជាគុណយើង។ អ៊ីចឹងយើងត្រូវគោរព អង្គការជាម៉ែឪយើង អង្គការឲ្យធ្វើអី គឺយើងត្រូវធ្វើហ្នឹង។

**ស៖** តើសេចក្ដីណែនាំនេះ វាប៉ះពាល់ដល់ការងាររបស់លោកនៅស-២១ដូចម្ដេចដែរ? តើលោកដែលមានអារម្មណ៍គិតថា លោកអាចនឹងមានជម្រើសផ្សេងក្រៅពីនេះដែរឬទេ?

**ឆ៖** បាទខ្ញុំសូមជម្រាបលោកឲ្យត្រង់ ពេលដែលខ្ញុំឃើញព្រឹត្តិការណ៍កើតនៅស-២១ហ្នឹង ខ្ញុំដូចឆ្នាំ៧៧ សុន សេន មកប្រជុំនៅស-២១ហ្នឹង គឺខ្ញុំបានឡើងឈរសុំគាត់ ពេលដែល សុន សេន មកបង្រៀនសូត្រពួកនៅធ្វើការហ្នឹង។ ខ្ញុំឡើងសុំ លើកដៃសុំគាត់ ថាអ៊ំៗ សុំអ៊ំឯទៅទ័ពវិញហើយ។ គាត់ថាមិត្តឯងប៉ានវ៉ៃយួនអត់? ខ្ញុំថា ប៉ានអ៊ំ។ នឹកឃើញថា ជម្រើសខ្ញុំមានតែទៅទ័ពវិញសុខចិត្តងាប់ តែនៅកន្លែងនេះ គឺខ្ញុំបើគេចាប់ខ្ញុំ គឺចាប់ទាំងម៉ែឪបងប្អូនខ្ញុំសម្លាប់ចោលទាំងអស់ បាទ។

[០៩:២៥:៤៨]

**ប្រធានអង្គជំនុំ៖**

ប៉ុន្តែលោក ហ៊ឹម ហ៊ុយ ដូចឆ្លើយអត់ចំសំណួរទេ នេះជាឧទាហរណ៍មួយ ប៉ុន្តែសួរថា លោក

មានជម្រើសផ្សេងដែលលោកចង់ជ្រើសរើសនូវការងារផ្សេងទៀត តាមចំណង់ចំណូលចិត្តរបស់លោកបានដែរឬទេ? នេះជាសំណួរដែលច្បាស់លាស់ នៅក្នុងកម្ពុជាប្រជាធិបតេយ្យ ជាពិសេសដែលលោកនៅធ្វើការនៅមន្ទីរស-២១ហ្នឹង សួរថាតើលោកអាចមានជម្រើសផ្សេង មិនបំពេញមុខងារតាមការចាត់តាំងរបស់អង្គការបានដែរឬទេ? សូម្បីតែនៅក្នុងអង្គភាពមន្ទីរសន្តិសុខស-២១ ក៏ដោយ លោកអាចសុំពីកន្លែងមិនធ្វើអានេះទេ ទៅធ្វើកន្លែងផ្សេង ឧទាហរណ៍អ៊ីចឹង តើលោកមានជម្រើសនេះដែរឬទេ នៅក្នុងការអនុវត្តមុខងារភារកិច្ចរបស់ខ្លួននៅក្នុងមន្ទីរសន្តិសុខ ស-២១ កាលនោះ?

**លោក ហ៊ីម ហ៊ុយ៖**

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកប្រធាន។ ពេលដែលនៅស-២១ហ្នឹង គេក៏បានរើសខ្ញុំឲ្យទៅសួរចម្លើយ។ ខ្ញុំថា ខ្ញុំអត់ចេះសួរទេ ហើយមួយទៀត ក៏ខ្ញុំមិនចេះសរសេរអក្សរដែរ។ នឹកឃើញថា ខ្ញុំសួរចម្លើយ គឺខ្ញុំអត់ចេះធ្វើឯកសារឲ្យគេ អ៊ីចឹងខ្លាចគេចោទប្រកាន់ខ្ញុំ។ មានតែជម្រើសមួយទេ ដែលខ្ញុំនៅកន្លែងចាំទទួលអ្នកទោស គឺខ្ញុំបានដឹងសភាពការណ៍ទាំងអស់ បាទ។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** បាទ គឺថាលោកកំពុងតែរៀបរាប់ស្ថានភាពមួយ <ដែល>គេ<មិនបានផ្ដល់ការងារឲ្យលោក> ដោយសារតែលោក<មិន>មានលក្ខណៈសម្បត្តិត្រឹមត្រូវ។ សំណួរសួរផ្សេង នៅពេលដែលលោកទទួលសេចក្ដីណែនាំពី ហ៊, ពីប៉េង, ពីខុច, ពី<ផល> តើលោកមាន<មានអារម្មណ៍ថា លោកមាន>ជម្រើស<ផ្សេងទៀតទេក្នុងបញ្ហានោះ? តើលោកអាចសម្រេច>មិនអនុវត្តតាមសេចក្ដីណែនាំហ្នឹងបានដែរទេ <បើលោកមិនចង់ធ្វើតាមនោះ>?

[០៩:២៧:៥២]

**ឆ៖** បាទ ខ្ញុំមិនអាចមិនអនុវត្តតាមគេទេ ត្រូវអនុវត្តតាមគេ ព្រោះពេលនោះ បានចេញខ្លួនពីសួរចម្លើយហើយ បានមកនៅកន្លែងហ្នឹង យើងវាស្រួលជាងនៅកន្លែងសួរចម្លើយ។ សួរចម្លើយពិបាកធ្វើឯកសារ។ ហើយមួយទៀត គឺមិនដឹងអីទាំងអស់។ មកនៅក្រៅ គឺដឹងថា គេចាប់ពីណាមក ពីណាមក គឺខ្ញុំមានតែជម្រើសហ្នឹងមួយទេបាទ។

**ស៖** សំណួរចុងក្រោយពាក់ព័ន្ធទៅនឹងវគ្គរៀនសូត្រ។ លោកថា វគ្គរៀនសូត្រហ្នឹង គឺទាំងអ្នកសួរចម្លើយ ទាំងអ្នកយាមទាំងអស់ហ្នឹងគឺថា ចូលរួមរៀនសូត្រជាមួយគ្នា អ៊ីចឹង <តើគេចូលរៀនទាំងអស់គ្នា ឬក៏ចូលខ្លះ មិនចូលខ្លះ> ឬក៏យ៉ាងណា?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01297758



**ឆ៖** បាទ ពេលរៀនសូត្រ គឺរៀនសូត្រជាមួយគ្នា។ បាទ គេដាក់រួមទាំងអស់ រៀនសូត្រនៅកន្លែងសាលានយោបាយមួយខាងត្បូងផ្ទះ តាឌុច ហ្នឹង។

**ស៖** ហើយក្រៅពីអ្នកយាម និងអ្នកសួរចម្លើយ តើមានបុគ្គលិកកម្មាភិបាលណាផ្សេងទៀត ពី ស-២១ ហ្នឹងចូលរួមដែរទេ?

**ឆ៖** បាទ អត់មានទេ មានតែកន្លែងស-២១ ហើយអ្នកមកពីស្រែ មកពីអីហ្នឹង មករៀនហ្នឹង។

**ស៖** ឥឡូវនេះខ្ញុំចូលទៅប្រធានបទថ្មីមួយ និយាយអំពីក្មេងៗនៅស-២១។ ទី១ សូមលោកជម្រាបជូនអង្គជំនុំជម្រះមើល តើគេមានឃុំឃាំងកូនក្មេងនៅស-២១ដែរទេ? ហើយបើមាន ថាតើ<> គេឃុំក្មេងៗទាំងនោះ<នៅកន្លែងណា>? ហើយតើគេឃុំក្មេងៗទាំងនោះ ជាមួយអ្នកណាដែរ? <តើលក្ខខណ្ឌនៃការឃុំខ្លួននោះយ៉ាងម៉េចដែរ?>

**ឆ៖** បាទ គឺគេឃុំខ្លួនក្មេងៗនោះគឺជាមួយម្ដាយ នៅជាមួយម្ដាយ។

[០៩:៣០:១៧]

**ស៖** ឥឡូវនេះខ្ញុំសូមសួរពាក់ព័ន្ធចម្លើយរបស់លោក ឆ្លើយជូនសហចៅក្រមស៊ើបអង្កេត គឺ E3/5154, អង់គ្លេស 00161603, ខ្មែរ 00146651, បារាំង 00148099។ នេះគឺអ្វីដែលលោកបានឆ្លើយ សូមដកស្រង់៖ "ក្មេងៗ<នៅ>ជាមួយម្ដាយ<> គឺម្ដាយគេមិនបានដាក់ខ្នោះទេ គេយកអ្នកទាំងនេះទៅដាក់ក្នុងបន្ទប់ធំមួយ។ ខ្ញុំដឹងរឿងនេះ ដោយសារ<នៅពេល>មានអ្នកទោសជាច្រើន <>គេឲ្យខ្ញុំជួយមើលអ្នកទាំងនោះ ហើយខ្ញុំឃើញអ្នកទាំងនោះ គេដាក់នៅក្នុងបន្ទប់មួយធំ។ <តាហ៊ី បានឈរជើងនៅកន្លែងនោះ>។" បញ្ចប់ការដកស្រង់។ នៅត្រង់ផ្នែកនេះ លោកបានឆ្លើយថា គេបានស្នើឲ្យលោកជួយពិនិត្យមើលកុមារ និងស្ត្រីទាំងនោះដោយសារថាមានអ្នកទោសហ្នឹងច្រើនពេក។ <តើលោកចង់បានន័យថាម៉េច ពេលលោកនិយាយថា "ច្រើន" ហ្នឹង?> នៅពេល<ដែលគេឲ្យលោកជួយមើល>ក្មេងៗ និងម្ដាយរបស់ក្មេងៗទាំងនោះ <តើមានម្ដាយ និងក្មេងៗ>ប្រហែលជាប៉ុន្មាននាក់ដែរ <ដែលត្រូវ>បាន<>គេ<ឃុំខ្លួននៅក្នុងបន្ទប់ធំ ដែលលោកនិយាយ>នោះ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា ពេលដែលគេចាប់មកច្រើនរាប់រយនាក់អ៊ីចឹង គឺគេឲ្យខ្ញុំចូលដើរជួយមើលតាមអគារហ្នឹង ដើរតាមប្រឡោះយ៉អគារហ្នឹង ដើរមើលទៅកុំឲ្យពួកអ្នកយាមហ្នឹងងក់។ បាទ ហើយចំនួនប៉ុន្មានៗ គឺខ្ញុំមិនចាំទេបាទ។

**ស៖** ខ្ញុំមិនមានចំណាប់អារម្មណ៍ពាក់ព័ន្ធនឹងចំនួនអ្នកទោសសរុបទេ ខ្ញុំចង់ដឹងតែចំនួនក្មេងៗ

និងម្តាយរបស់ពួកគេ<ដែលត្រូវបានឃុំខ្លួន>នៅក្នុងបន្ទប់ធំមួយដែលលោករៀបរាប់នេះ។ នៅពេលដែលគេនាំអ្នកទោស<មួយក្រុមធំ>ចូលមក តើលោកអាចប៉ាន់ប្រមាណបានថាមានក្មេងដែលគេនាំមកហ្នឹង ប្រហែលជាប៉ុន្មាននាក់? ហើយម្តាយរបស់ក្មេងៗទាំងនោះប្រហែលជាប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថាខ្ញុំអត់ចាំទេ ព្រោះបានត្រឹមតែដើរមើលហើយ ខ្ញុំទៅវិញ បាទ។

[០៩:៣២:៤៥]

**ស៖** លោកទើបតែបានឆ្លើយថា គេស្នើសុំឲ្យលោកជួយនេះនៅពេលដែលគេនាំអ្នកទោសមកជាក្រុមធំ។ តើពេលដែលគេនាំអ្នកទោសជាក្រុមធំៗបែបនេះ ហើយគេស្នើលោកឲ្យជួយពិនិត្យតាមដានបែបនេះ តើគេនាំក្រុមធំៗបែបនេះមកញឹកញាប់<ទេ តើមកប៉ុន្មានដង>ដែរ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា ពេលដែលគេចាប់ គឺចាប់មកជាច្រើនគ្រប់កន្លែងទាំងអស់ ដល់អ៊ីចឹងគេខ្លាចមើលមិនទាន់មិនអី ឲ្យខ្ញុំជួយដើរមើលម្តងៗផង បាទព្រោះខ្ញុំចូលមកគឺខ្ញុំមើលម្តងហើយ ខ្ញុំចេញទៅវិញទៅ។ មួយខ្លាចកម្លាំងអ្នកយាមហ្នឹងធានាមិនបាន ខ្លាចរងក់ខ្លាចអី ជួយមើលម្តងម្នាក់ៗហ្នឹងទៅ។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានទេ មានអ្វីកើតឡើងចំពោះក្មេងៗដែលគេនាំមកជាមួយអ្នកទោសជាក្រុមធំៗនេះ?

**ឆ៖** ខ្ញុំអត់បានដឹងដែរបាទ។

**ស៖** តើលោកដឹងថា ក្មេងៗទាំងនេះត្រូវបានគេសម្លាប់ចោលដែរ ឬក៏អត់ទេ?

**ឆ៖** បាទ ក្មេងពួស្ញូវ ប៉េង និយាយថា គេសម្លាប់ចោលក្រោយគុកហ្នឹង។

**ស៖** នៅពេលគាត់ប្រាប់លោកថា ក្មេងហ្នឹងគេយកទៅសម្លាប់នៅខាងក្រោយគុកនោះ តើលោកដឹងទេ គាត់និយាយហ្នឹងនិយាយសំដៅទៅលើទីតាំងត្រង់កន្លែងណាដែរនៃគុកនេះ? ម្សិលមិញយើងនិយាយអំពីទីតាំងសម្លាប់មនុស្សនៅខាងលិចបរិវេណវិទ្យាល័យ និងនៅទិសខាងត្បូង ប៉ុន្តែកន្លែងមួយនេះ តើគាត់និយាយសំដៅទៅលើកន្លែងណាមួយនៃកន្លែងទាំងពីរដែលលោកឆ្លើយពីម្សិល ឬក៏ផ្សេង?

**ឆ៖** បាទ គឺកន្លែងចំក្រោយគុកនុំងតែម្តង បាទ។ ពួក ប៉េង ៗអ្នកនិយាយ។

[០៩:៣៥:២០]

**ស៖** ខ្ញុំសុំអានចម្លើយចេញពីកំណត់ហេតុស្តាប់ចម្លើយរបស់លោកគឺ E3/5154 អង់គ្លេស

00161603, ខ្មែរ 00146651, បារាំង 00148099។ នេះជាអ្វីដែលលោកបានឆ្លើយ៖ "ប៉ុន្តែ ប៉េង បាននាំយកពួកគេទៅសម្លាប់នៅក្នុងបរិវេណទួលស្លែងតែម្តង។ ហើយគាត់ និងអ្នកនៅក្រោមចំណុះរបស់គាត់ហ្នឹង ជាអ្នកសម្លាប់ក្មេងៗទាំងនោះ <ហើយកប់នៅ>ប្រហែលជាចម្ងាយ១០០ម៉ែត្រនៅខាងជើង<ខាងក្រោយ>គុកនេះ។" តើ<ត្រឹមត្រូវ>ទេ <កន្លែងកប់>ក្មេងៗទាំងហ្នឹង<នៅ>ខាងជើងនៃគុកហ្នឹង ចម្ងាយប្រមាណជា១០០ម៉ែត្រ? <ឬក៏ពេលនេះលោកមិនចាំច្បាស់ពីរឿងនោះទេ?>

**ឆ៖** បាទ ខាងជើងគុកហ្នឹង ក៏គេសម្លាប់ ខាងលិចគុកហ្នឹង ក៏គេសម្លាប់ដែរ បាទ។

**លោក វ៉ិចទ័រ កូប៉េ៖**

នេះគឺជាការជំទាស់យឺតបន្តិចហើយ ដោយសារថា ខ្ញុំត្រូវស្វែងរកសម្រង់នេះសិន។ ប៉ុន្តែដើម្បី<ភាពពេញលេញ>ទៅនឹងសក្ខីកម្ម<ពីខាងដើម>របស់សាក្សីរូបនេះ ខ្ញុំសុំ<យោងទៅ>លើ<>ឯកសារប្រតិចារឹក E150 នៅម៉ោង១១:៤៧ ដែលសាក្សីបានឆ្លើយថា សុំដកស្រង់៖ "ទាក់ទងទៅនឹងក្មេងៗ<ដែល>ម្តាយ<ត្រូវ>បាន<គេ>ឃុំខ្លួន និងយកទៅសម្លាប់ចោលនោះ ខ្ញុំមិនដឹងអ្វីទេ មិនដឹងអ្វីទាំង<អស់>។ ខ្ញុំថា ប៉េង និងក្រុមរបស់គាត់ជាអ្នកប្រតិបត្តិការក្នុងការសម្លាប់អ្នកទាំងនេះ។" <ដូច្នេះនៅក្នុង>ភស្តុតាងត្រង់កន្លែងនេះ <គាត់ហាក់ដូចជាកំពុងតែទាយ ឬក៏កំពុងតែឆ្លើយស្មានៗ។ ដូច្នេះខ្ញុំគិតថា ដើម្បីឱ្យប្រតិចារឹកបានពេញលេញល្អ ចំណុចនេះត្រូវតែយកមកសួរផ្ទុញសាក្សីផងដែរ>។

[០៩:៣៧:៣៦]

**លោក ត្រាវីស ហ្វារ៖**

<ខ្ញុំគិតថា> យើងអាចដោះស្រាយបញ្ហា<សំណួរឱ្យឆ្លើយស្មានៗ>នេះ <ដោយគ្រាន់តែ>សួរអំពីប្រភពនៃការដឹងរបស់គាត់បាន។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** លោកសាក្សី តើធ្វើម៉េចបានជាលោកដឹងថា ក្មេងៗទាំងនេះត្រូវបានគេយកទៅសម្លាប់ចោលចម្ងាយ១០០ម៉ែត្រ នៅទិសខាងជើងនៃបរិវេណវិទ្យាល័យ គឺស-២១នេះ ម៉េចបានជាលោកដឹង?

**លោក ហ៊ឹម ហ៊ុយ៖**

**ឆ៖** ដូចខ្ញុំបានជម្រាបអ៊ីចឹងគឺ ប៉េង អ្នកប្រាប់ខ្ញុំបាទ គឺក្រុមរបស់គេនៅខាងក្នុងអ្នកយកទៅសម្លាប់។ ពេលដែលគេសម្លាប់ហើយ ក៏គេយកម៉ែ ហើយអ្នកដែលសួរចម្លើយហើយហ្នឹងគឺដឹកទៅជើងឯក។

**ស៖** តើលោកដឹងថា ហេតុអ្វីបានជាក្មេងៗទាំងនោះ ត្រូវបានគេសម្លាប់នៅបរិវេណទួលស្លែង ទោះបីជានៅពេលនោះគឺថា ឪពុកម្តាយរបស់គេត្រូវបញ្ជូនទៅជើងឯកក៏ដោយ? សំណួរម្យ៉ាងទៀត បើសិនជាលោកដឹង សូមជួយឆ្លើយជូនតុលាការ ថាហេតុអ្វីបានជាគេមិនយកក្មេងទាំងអស់នោះទៅសម្លាប់ចោលនៅឯជើងឯកជាមួយម្តាយរបស់គេទៅ?

**ឆ៖** បាទ ខ្ញុំសុំជម្រាបថា គេមិនឲ្យបែកការណ៍យកក្មេងទៅជាមួយទេ។ យកក្មេងទៅជាមួយក្មេងយំតាមផ្លូវតាមអី គឺអ្នកនៅតាមផ្លូវ ដូចពួករោងចក្រ ពួកកាត់ដេរអីដឹង គឺបែកការណ៍។ អ៊ីចឹងគេអត់ឲ្យនេះ អត់ឲ្យដឹងទេ គេត្រូវលាក់ការណ៍អ៊ីចឹង។

[០៩:៣៩:៣០]

**ស៖** ខ្ញុំខ្លាចតែខ្ញុំយល់មិនបានច្បាស់អំពីទីតាំងសម្លាប់មនុស្សនៅជិតនឹងបរិវេណស-២១ ព្រោះម្សិលមិញលោកនិយាយទីតាំងមួយថា នៅទិសខាងលិច និងកន្លែងសម្លាប់មនុស្សមួយកន្លែងទៀតនៅទិសខាងត្បូង។ ឥឡូវនេះកន្លែងសម្លាប់ក្មេងៗ លោកថានៅទិសខាងជើង។ តាមការដឹងរបស់លោក តើមានទីតាំងសម្លាប់មនុស្សបីកន្លែងនៅជុំវិញបរិវេណគុកទួលស្លែងនេះ អ៊ីចឹងមែនឬ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា ខ្ញុំដឹងក៏តាមរយៈ ប៉េង ហ្នឹងដែរ។

**ស៖** តើក្មេងៗទាំងនោះមានប៉ុន្មានឆ្នាំ? តើក្មេងៗដែលលោកបានឃើញគេឃុំខ្លួននៅស-២១ ហ្នឹង នៅទួលស្លែងដោយផ្ទាល់ភ្នែកហ្នឹង មើលទៅអាយុប៉ុន្មានឆ្នាំដែរ?

**ឆ៖** បាទ ប្រហែលពីមួយឆ្នាំឡើង ទៅដល់ប្រាំ ប្រាំមួយឆ្នាំ។

**លោក ត្រាវីស ហ្វារ៖**

លោកប្រធាន យើងខ្ញុំសូមការអនុញ្ញាត សូមបញ្ចាំងវីដេអូ*ឃ្លីប*មួយទៀត។ តើខ្ញុំត្រូវសរសេរលេខនេះជូន ឬក៏គ្រាន់តែអានលេខនេះ គឺមកពីឯកសារ E3/2357R នៅនាទី ទី<៤០:៤៨>វិនាទី ទៅដល់នាទី៤១:១៥វិនាទី។ <ជាថ្មីម្តងទៀត នេះជាខ្សែភាពយន្តខ្លីនៃកិច្ចសម្ភាសន៍ជាមួយសាក្សីរូបនេះ។>

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ចាក់ផ្សាយនូវខ្សែវីដេអូ*ឃ្លីប*តាមសំណើសុំរបស់សហព្រះរាជអាជ្ញារងអន្តរជាតិ លើអេក្រង់ទូរទស្សន៍។

[០៩:៤២:០៥]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

*"...គេសុំយកពីម៉ែអីអ៊ីចឹងទៅ គេប្រាប់ថា ប្រមូលដាក់នៅមណ្ឌល ហើយម៉ែឲ្យយកទៅ។ ឈ្មោះ ប៉េង ប្រធានខ្ញុំហ្នឹង ជាអ្នកកាន់កាប់(ឮមិនច្បាស់) គឺនាំក្មេងៗ យកទៅសម្លាប់។ សម្លាប់នៅក្បែរៗអស់ហ្នឹង។..."*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[០៩:៤២:៣៥]

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** លោកសាក្សី នៅពីដំបូងនោះ គឺយើងឮ<លោកនិយាយ>ថា <គេប្រាប់ម្ដាយៗថា គេយក>ក្មេង<ៗ>ទៅកន្លែងមន្ទីរកុមារ <តើលោកអាចប្រាប់បានទេ ធ្វើម៉េចទើបលោកដឹងថាគេ>ប្រាប់អ៊ីចឹង<ទៅម្ដាយទាំងនោះ>?

**លោក ហ៊ឹម ហ៊ុយ៖**

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ម្ដងទៀត។

**ស៖** មិនជាបញ្ហាអីទេ។ នៅក្នុង*វីដេអូ*ហ្នឹង <លោកនិយាយថា> គេប្រាប់ម្ដាយថា កូនហ្នឹងត្រូវបានយកទៅមណ្ឌលកុមារ។ <ប៉ុន្តែជាការពិត ក្មេងទាំងអស់ហ្នឹងត្រូវបាន> ប៉េង <យកទៅសម្លាប់>។ <សំណួររបស់ខ្ញុំសួរ>ថាតើលោកដឹងយ៉ាងម៉េច ដែលថាម្ដាយហ្នឹងត្រូវបានគេប្រាប់ថា កូនរបស់ខ្លួននេះ ត្រូវបានគេបញ្ជូនទៅមណ្ឌលកុមារ? <តើលោកពិតជាបានឮគេនិយាយ>បែបនេះ ទៅម្ដាយ<ទាំងនោះ ឬក៏លោកបាននិយាយពាក្យនេះប្រាប់ទៅម្ដាយៗណាមួយ>?

**ឆ៖** ខ្ញុំសូមជម្រាបថា ប៉េង បាននិយាយប្រាប់ខ្ញុំថា យកក្មេងហ្នឹងទៅមណ្ឌលកុមារ។ បើយើងមិនប្រាប់អ៊ីចឹង គឺម្ដាយគេនឹងបែកការណ៍ដឹង ដល់រឿងអស់ហ្នឹងផ្អើលហើយ។ អ៊ីចឹងយើងថាយកទៅដាក់នៅមណ្ឌលកុមារទៅ។

**ស៖** ហើយប្រហែល<នេះ>ជាសំណួរ<មួយដែលច្បាស់លាស់> ថាតើហេតុអ្វីបានជាគេប្រើប្រាស់នូវវិធីនេះ ដែលត្រូវប្រាប់ម្ដាយថា កូនរបស់ខ្លួនត្រូវបានគេបញ្ជូនទៅមណ្ឌលកុមារ ហើយមិនប្រាប់ថា កូនរបស់ម្ដាយហ្នឹង ត្រូវបានគេយកទៅសម្លាប់នោះ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា នេះជាបទបញ្ជារបស់មន្ទីរស-២១ ធ្វើម៉េចកុំឲ្យម៉ែឪដឹងថា គេយកកូនទៅសម្លាប់។ អ៊ីចឹងគេឲ្យប្រើយុទ្ធវិធីមួយថា យកទៅដាក់មណ្ឌលកុមារ បាទ។

**លោក ត្រាវីស ហ្វារ៖**

លោកប្រធាន ខ្ញុំមាន*ឃ្លីបវីដេអូ*មួយទៀត គឺឯកសារ E3/536R ពេលនាទីទី<២៧:៣៨>វិនាទី ទៅដល់<>នាទី<២៨:១៥វិនាទី>។ សូមអនុញ្ញាតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជម្រះអនុញ្ញាត។ ហើយផ្នែកខាងសោតទស្សន៍ចាក់ផ្សាយនូវផ្នែកវីដេអូ*ឃ្លីប* តាមសំណើសុំរបស់សហព្រះរាជអាជ្ញារងអន្តរជាតិលើអេក្រង់ទូរទស្សន៍។

[០៩:៤៥:៣៨]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"...ពេលដែលខ្ញុំ(ឮមិនច្បាស់)ឡើងទៅ បាទ ដែលខ្ញុំបញ្ជូនទៅហ្នឹង បាទ។ សម្លាប់ដូចតែគ្នាហ្នឹង ទៅដល់ចងមុខ ចងអីហ្នឹង មិនឲ្យឃើញទេ បាទក្មេងៗចង ចងដៃ (ឮមិនច្បាស់) ហើយគេវាយ ធ្វើដូចៗគ្នាទាំងអស់..."*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[០៩:៤៦:១៨]

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** លោកសាក្សី មានចំណុចពីរដែលខ្ញុំចង់សួរលោក។ ទី១ គឺយើងឮ<លោកនិយាយ>ថា <"ខ្ញុំអាច>បញ្ជូនក្មេងដែលមានអាយុ<>៧ <ឬ ៨>ឆ្នាំ<>។ <យ៉ាងហោចណាស់ នោះជាសម្ដីរបស់លោក ដែលគេបានបកប្រែទៅជាភាសាអង់គ្លេស> តើត្រឹមត្រូវដែរឬទេថា លោក<ជួយ>ប្រមូលក្រុមក្មេង<>ទាំងអស់នេះទៅឲ្យ ប៉េង នោះ?

**លោក ហ៊ឹម ហ៊ុយ៖**

**ឆ៖** បាទ ពេលហ្នឹង គឺពេលដែលគេយកម៉ែឪទៅជើងឯកហ្នឹង ក៏គេឲ្យជួយយកក្មេងហ្នឹងចុះមកដីសិនទៅ ឲ្យគេ។ ហើយបានពួក បងធី បងអីហ្នឹងក៏នាំគ្នា ពួកកម្លាំងខ្ញុំក៏នាំគ្នាចូលទទួលអ្នកដែលគេយាមហ្នឹង គេដាក់ឈ្មោះដាក់អីអ្នកណាមួយៗ បងធី ហ្នឹងទៅបង្ហាញឈ្មោះណាៗ ឲ្យពួកខ្ញុំយកម៉ែឪហ្នឹងមក។ ហើយដែលកុមារៗហ្នឹង គឺប្រគល់ឲ្យ ប៉េង។ ប៉េង ហើយក៏ពួកខ្ញុំយកម៉ែឪហ្នឹងឡើងឡាន យកទៅជើងឯក។

**ស៖** ហើយនៅក្នុងចំណុចនៅពេលដែលលោកបានយកក្មេងចុះមកខាងក្រោម តើលោកប្រគល់

ក្មេងទាំងអស់នោះទៅឲ្យ ប៉េង តែម្តង ឬមួយក៏ទុកគេនៅទីនោះ ហើយត្រូវ<>ដឹកជញ្ជូន<ឪពុកម្តាយរបស់ពួកគេ>ទៅខាងជើងឯកនោះ?

[០៩:៤៧:៥១]

**ឆ៖** បាទ ពេលនោះ គឺពួកខ្ញុំអ្នកចាំយកម៉ែឪយកទៅជើងឯក។ ហើយគេឲ្យជួយយកអាកូនៗហ្នឹង ចុះមកដីឲ្យគេសិនទៅ។ ហើយក៏ពួកខ្ញុំប្រគល់ឲ្យពួក ប៉េង ហ្នឹងហើយ ក៏ពួកខ្ញុំយកម៉ែឪហ្នឹង ឡើងឡាន ដឹកម៉ែឪហ្នឹង យកទៅជើងឯក។

**ស៖** ចំណុចមួយទៀត ដែលខ្ញុំចង់សួរពាក់ព័ន្ធទៅនឹងឃ្លីបវីដេអូហ្នឹង គឺលោកបានបញ្ជាក់ហើយថា កុមារហ្នឹងត្រូវបានគេសម្លាប់ដូចជាមនុស្សធំដែរ។ តើលោកអាចប្រាប់បានទេ ថាតើលោកធ្វើយ៉ាងម៉េច ទើបដឹងថាកុមារហ្នឹងត្រូវបានគេសម្លាប់ដូចមនុស្សធំដែរ? ហើយថាតើគេប្រើប្រាស់វិធីក្នុងការសម្លាប់កុមារហ្នឹង យ៉ាងដូចម្តេចដែរ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា នេះជាការប៉ាន់ស្មានរបស់ខ្ញុំទេ ការសម្លាប់មនុស្សដូចតែគ្នាទេ។

**ស៖** តើលោកអាចបញ្ជាក់បានទេ ថាតើគេប្រើវិធីសម្លាប់យ៉ាងដូចម្តេចទៅលើកុមារហ្នឹង? តាមរយៈអ្វីដែលលោកបានដឹងនៅពេលនោះ ថាតើការសម្លាប់ដែលដូចគ្នាទៅនឹងមនុស្សធំហ្នឹង គេសម្លាប់របៀបណា លោកសាក្សី?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា ខ្ញុំការប៉ាន់ស្មានក្មេង ហើយនិងមនុស្សចាស់ហ្នឹង ដូចគ្នា គឺគេវាយគេមានដែក ៗដែលភ្លៅរទេះហ្នឹង ដែកខ្នោះហ្នឹង ហើយនិងកាំបិតដែលគេវាយហើយ គេនឹងសម្លាប់អារ-ក អារអីសម្លាប់នឹងកាំបិត បាទ។

[០៩:៤៩:៥៣]

**ស៖** ហើយចំណុចចុងក្រោយ<លោកនិយាយ>នៅក្នុងវីដេអូនេះ<>ថា ក្មេង<ៗ>ត្រូវបានគេចងមុខ ហើយចងស្លាបសេក <តើក្មេងៗទាំងនោះត្រូវបានគេចងមុខ និងចងស្លាបសេកតាំងពី>ពេល<>លោកបាន<ប្រគល់ទៅឲ្យ> ប៉េង <>ឬ<យ៉ាងម៉េច>?

**ឆ៖** បាទ ពេលហ្នឹងពេលដែលខ្ញុំយកទទួលពេលមួយគ្នាដែរ បាទយកកូនចេញហើយ ក៏ត្រូវយកម៉ែឪហ្នឹងចេញទៅដែរ។ បាទអ៊ីចឹងជួយប្រមូលឲ្យ ប៉េង សិនទៅ ហើយចាំយើងយកម៉ែឪទៅតាមក្រោយ ព្រោះកុំឲ្យរញ៉េរញ៉ៃ បែកការណ៍ ឡូឡាពេញគុកហ្នឹង។

**ប្រធានអង្គជំនុំ៖**

សំណួរមិនអ៊ីចឹងទេ សំណួរពាក់ព័ន្ធជាមួយនឹង ពាក់ព័ន្ធជាមួយនឹងក្មេងទេ ក្មេងពេលដែលនាំចេញ យកចេញមកហ្នឹង នាំចុះមកហ្នឹងមានចងសេក ចងដៃ ហើយនិងចងមុខដែរឬទេ? ដូចមនុស្សចាស់ដែរឬទេ? នេះជាសំណួរ គោលដៅសំណួរសួរនេះគឺសួរចំណុចនេះ។ ឯចំណុចដែលលោកឆ្លើយអំមិញនេះ លោកឆ្លើយរួចហើយ។

**លោក ហ៊ីម ហ៊ុយ៖**

**ឆ៖** បាទ គឺក្មេងដែលធំៗគឺគេចងដូចមនុស្សចាស់ដែរបាទ។ គេខ្លាចក្មេងហ្នឹងរត់។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** ចុះទារកវិញ ឬក៏កុមារតូចៗ<វិញ គេធ្វើយ៉ាងម៉េចដែរ? តើមានទារក ឬក្មេងតូចៗនៅក្នុងក្រុម> ដែលលោកបាន<ប្រគល់ទៅឲ្យ> ប៉េង <នៅក្នុងឱកាសនោះ>ដែរ<ទេ>?

**ឆ៖** ហ្នឹងពួកហ្នឹងគេអ្នកប្រមូល គេបីគេអីយកទៅ អាណានេះធំគេពយកទៅបាទ។

[០៩:៥១:៥៩]

**ស៖** តើលោក<>មាន<ជួយ>បី<ទារកចុះទៅក្រោមទេ>?

**ឆ៖** បាទ ខ្ញុំអត់មានបីមានអីទេ ពីព្រោះខ្ញុំ ពួកកម្លាំងនៅខាងក្នុងហ្នឹងហើយដែលអ្នកបីក្មេងហ្នឹង ហើយពក្មេងហ្នឹងយកទៅ អ្នកការពារហ្នឹង ដែលអ្នកយកទៅសម្លាប់បាទ។ ពួកខ្ញុំចាំតែយកតែអ្នកនេះហ្នឹងទៅទេ អ្នកដែលម៉ែឪហ្នឹងយកទៅទេ។ ប៉ុន្តែគ្រាន់តែជួយយកក្មេងៗចុះមកដល់ដីឲ្យគេហ្នឹងបាទ ប្រគល់ឲ្យគេត្រឹមហ្នឹង គេយកចេញទៅ។

**លោក ត្រាវីស ហ្វារ៖**

លោកប្រធាន ខ្ញុំមានវីដេអូឃ្លីបមួយទៀត ពាក់ព័ន្ធនឹងប្រធានបទនេះផងដែរ។ ដោយសុំការអនុញ្ញាតបញ្ចាំងហ្នឹងគឺ E3/536R គឺវាមានរយៈពេល<ពី>នាទី<២៨:៤៥ វិនាទី> រហូតទៅដល់២៩:១៥វិនាទី។ អ៊ីចឹងខ្ញុំសូមអនុញ្ញាតលោកប្រធានចាក់វីដេអូ*ឃ្លីប*នេះមួយទៀត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ ហើយផ្នែកសោតទស្សន៍ចាក់ផ្សាយវីដេអូឃ្លីបតាមសំណើសុំរបស់សហព្រះរាជអាជ្ញារងអន្តរជាតិលើអេក្រង់ទូរទស្សន៍។

[០៩:៥៣:២៦]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"... ក្រោយពី (ឮមិនច្បាស់) បីបួនប្រាំនាក់ហ្នឹងមកណា ចុងក្រោយខ្ញុំជួប (ឮមិនច្បាស់) ហ៊ីម ហ៊ុយ។ ជួបកាលនេះ គេយកសម្លាប់ទាំងអស់ សម្លាប់ពេលទុំងឯង។ កូនក៏គេយកទៅសម្លាប់ដែរ អត់ទុក យកទៅសម្លាប់។..."*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[០៩:៥៣:៥៩]

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** លោកសាក្សី នៅក្នុងចំណុចដំបូងគឺមិនមែនជាលោកជាអ្នកនិយាយទេ គឺលោក ណាត គឺ គាត់បានបញ្ជាក់ថា <គាត់បានឃើញអ្នកយាមពរ>ទារក<បី បួន ឬប្រាំនាក់នៅក្នុងដៃ> ហើយគាត់ <ថា គាត់>បានជួបលោក ហើយ<>ថា<លោកជាមនុស្សម្នាក់ ក្នុងចំណោមអ្នកផ្សេងៗទៀត ដែលបានពរ>ទារក<>យកចេញទៅ។ តើត្រឹមត្រូវដែរឬទេ?

**លោក ហ៊ីម ហ៊ុយ៖**

**ឆ៖** បាទ គឺត្រឹមត្រូវដែលយកចេញទៅហ្នឹង។

**ស៖** ហើយ<>គាត់ក៏បានបញ្ជាក់<ដែរ>ថា <ក្រោយមក>លោកប្រាប់គាត់ថា កុមារហ្នឹងត្រូវបានគេបញ្ជូនដើម្បីទៅសម្លាប់។ តើលោក<នៅចាំថា>មានប្រាប់ទៅលោក ណាត ហ្នឹងថាអីចឹងដែរឬទេ?

**ឆ៖** បាទ តែដឹកម៉ែឪចេញទៅហើយ គេយកក្មេងហ្នឹងទៅមុនហើយ យកទៅសម្លាប់មុនហើយ បានយកម៉ែឪឡើងឡាន ពួកហ្នឹងយកកូនទៅ ពួកខ្ញុំយកម៉ែឪហ្នឹងទៅឡើងឡាន។

**ស៖** នៅពេលដែលយើងប្រើពាក្យថា "ទារក" តើវាទារកនោះមានអាយុប៉ុន្មានខែ? ហើយតើការសំដៅលើក្មេងដែលមិន<>ចេះដើរ ឬមួយក៏យ៉ាងណា អាចបញ្ជាក់ពីអាយុរបស់វាបានទេ?

**ឆ៖** បាទខ្ញុំបញ្ជាក់ប្រាប់ថា មានពីត្រឹមពបីដូចអំមិញអីចឹង ពី១ខែឡើងទៅហ្នឹង គឺថាគេយកទៅ ទាំងអាយុប្រហែល៧, ៨ឆ្នាំហ្នឹង។

[០៩:៥៦:០០]

**ស៖** ខ្ញុំសូមបន្តទៅប្រធានបទមួយទៀត។ <>អម្បាញ់មិញ យើងនិយាយអំពីកុមារ ឥឡូវយើងនិយាយអំពីការសម្លាប់កងទ័ពវៀតណាម មិនមែនទៅជើងឯកទេ គឺយើងនិយាយតែនៅក្នុងទួលស្លែង

ទេ។ ថាតើលោកធ្លាប់ឃើញថា មានកងទ័ពវៀតណាមត្រូវបានគេសម្លាប់នៅក្នុងបរិវេណទួលស្លែងនេះដែរឬទេ?

**ឆ៖** បាទ កងទ័ពវៀតណាមដែលចាប់បានយកមក គេសួរចម្លើយហើយ គឺគេសម្លាប់នៅខាងក្រោយគុកទួលស្លែង ហើយនិងខាងត្បូងហ្នឹង។

**ស៖** ហើយអ្នកណាជាអ្នកសម្លាប់ទាហានវៀតណាមនៅប៉ែក<>ខាងត្បូងនៅក្នុងបរិវេណនៃគុកទួលស្លែងនេះ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា គឺក្រុម ប៉េង ដែលអ្នកយកទៅសម្លាប់នៅកន្លែងហ្នឹង។

**ស៖** តើលោកដឹងទេថាតើក្រុម ប៉េង ហ្នឹងសម្លាប់កងទ័ពវៀតណាមហ្នឹងប៉ុន្មានដងដែរនៅឯគុកទួលស្លែងនោះ?

**ឆ៖** បាទ គឺខ្ញុំអត់បានដឹងដែរ ព្រោះទ័ពវៀតណាមហ្នឹង ដែលចាប់បានមកចំនួនប្រហែលជា៤០នាក់ ឬមួយក៏ហាហុកសិបនាក់ ក៏មិនដឹងដែរកាលហ្នឹង។

**ស៖** តើពួកគេទាំង៤០, ៥០<, ៦០>នាក់ហ្នឹង ត្រូវបានគេចាប់នៅ<>ពេលតែមួយ<> ឬមួយក៏<ជាចំនួនសរុបរបស់កងទ័ពវៀតណាម នៅក្នុងអំឡុង>ពេល<ដែលលោកបានដឹងនោះ>?

[០៩:៥៨:០៩]

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា ការចាប់នេះគឺផ្សេងគ្នា។ ខ្ញុំទៅយកនៅអីខាងបូព៌ានៅស្វាយរៀងពីរដង។ ម្តងបានគ្នាប្រាំនាក់មក ហើយម្តងទៀតប៉ុន្មាននាក់ ក៏ខ្ញុំមិនបានចាំដែរ។ ហើយក្រៅពីហ្នឹង ពី៧០៣ បញ្ជូនមក ហើយពីខាងណាទៀតបញ្ជូនមកទេកាលហ្នឹង។

**ស៖** ជាថ្មីម្តងទៀត ខ្ញុំចង់សួរពាក់ព័ន្ធទៅនឹងចម្លើយដែលលោកបានឆ្លើយទៅដល់អ្នកស្រាវជ្រាវ គឺឯកសារ E3/5155, ERNជាភាសាអង់គ្លេស00161591, ខ្មែរគឺ <00146639>, បារាំង 001480 84។ គឺគេសួរលោកថា <>"ទាក់ទងទៅនឹងការយកអ្នកទោសទៅសម្លាប់ តើគេទុកឲ្យពួកកងទ័ពវៀត-ណាមនៅយូរជាងគេមុនយកទៅសម្លាប់ ឬមួយយ៉ាងណា?" <ហើយលោកឆ្លើយ សូមដកស្រង់> "គេបានទុកពួកកងទ័ពវៀតណាមហ្នឹង<ប្រហែលកន្លះ>ខែ។ <ក្រោយពី>សួរចម្លើយ <>គេ<យកអ្នកទាំងនោះទៅ>សម្លាប់។ <គេ>សម្លាប់<អ្នកទាំងនោះរួមគ្នា>នៅក្រោយគុកទួលស្លែងនោះ។ ហើយក្រុម ប៉េង ហើយនិងក្រុមខ្ញុំជាអ្នកទទួលបន្ទុកនោះ។" <ដូច្នេះ>នៅក្នុង<>សម្រង់នេះ <>លោក<> និយាយថា ក្រុមដែលសម្លាប់កងទ័ពវៀតណាមនេះ គឺក្រុមលោក និងក្រុម ប៉េង <តើត្រឹមត្រូវទេ? តើ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សមាជិកក្រុមរបស់លោកជាប់ពាក់ព័ន្ធនឹងការសម្លាប់អ្នកទោសជាកងទ័ពវៀតណាមនោះទេ>?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា ពេលដែលយកទៅសម្លាប់ហ្នឹង គឺគេឲ្យពួកក្រុមហ្នឹងជួយៗបណ្ដើរយកទៅ បាទជាមួយពួកខាងក្នុងហ្នឹង ខាងការពារហ្នឹង ជួយបណ្ដើរយកទៅ។ តែការសម្លាប់មិនដឹងជាខាងណា ខាងណីទេ ព្រោះខ្ញុំអត់បានទៅកន្លែងហ្នឹង ខ្ញុំនៅកន្លែងចាំទទួលអ្នកទោសដែលគេបញ្ជូនមកទៀត។

[១០:០០:៤០]

**ស៖** អ៊ីចឹងខ្ញុំចង់បញ្ជាក់ថា តើខ្ញុំយល់លោកច្បាស់នោះ។ តើសមាជិកក្រុមលោក ឬក៏អ្នកដែលក្រោមបង្គាប់លោក មានពាក់ព័ន្ធទៅនឹងការសម្លាប់ជាក់ស្ដែងទៅលើកងទ័ពវៀតណាមនៅឯបរិវេណគុកទួលស្លែងដែរឬទេ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា ខ្ញុំអត់បានដឹង ហើយអត់មានសាកសួរអីគេទៀតទេ គ្រាន់គេឲ្យពួកខ្ញុំជួយបណ្ដើរទៅ ជាមួយពួកខាងក្នុងហ្នឹង ព្រោះបណ្ដើរទៅ កាន់ម្នាក់មួយ ម្នាក់មួយយកទៅ បណ្ដើរយកទៅ។

**ស៖** ឥឡូវខ្ញុំសូមបន្តទៅប្រធានបទមួយទៀត ហើយខ្ញុំសូមសួរពាក់ព័ន្ធនឹងលោកម្នាក់ដែល <យើងបានពិភាក្សាកាលពីម្សិលមិញ>ឈ្មោះថា ប៉ូច។ តើមានអ្វីកើតឡើងចំពោះ<>បុគ្គលម្នាក់ដែលឈ្មោះថា ប៉ូច <នៅស-២១>?

**ឆ៖** បាទ ប៉ូច ហ្នឹងគឺកងរយ បាទ។ កងរយ កងការពារហ្នឹង។

**ស៖** តើនៅពេលនោះ គឺគាត់ត្រូវបានគេចាប់ខ្លួននៅពេលណាដែរ?

**ឆ៖** ខ្ញុំភ្លេចហើយ ដូចឆ្នាំ៧៧ដែរ។

**ស៖** តើលោកអាចបញ្ជាក់អំពីការចាប់<ខ្លួននោះ ហើយនិងព្រឹត្តិការណ៍បន្តបន្ទាប់មកទៀតបាន>ទេ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា ការចាប់ខ្លួនអ្នកធ្វើការក្នុង ខ្ញុំអត់ដឹងទេ។ វាចេះតែបាត់មនុស្សពេលហូបបាយចេះតែបាត់មនុស្ស។

[១០:០៣:១០]

**ស៖** តើមានអ្នកណាម្នាក់ទៀត ឬក៏អ្នកដទៃទៀត ត្រូវបានគេចាប់ខ្លួនដែរឬទេ នៅពេលដែលមានការចាប់ខ្លួន ប៉ូច ហ្នឹង?

**ឆ៖** បាទ គឺចាប់តទៀត គឺកងរយ បីបួននាក់ទៀត។ ចាប់ ស្លួន មួយហើយ ម៉ាន មួយជនជាតិចាម ហើយជនជាតិចាមពីរនាក់ គឺសុទ្ធតែកងរយ ធ្វើការនៅកន្លែងហ្នឹង។ ឈ្មោះ ឆន ហៅ ម៉ាន ដែរ។

**ស៖** តើពួកគេទាំងនេះ ត្រូវបានគេចាប់ខ្លួននៅក្នុងអំឡុងពេលដែលគេចាប់ខ្លួន ប៉ូច ហ្នឹងដែរ <ឬ?> ឬ<ក៏វាជាផ្នែកនៃព្រឹត្តិការណ៍ដាច់តែឯងទេ>?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា ប្រហែលជាបន្ទាន់គ្នាដែរ។ សួរមួយ ឆ្លើយមួយ ចាប់មួយ ចាប់បន្តគ្នារហូត។

**ស៖** តើមានអ្នកណាដែលប្រាប់លោក<>ទេ ថាតើមានអ្វីកើតឡើងចំពោះលោក ប៉ូច ក៏ដូចជាអ្នកដែលត្រូវចាប់ខ្លួន<នៅពេលដំណាលគ្នានឹងគាត់>ដែរឬទេ?

**ឆ៖** បាទគឺខ្ញុំអត់បានដឹងថា ចាប់ខ្លួនដោយសាររឿងអីៗ អត់ដឹងទេ ប៉ុន្តែចេះតែបាត់គ្នា ចាប់បន្តរហូត បាទចាប់បន្តរហូទនៅកន្លែងហ្នឹង។ ក្រុមរបស់ខ្ញុំ ក៏គេចាប់ដែរ។

**ស៖** តើមានអ្នកណាម្នាក់ប្រាប់ទៅលោកទេ ថាតើមានអ្វីកើតឡើងចំពោះ ប៉ូច ហ្នឹងបន្ទាប់ពីការចាប់ខ្លួនរបស់គាត់ហ្នឹង តើលោកមានបានព័ត៌មាន ឬឮពីណាទេ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា ខ្ញុំអត់មានដឹងព័ត៌មានពីណាទេ ព្រោះអត់មាននរណានិយាយប្រាប់អ្នកណាទេ ការចាប់ខ្លួនម្នាក់ៗ គឺម្នាក់ៗឃើញគេចាប់ខ្លួន ឃើញគេបណ្តើរយកសួរចម្លើយហ្នឹង គឺដូចខ្ញុំភ័យខ្លួន បាទព្រោះក្រុមរបស់ខ្ញុំក៏គេចាប់ដែរ។

[១០:០៥:៤០]

**ស៖** ខ្ញុំសូមអានសម្រង់មួយពាក់ព័ន្ធនឹងចម្លើយដែលលោកបានបញ្ជាក់នោះ<> គឺពាក់ព័ន្ធនឹង E3/5158, ERN ជាភាសាអង់គ្លេសគឺ 00164451, ភាសាបារាំង00164454, ខ្មែរ00164447។ សំណួរបានសួរទៅលោកថា៖ "តើលោកមានទទួលដំណឹងពាក់ព័ន្ធទៅនឹង ប៉ូច នេះទេ? ហើយលោកឆ្លើយថា៖ គាត់ត្រូវបានចាប់ខ្លួននៅឆ្នាំ៧៧ <>ប្រហែលជាបញ្ជារបស់ ឌុច <ដោយសារថា គ្មាននរណាក្រៅពីឌុចទេ សូម្បី> ហ៊ី <ក៏មិនមានអំណាច>ចេញបទបញ្ជា<ឲ្យ>ចាប់<នរណាម្នាក់ដែរ>។ ហើយគេសួរលោកទៀត៖ ថាតើលោកដឹងពីវាសនារបស់ ប៉ូច ហ្នឹងទេបន្ទាប់ពីចាប់ខ្លួននោះ? <ហើយលោក> ឆ្លើយថា៖ នៅពេលនោះ គឺមិនទាន់មានកន្លែងសម្លាប់ ឬវាលពិឃាតជើងឯកនោះទេ។ <ក្នុងអំឡុងពេលប្រជុំមួយ ឌុច បានប្រាប់យើងថា អ្នកដែលមកពីកងពល៧០៣ ហើយកំពុងធ្វើការនៅ ស-២១ ហើយអ្នកដែលត្រូវបានអ្នកទោសមកពី>កងពល៧០៣<ឆ្លើយដាក់> ត្រូវបានគេចាប់ ហើយ<សួរចម្លើយ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

និង>សម្លាប់នៅក្នុងបរិវេណគុកទួលស្លែង។” បញ្ចប់ការដកស្រង់។

តើខ្ញុំអាននេះអាចធ្វើឲ្យលោកនឹកឃើញបានទេ? <តើលោកចាំ>ថាលោកបានចូលរួមនៅក្នុងអង្គប្រជុំមួយដែល ឌុច ប្រាប់<លោក>ថា <>បុគ្គលមួយចំនួន<មកពី>កងពល៧០៣ <ហើយធ្វើការនៅស-២១>នោះត្រូវបានចាប់ខ្លួន ហើយក្រោយមកទៀតក៏ត្រូវបានសម្លាប់នៅក្នុងបរិវេណគុកទួលស្លែងនេះដែរឬទេ?

**ឆ៖** បាទគឺខ្ញុំសន្និដ្ឋានថា ចាប់៧០៣មក គឺឆ្លើយដាក់ បងប៉ូច ហ្នឹង។ ឆ្លើយដាក់ បងប៉ូច ហ្នឹង ហើយ គេត្រូវការចាប់ខ្លួន បងប៉ូច ហ្នឹងទៀត។ នឹកឃើញថាការចាប់ខ្លួននេះ ប្រហែលជាមានចាប់បន្តទៀត ប៉ុន្តែមិនដឹងតាមរយៈអ្នកណាទេ ប៉ុន្តែអ្នកដែលដាក់បញ្ជាមកគឺ តាឌុច។ ហើយ តាឌុច ហ្នឹងបញ្ជាមក តាហ៊ី, តាហ៊ី បញ្ជាទៅឲ្យពួក ប៉េង ធ្វើការចាប់ខ្លួនហ្នឹង។

[១០:០៨:១៣]

**ប្រធានអង្គជំនុំ៖**

បាទ បាន១។ បាទ មុននឹងសម្រាកអង្គជំនុំជម្រះសូមរំឭកសាក្សីថា សាក្សីមានការប្រុងប្រយ័ត្ន សូមត្រូវមានការប្រុងប្រយ័ត្នក្នុងការឆ្លើយតប ការឆ្លើយតបឯណាដែលលោកប្រើពាក្យថាតាមការសន្និដ្ឋានរបស់លោកមិនត្រឹមត្រូវទេ លោកមិនមែនអ្នកជំនាញទេ។ សាក្សី យើងបានប្រាប់ហើយកាតព្វកិច្ច ឃើញ ដឹង ឮច្បាស់លាស់ បទពិសោធន៍ឆ្លងកាត់ ហើយឬក៏ការសង្កេតរបស់ខ្លួន នេះគឺផ្អែកលើមូលដ្ឋានទាំងអស់នេះដើម្បីឆ្លើយតបនឹងសំណួរ។ ទី២ ចម្លើយតបហ្នឹង គឺមិនគប្បីប្រើពាក្យស្មានទេ។ “ស្មាន” ហ្នឹងវាស្មើ “មិនដឹង”។ បើឮអ្នកណា បុគ្គលណានិយាយប្រាប់គឺសូមបញ្ជាក់ឲ្យបានច្បាស់លាស់ ហើយជៀសវាងការឆ្លើយតបទៅ វាមិនអាចប្រើប្រាស់បាននៅក្នុងការរួមវិភាគទានក្នុងការស្វែងរកការពិតទេ។ បាទទោះបីយ៉ាងណា ក៏អង្គជំនុំជម្រះអរគុណចំពោះសាក្សីដែលបានប្រឹងប្រែងឆ្លើយតបនឹងសំណួរ។ ហើយយើងសង្ឃឹមថា លោកនឹងផ្ចិតផ្ចង់នៅក្នុងការគិតដើម្បីឆ្លើយតបហ្នឹងឲ្យត្រូវនឹងសំណួរ ហើយត្រូវនឹងតាមលក្ខខណ្ឌបច្ចេកទេសនៃកិច្ចដំណើរការនីតិវិធី តាមកាតព្វកិច្ចក្នុងនាមជាសាក្សីដើម្បីរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។

បាទឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01297771



សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:១០ នាទី ដល់ម៉ោង ១០:៣០ នាទី)*

[១០:៣០:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីវសនាការ ហើយផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** សូមអរគុណលោកប្រធាន។ លោកសាក្សី មុនពេលយើងឈប់សម្រាក លោកបាននិយាយថា ក្រោយពីគេចាប់ខ្លួន ហ៊ុយ ស្រែ ទៅ កូននិងប្រពន្ធរបស់ ហ៊ុយ ស្រែ ក៏ត្រូវបានគេចាប់ខ្លួនដែរ។ តើលោកដឹងទេ ពេលនុ៎ងកូនរបស់ ហ៊ុយ ស្រែ មានអាយុប៉ុន្មានឆ្នាំដែរ?

**លោក ហ៊ីម ហ៊ុយ៖**

**ឆ៖** ខ្ញុំមិនបានចាំថាអាយុប៉ុន្មានទេ ប៉ុន្តែកូននោះនៅតូច ហើយចាប់នៅហ្នឹង ចាប់ហ្នឹងគឺខ្ញុំនៅធ្វើស្រែដែរ ចាប់គាត់ហ្នឹង។ បាទ ខ្ញុំទៅអត់ទាន់ ចាប់នៅកន្លែងផ្ទះលោក លន់ ណុន។

**ស៖** តើលោកស្គាល់ឈ្មោះកូនៗ និងប្រពន្ធរបស់គាត់ទេ?

[១០:៣១:១៧]

**ឆ៖** ប្រពន្ធគាត់ខ្ញុំភ្លេចឈ្មោះហើយ ដូចឈ្មោះ ខឿន ឈ្មោះអីមិនដឹងទេ។ ហើយគាត់នេះឈ្មោះ ហ៊ុយ។ ប្អូនបងហ៊ុយ នោះឈ្មោះ ហឿន មួយទៀត។ ហើយកូនគាត់ដឹងឈ្មោះអី ខ្ញុំអត់បានស្គាល់ឈ្មោះដែរ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំនឹងចូលសួរអំពីជើងឯក ប៉ុន្តែដំបូងសុំឲ្យលោកផ្តោតទៅលើអំឡុងពេលក្រោយពេលគេបង្កើតជើងឯងហើយ។ ក្រោយពីបង្កើតជើងឯកហើយ គេនៅបន្តសម្លាប់មនុស្សនៅបរិវេណទួលស្លែងដែរទេ? មានន័យថា ទោះបីជាគេដឹកជញ្ជូនអ្នកទោសយកទៅជើងឯកក្តី តើគេមានបន្តសម្លាប់មនុស្សនៅទួលស្លែងនេះតទៅទៀតទេ?

**ឆ៖** បាទ ពេលនោះគឺខ្ញុំអត់បានចាំដែរ ប៉ុន្តែបើយកទៅជើងឯក ចំណែកពួកកម្មាភិបាលធ្វើការកន្លែងហ្នឹង ហើយពួកអ្នកយាមអ្នកអីហ្នឹង ក៏គេនៅតែសម្លាប់ទួលស្លែងហ្នឹងដែរ បាទ។

**ស៖** ខ្ញុំសុំសួរលោកចេញពីចម្លើយរបស់លោក គឺឯកសារ E3/5155, អង់គ្លេស 00161592, ខ្មែរ 00146640 និងបារាំង 00148085។ គេបានសួរលោកថា៖ "ក្រៅពីជើងឯក និងស-២១ តើមានទីតាំងផ្សេងទៀត ដែលត្រូវគេសម្លាប់មនុស្សទេ? លោកឆ្លើយថា សុំដកស្រង់៖ មានតែទីតាំងពីរកន្លែងនេះទេ។ សូម្បីនៅពេលដែលជើងឯកបានបង្កើតហើយក៏ដោយ ក៏គេនៅតែបន្តសម្លាប់មនុស្សនៅ <ស-២១ នៅពេលដែលចំនួនតិច ហើយជាមនុស្សសំខាន់>។" តើនេះជួយរំឭកដល់ការចងចាំរបស់លោកទេ ថាការសម្លាប់នៅតែបន្តសម្លាប់មនុស្សជាក្រុមតូចៗនៅជុំវិញទួលស្លែង <សម្រាប់មនុស្សសំខាន់> សូម្បីតែក្រោយពេលគេបង្កើតជើងឯកហើយក្តី? លោកនៅចាំថា លោកបានឆ្លើយថាយ៉ាងដូច្នេះទេ?

[១០:៣៣:៤៨]

**ឆ៖** បាទ គេនៅៗសម្លាប់នៅជើងឯក អ្ហា!នៅទួលស្លែងដែរ ព្រោះអ្នកដែលធ្វើការនៅកន្លែងហ្នឹង ដូចខ្ញុំជម្រាបអ៊ីចឹង គេអត់ឲ្យយកទៅជើងឯកទេ ព្រោះអ្នកធ្វើការដឹងខ្លួនហើយ។ អ៊ីចឹងគេសម្លាប់នៅទួលស្លែងហ្នឹង។

**ស៖** ដូច្នេះលោកនិយាយថា បុគ្គលិកស-២១ ត្រូវបានគេបន្តសម្លាប់នៅជុំវិញទួលស្លែង។ ចុះ <តើមាន>ក្រុមមនុស្សដទៃទៀត ត្រូវបានគេបន្តសម្លាប់នៅម្តុំស-២១ហ្នឹងដែរឬ ក្រោយគេបង្កើតជើងឯកហើយ?

**ឆ៖** បាទ គឺគេដឹកយកទៅជើងឯក។ តែកម្មាភិបាលធំៗទេ ដែលគេសម្លាប់នៅទួលស្លែងហ្នឹង។

**ស៖** ខ្ញុំសូមចូលសួរលោកអំពីជើងឯកតែម្តងឥឡូវនេះ និងសួរលោកអំពីការបង្កើតជើងឯក និងការប្រតិបត្តិការនៅទីនោះ។ តើមានអ្នកណាម្នាក់ធ្លាប់បានប្រាប់លោកថា មូលហេតុអ្វីបានជាគេបង្កើតជើងឯក ហើយផ្លាស់ប្តូរទីតាំងសម្លាប់មនុស្សពីស-២១ ទៅសម្លាប់នៅជើងឯក? មានដែលអ្នកណាប្រាប់លោកអំពីការមូលហេតុនៃការបង្កើតជើងឯកនេះទេ?

**ឆ៖** បាទ ពេលនោះគឺ តាហ៊ី អ៎!តាឌុច និយាយជាមួយ តាហ៊ី។ និយាយជាមួយ តាហ៊ី នៅផ្ទះតាហ៊ី ហ្នឹងថា យើងឈប់សម្លាប់នៅទួលស្លែងទៀត យើងយកទៅជើងឯក។ ទៅមើលទីតាំងជើងឯកដាក់ជើងឯកទៀត បាទ។

**ស៖** តើលោកនៅចាំ ឬក៏លោកបានរៀនសូត្រអំពីមូលហេតុនេះទេ ថាហេតុអ្វីបានជាគេផ្លាស់

ប្តូរទីតាំងសម្លាប់មនុស្សពីទួលស្លែង ទៅសម្លាប់នៅឯជើងឯក?

[១០:៣៦:១៦]

**ឆ៖** បាទ គេនិយាយថា ទួលស្លែងលែងសម្លាប់ហើយ ខ្លាចបែកការណ៍ ខ្លាចអន្តរជាតិដឹង បែកការណ៍។ អ៊ីចឹងគេឲ្យទៅដាក់ទីតាំងនៅជើងឯកវិញ។

**ស៖** ឥឡូវខ្ញុំសួរលោកអំពីសម្តីដែល ឌុច បាននិយាយ ពាក់ព័ន្ធនឹងការបង្កើតជើងឯក។ នេះគឺឯកសារ E3/5766 នេះគឺជាការសួរតទល់ជាមួយនឹងសាក្សី ដែលលោកក៏បានចូលរួម<ជាមួយអ្នកផ្សេងៗទៀត>ដែរ <គឺនៅពីរថ្ងៃ> ក្រោយពីលោកបានចូលទៅកន្លែងស៊ើបអង្កេតផ្ទុំអង្គហេតុឡើងវិញ។ ERN ជាភាសាអង់គ្លេស 00165437, ខ្មែរ 00165428, បារាំង 00165445។ មានការពិភាក្សាគ្នាអំពីការ<ប្តូរទីកន្លែង>សម្លាប់<ទៅ>ជើងឯក។ ចំណុចមួយដែល ឌុច និយាយនោះ សូមដកស្រង់៖ "ដូចខ្ញុំបានពន្យល់រួចមកហើយ វាមានហានិភ័យពាក់ព័ន្ធទៅនឹងជំងឺឆ្លងជុំវិញទីនោះ ដោយសារថា នៅជុំវិញនោះកប់ខ្មោចច្រើនពេក។" តើលោកឮ ធ្លាប់ស្តាប់ឮមូលហេតុនេះពី ឌុច ឬពី តាហ៊ី ដែលថាមូលហេតុដែលគេត្រូវផ្លាស់ប្តូរទីតាំងសម្លាប់មនុស្សនេះ ដោយសារតែការភ័យខ្លាចប្រឈមទៅនឹងជំងឺឆ្លង ដោយសារនៅជុំវិញទួលស្លែងនេះ កប់ខ្មោចច្រើនពេក លោកធ្លាប់ដែលឮមូលហេតុនេះទេ?

**ឆ៖** បាទ ខ្ញុំឮ ព្រោះគាត់និយាយថា កន្លែងនេះវាស្អុយ ហើយមួយទៀត ខ្លាចរនែ មួយទៀត វាច្រើនពេកហើយ កប់ហ្នឹង។ អ៊ីចឹងគេដូរទីតាំងទៅជើងឯកវិញ។

**ស៖** មុននឹងយើងចូលនិយាយអំពីប្រតិបត្តិការនៅជើងឯក ខ្ញុំយល់ឃើញថា នេះជាសំណួរពិបាកហើយ ក៏ប៉ុន្តែលោកអាចប៉ាន់ប្រមាណចំនួនអ្នកដែលត្រូវគេសម្លាប់ ទាំងនៅស-២១ គឺទួលស្លែង និងជើងឯក សរុបគ្នាទាំងពីរកន្លែងនេះ លោកប៉ាន់ប្រមាណមើលទៅ គេសម្លាប់មនុស្សអស់ប៉ុន្មាននាក់ដែរ?

[១០:៣៨:៥៧]

**ឆ៖** បាទ ខ្ញុំអត់មានកាន់ឯកសារអីអស់ហ្នឹងទេបាទ ប៉ុន្តែខ្ញុំថាច្រើន រាប់ម៉ឺននាក់ហើយ។

**ស៖** ហេតុអ្វីបានលោកនិយាយថា មនុស្សរាប់ម៉ឺននាក់ហើយ ដែលត្រូវបានគេយកទៅសម្លាប់នៅទីតាំងពីរកន្លែងនេះ?

**ឆ៖** បាទ ព្រោះខាងមជ្ឈមណ្ឌលសរុបមើលទៅ តាមយកភ័ស្តុតាងបាន គឺជាងជិត២០.០០០នាក់ណោះ។

**ប្រធានអង្គជំនុំ៖**

ឥឡូវហ្នឹងគេសួរលោក ជាបទពិសោធន៍របស់លោក អារឿងបញ្ហាឯកសារមជ្ឈមណ្ឌលហ្នឹង គឺជាការរៀបចំក្រោយទេ។ និយាយពីរឿងការដឹងរបស់លោក គឺគប្បីលោកឆ្លើយអំពីការដឹងរបស់លោក បទពិសោធន៍របស់លោក និងការសង្កេតរបស់លោក នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ កាលណាលោកឆ្លើយមកក្រោយៗទៀតនេះ វាជារឿងហេតុផ្សេង មិនបញ្ជាក់ថា លោកដឹង បានឃើញ បានសង្កេត បានកត់សម្គាល់ និងឆ្លងកាត់បទពិសោធន៍របស់លោកដោយខ្លួនឯងទេ។ សក្ខីកម្មរបស់លោកត្រូវផ្ដល់នូវអ្វីដែលលោកបានយល់ដឹង បានឃើញ បានឮ បានប្រព្រឹត្ត បានធ្វើ ហើយនិងបានធ្វើការសង្កេត កត់សម្គាល់ផ្ទាល់ដោយខ្លួនឯង។ ព័ត៌មាននេះ គឺការយល់ដឹងពេលដែលលោកធ្វើការនៅមន្ទីរសន្តិសុខស-២១។ តើលោកកាលនោះ គឺលោកមានការប៉ាន់ប្រមាណប៉ុណ្ណឹង តើលោកមានមូលដ្ឋានអីដែលសង្កេតយ៉ាងម៉េច បានជាលោកឆ្លើយថា មានរហូតដល់រាប់ម៉ឺននាក់?

[១០:៤០:៤៧]

**លោក ហ៊ឹម ហ៊ុយ៖**

**ស៖** បាទ ខ្ញុំសូមជម្រាបថា បើនៅទួលស្លែងផង ហើយនៅជើងឯកផង ឃើញរណ្ដៅមួយគំនរពីរគំនរ ខ្ញុំនឹកឃើញថា ច្រើន។ ប៉ុន្តែមិនដឹងប៉ុន្មាន ទាល់សួរបង សួស ធី បានដឹងថា មានចំនួនប៉ុន្មាន ព្រោះគាត់អ្នកសរុបបញ្ជីអាហ្នឹង បាទ។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** ឥឡូវនេះខ្ញុំសូមចូលទៅនិយាយអំពីបញ្ហា<យន្តការនៃ>ប្រតិបត្តិការនៅជើងឯក។ តើលោកអាចជម្រាបជូនតុលាការបានទេថា <តើលោកធ្វើម៉េចដឹងថា> វាជាពេលវេលាដែលត្រូវលោកដឹកជញ្ជូនអ្នកទោសទៅជើងឯក? តើអ្នកណាជាអ្នកប្រាប់លោកថា វាដល់ពេលវេលាដែលលោកត្រូវដឹកជញ្ជូនអ្នកទោសពីទួលស្លែងទៅជើងឯកហើយ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា ពេលដែលគេបញ្ជាខ្ញុំគឺ តាហ៊ី។ តាហ៊ី ឱ្យពួកខ្ញុំរៀបចំឡានចូលដឹកអ្នកទោសទៅជើងឯក។ ហើយពួកក្រុមខ្ញុំក៏រៀបឡានចូលទៅ ដឹកពីទួលស្លែងហ្នឹងទៅជើងឯក ទៅឱ្យខាងពួក បងប៉េង នៅជើងឯកហ្នឹង បាទ។

**ស៖** តើ<រយៈពេលប៉ុន្មានមុននឹងដឹកអ្នកទោសទៅ ដែល> តាហ៊ី <>ប្រាប់លោក<ឱ្យដឹងដើម្បីធ្វើការងារនេះ? តើគាត់ប្រាប់លោកមួយម៉ោងមុន ឬក៏ជូនដំណឹងមួយថ្ងៃ ឬក៏ពីរថ្ងៃមុន>?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ គេប្រាប់ពីដូចថា ម៉ោងបួនម៉ោងអីអ៊ីចឹង ពេលថ្ងៃរសៀលហ្នឹង គេប្រាប់ថាថ្ងៃនេះ យកអ្នកទោសដែលសួរចម្លើយហើយប៉ុន្មានហ្នឹង យកទៅជើងឯក បានឲ្យពួកខ្ញុំរៀបចំមើលឡានដាក់ប្រេងដាក់អី ឡានហ្នឹង។ ហើយទៅឡានប៉ុន្មាន អីប៉ុន្មាន គេប្រាប់ឲ្យរៀបចំឡានហ្នឹងទៅ បាទ។

[១០:៤២:៥៨]

**ស៖** ហើយនៅពេលដែលគាត់ប្រាប់លោកអ៊ីចឹង តើលោកមានបញ្ជូនព័ត៌មាននេះទៅសមមិត្តតេង ហើយឬក៏ប្រាប់ទៅអ្នកណាដែលប្រចាំការអចិន្ត្រៃយ៍នៅជើងឯកនោះដែរទេ?

**ឆ៖** បាទ ខ្ញុំអត់បានដឹងដែរ ព្រោះមាន តាហ៊ី អីគាត់ឧស្សាហ៍ជិះម៉ូតូ ជិះអី គាត់ទៅ។ ហើយជួនកាលគាត់ឲ្យនីរសារគាត់ទៅប្រាប់។

**ស៖** ខ្ញុំសូមសួរលោកនូវសម្តីរបស់សាក្សី តយ តេង ឆ្លើយជូននៅថ្ងៃទី២១ មេសា គឺក្រោយម៉ោង០៣:១៨នាទី គាត់និយាយអំពីភារកិច្ចរបស់គាត់ក្នុងការជីករណ្តៅនៅឯជើងឯក។ សូមដកស្រង់៖ “មុនគេដឹកអ្នកទោស<មក> ហ៊ុយ បានប្រាប់យើងពីរថ្ងៃមុន ឲ្យរៀបចំជីករណ្តៅទាំងនោះ ដែលថានៅថ្ងៃជាក់លាក់នេះ គេនឹងដឹកអ្នកទោសមកហើយ។ ហើយដោយសារតែមូលហេតុនេះ ក្រុមរបស់យើងខ្ញុំត្រូវតែជីករណ្តៅឲ្យរួចរាល់ឲ្យហើយ។” បញ្ចប់ការដកស្រង់។ តើនេះជួយរំឭកដល់ការចងចាំរបស់លោកទេ ថាលោកនេះបានទាក់ទងជាមួយសមមិត្ត តេង នេះជាមុន ឲ្យជីករណ្តៅរួចឲ្យហើយ មុននឹងដឹកអ្នកទោសយកទៅដល់កន្លែងនោះ លោកចាំទេ?

**ឆ៖** បាទ ពេលមួយគឺ តាហ៊ី ឲ្យខ្ញុំទៅ។ ជិះម៉ូតូទៅ ទៅប្រាប់ពួក បងតេង ហ្នឹង ឲ្យជីករណ្តៅទៅ ថ្ងៃនេះថ្ងៃនោះ គេនឹងយកអ្នកទោសមកហើយ។ ថាប៉ុន្មានរណ្តៅ គេប្រាប់ថា ឲ្យជីកពីររណ្តៅ ខ្ញុំក៏ទៅប្រាប់ឲ្យជីកពីររណ្តៅទៅ។ ហើយកុំឲ្យអ្នកណាទៅណាទីណី តែម៉ោងប្រាំបី ម៉ោងអីហ្នឹង គេនឹងដឹកយកមកហើយ។

[១០:៤៥:១១]

**ស៖** នៅពេលលោកនិយាយថា ត្រូវជីករណ្តៅពីរឲ្យរួចរាល់ជាមុន។ តើអ្នកទោសប៉ុន្មាននាក់ដែលអាចនឹងយកទៅសម្លាប់ ហើយដាក់ចោលនៅក្នុងរណ្តៅទាំងពីរហ្នឹង?

**ឆ៖** បាទ តែបើគេឲ្យជីករណ្តៅពីរ អាហ្នឹងអ្នកទោសប្រហែលចូលរយនាក់ហើយបាទ។

**ស៖** អ៊ីចឹងមានន័យថា <>រណ្តៅនីមួយៗដាក់ចំនួនអ្នកដែលគេសម្លាប់ខុសៗគ្នា ឬក៏ថាមួយរណ្តៅកំណត់ថា១០០នាក់?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ ខុសគ្នា។ មួយរណ្ដៅ៥០នាក់អ៊ីចឹងទៅ បើយក១០០នាក់ ជួនកាលគេឲ្យជីកតែមួយរណ្ដៅហ្នឹងគឺ ហាហុកសិបនាក់, ៧០នាក់អ៊ីចឹងទៅបាទ។

**ស៖** លោកបានលើកឡើងថា ខ្លួនលោក <ជូនដំណឹងទៅ>សមមិត្ត តេង <អំ>ពី<ការ>ជីករណ្ដៅ<នៅពេលនោះ។> តើ<លោកដឹងទេ ថាគេបាន>ប្រាប់<គាត់>ជាមុន<នៅពេលផ្សេងទៀត ហើយបើសិនជាលោកដឹង តើដឹងយ៉ាងម៉េច> ឬក៏<លោកមិនដឹង>ទេ?

**ឆ៖** បាទ ដែលពេលដូចថា តាហ៊ី ឲ្យខ្ញុំទៅប្រាប់អ៊ីចឹង គឺខ្ញុំបានប្រាប់នុ៎ងទៅ ហើយដល់អ៊ីចឹងខាងក្រុមនោះគេជីកទៅ ដឹងថាគេជីកហើយ ប៉ុន្មានថ្ងៃៗគេជីកហើយបាទ។

**ស៖** តើលោកអាចប៉ាន់ប្រមាណចំនួនអ្នកទោសដែលលោកដឹកជញ្ជូនទៅជើងឯកបានទេ មួយលើកៗហ្នឹង?

**ឆ៖** បាទ គិតពី៥០នាក់ឡើងទៅ ចូល១០០នាក់បាទ។

**ស៖** ខ្ញុំខ្លាចតែខ្ញុំយល់មិនច្បាស់ អ៊ីចឹងសួរបញ្ជាក់ថា ក្នុងមួយជើងៗគេដឹកអ្នកទោសពី៥០ ទៅ១០០នាក់ ឬក៏ថាមានជើងខ្លះហ្នឹងដឹករហូតទៅដល់ច្រើនរយនាក់ដែរ?

[១០:៤៧:៥២]

**ឆ៖** បាទ អត់មានទេ។ មួយជើង គឺឡានមួយដាក់បាន៣០នាក់ជាង ៤០នាក់ហ្នឹងអស់ហើយឡានមួយ ហើយនិងដឹកម្ដង គឺក្នុងមួយពេលហ្នឹង គឺដឹកពីរជើងបាទ ឡានពីរអ៊ីចឹងទៅ។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានទេ ថាមានក្រុមណាមួយនោះ ម្ដងណានោះដឹកទៅហ្នឹងវាច្រើនជាងក្រុមដទៃទៀតមែនទែននោះដែរទេ? ឬក៏អាចសួរម្យ៉ាងទៀតថា តើមានជើងណាមួយដឹកទៅច្រើនរយនាក់ដែរទេ?

**ឆ៖** បាទ ខ្ញុំអត់បានដឹងដែរ ព្រោះមិនមែនទៅតែខ្ញុំណា ផល ក៏ទៅ, ប៉េង ក៏ទៅ, តាហ៊ី ក៏ទៅអ៊ីចឹងខ្ញុំអត់ដឹងថា ជើងណាជើងណីទេ។

**ស៖** គិតត្រួសៗទៅ លោកដឹកអ្នកទោសទៅជើងឯកហ្នឹងញឹកញាប់ប៉ុនណាដែរ? ដឹកទៅប្រចាំថ្ងៃ ប្រចាំសប្ដាហ៍ ប្រចាំខែ ឬក៏យ៉ាងម៉េចដែរ ញឹកញាប់ប៉ុនណាដែរ?

**ឆ៖** ខ្ញុំអត់ប៉ាន់ស្មានបានទេ ព្រោះគេ ជួនកាលគេឲ្យខ្ញុំទៅៗ ជួនកាលគេឲ្យ ផល នោះទៅៗ ជួនកាលគេឲ្យ ប៉េង នោះទៅៗ ព្រោះអត់បានចាំទេបាទ។

**ស៖** ដូច្នេះបើខ្ញុំយល់មិនច្រឡំទេ លោកឆ្លើយថា ពេលខ្លះលោកបានទៅទីនោះ ជួនកាល ប៉េង

ទៅទីនោះ ជួនកាល ផល ទៅទីនោះ។ ត្រឹមត្រូវដែរទេ?

**ឆ៖** បាទ ខ្ញុំជម្រាបអំមិញហ្នឹងគឺ ប៉េង, ផល ហ្នឹងហើយអ្នកទៅ ចែកគ្នាទៅ។ មិនមែនចែកគ្នាទៅ គេចាត់តាំង តាហ៊ិ ហ្នឹងចាត់ឲ្យអ្នកណាទៅ គឺអ្នកហ្នឹងទៅ។

[១០:៥០:២៤]

**ស៖** ប្រហែលជាលោកមិនដឹងចំណុចនេះ ប៉ុន្តែបើសិនជាលោកដឹង តើគេចែកពេលវេលាទៅជើងឯកហ្នឹងស្មើៗគ្នាទេ? ឧទាហរណ៍ថា លោកត្រូវទៅមួយភាគបី ហើយ តេង ទៅមួយភាគបីនៃពេលវេលា ហើយ ផល ទៅមួយភាគបីនៃពេលវេលា។ មានការចែកពេលវេលាគ្នាយ៉ាងដូច្នេះទេ? <ឬក៏មានអ្នកណាម្នាក់ក្នុងចំណោមអ្នកទាំងបីហ្នឹងទៅញឹកញាប់ជាងគេ?>

**ឆ៖** បាទ ពួកខ្ញុំអត់មានចែកគ្នាទេ នៅលើតែ តាហ៊ិ ទេអ្នកឲ្យ អ្នកណាទៅគឺអ្នកហ្នឹងទៅ។ អត់ដឹងថាអ្នកណាទៅប៉ុន្មានជើង អ្នកណាទៅប៉ុន្មានជើងទេ ខ្ញុំអត់ៗចាំទេ។ ហើយក៏អត់មានសម្គាល់ថាអ្នកណាទៅណាដែរ ប៉ុន្តែពួកអស់ហ្នឹងគេ តែឲ្យ ប៉េង ទៅគឺ ប៉េង ទៅ, ឲ្យ ផល ទៅគឺ ផល ទៅ, ឲ្យខ្ញុំទៅគឺខ្ញុំទៅ ព្រោះខ្ញុំច្រើននៅចាំទទួលអ្នកទោសនៅកន្លែងនេះ។

**ស៖** នៅពេលលោកដឹកអ្នកទោសទៅជើងឯក តាមធម្មតាលោកដឹកទៅនៅម៉ោងប៉ុន្មាន?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា ពេលដឹកទៅគឺពេលស្ងាត់ម៉ោងប្រាំបីម៉ោងអី ឬមួយប្រាំបីជាង ធ្វើម៉េចឲ្យស្ងាត់ បានគេដឹកយកចេញទៅបាទ។

**ស៖** តើអ្នកទោសដែលគេដឹកជើងឯកហ្នឹង គេមានចងដៃ គេមានរុំមុខអីទេ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា គេមុននឹងយកទៅ គេដាក់ខ្នោះដៃមកក្រោយ ហើយគេចងមុខ។ ហើយខ្ញុំដាក់ក្នុងឡាននេះ ជួនកាលមនុស្សច្រើនអ៊ីចឹង គេដាក់កងជើងនៅក្នុងហ្នឹងទៀត ទាំងដៃទាំងអីហ្នឹង ដាក់ស៊កអ្នកទោសក្នុងហ្នឹង គេខ្លាចអ្នកទោសរត់រួច។

**ស៖** តើមានអ្នកណាម្នាក់ប្រាប់អ្នកទោសថា គេត្រូវដឹកអ្នកទោសហ្នឹងទៅទីណាដែរទេ?

[១០:៥២:៤៦]

**ឆ៖** បាទ បទបញ្ជារបស់គេ គេប្រាប់ថាកុំថាឲ្យអ្នកទោស -- កុំថាយកអ្នកទោសទៅសម្លាប់ថា យកដូរនៅផ្ទះថ្មី ធ្វើម៉េចកុំឲ្យអ្នកទោសចាប់អារម្មណ៍ថា គេយកខ្លួនទៅសម្លាប់ចោល។

**ស៖** តើលោកនាំអ្នកយាមទៅជើងឯកប៉ុន្មាននាក់ដែរ នៅពេលលោកដឹកអ្នកទោសទៅជើងឯកហ្នឹង?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ អ្នកការពារពីក្រោយ គឺឡានមួយពីរនាក់ពីក្រោយ ហើយអ្នកបើកពីរនាក់ខាងមុខ។

**ស៖** ឥឡូវខ្ញុំសូមសួរលោកថាអំពីបញ្ជីអ្នកទោស តើលោកមានបានទទួលបញ្ជីអ្នកទោសពីអ្នកណាម្នាក់ដែរទេ នៅពេលដែលលោកដឹកអ្នកទោសទៅជើងឯកនោះ?

**ឆ៖** បាទខ្ញុំអត់បានទទួលបញ្ជីពីអ្នកណាទេ ប៉ុន្តែថាគេឲ្យខ្ញុំដាក់ប៊ិកមួយ សៀវភៅមួយកត់ចំនួនដែលអ្នកទោសយកចេញពីស-២១ ទួលស្លែងនេះទៅ ឲ្យខ្ញុំកត់ឲ្យគ្រប់ចំនួនដែលយកចេញទៅប៉ុន្មានយកមកវិញ គឺឲ្យទៅ បងធី ទូទាត់ តើចំនួនគ្រប់ដូចគ្នាអត់។

**ស៖** ដូច្នេះ នៅពេលណាមួយនៃដំណើរការដឹកទៅហ្នឹង ដែលលោកត្រូវរាប់អ្នកទោសហ្នឹង តើលោករាប់មុនពេលដឹកអ្នកទោសចេញពីទួលស្លែង ឬក៏រាប់នៅពេលដែលអ្នកទោសទៅដល់ជើងឯកហើយ ឬក៏លោករាប់ទាំងពីរកន្លែង រាប់ទាំងមុនពេលដឹកចេញទៅពីទួលស្លែង រាប់ទាំងពេលទៅដល់ជើងឯក? <តើលោករាប់នៅពេលណា?>

**ឆ៖** បាទ ពេលអ្នកទោសដែលយកចេញពីទួលស្លែងនេះទៅ គឺបង សួស ធី ដឹងមានចំនួនប៉ុន្មានៗ គេដឹងរបស់គេហើយ។ អ៊ីចឹងចេះបណ្ដើរអ្នកទោសហ្នឹង ឡើងឡានៗទៅ ហើយដាក់មួយឡានប៉ុន្មាន ឲ្យរាប់មើលក្នុងមួយឡានប៉ុន្មាន មួយឡានប៉ុន្មានឲ្យដឹង ហើយដឹកយកទៅ។ ទៅដល់នោះ ពេលយកទៅចូលក្នុងផ្ទះនោះ ដាក់ចេញពីឡានយកចូលក្នុងផ្ទះដែលនៅជើងឯកហ្នឹង ដូចថាចំនួនប៉ុន្មាន ៥០ ឬចិតប៉ែតសិបនាក់អ៊ីចឹង រាប់ឲ្យដឹងចំនួន ហើយក៏បណ្ដើរមួយៗម្នាក់ទៅឲ្យពួក បងតេង ធ្វើការសម្លាប់ ហើយខ្ញុំកត់ឈ្មោះ។ ពេលដែលសព្វគ្រប់អស់ហើយ គឺយកបញ្ជីហ្នឹងមកទូទាត់ ឲ្យ បងធី ទូទាត់ បាត់ឬមួយក៏គ្រប់ចំនួនដែលបញ្ជូនយកទៅហ្នឹង។

[១០:៥៦:១០]

**ស៖** ហើយនៅពេលដែលលោករាយការណ៍អំពីការបញ្ចប់កិច្ចការនេះ<ទៅ សួស> ធី <តើលោកដឹងទេថា គាត់អាចបង្កើតឯកសារបន្ថែមទៀតផ្អែកទៅលើ>របាយការណ៍<របស់លោក>នោះដែរទេ?

**ឆ៖** បាទ ខ្ញុំហុចឲ្យគាត់ទៅ គាត់យកទៅត្រួតពិនិត្យជាមួយឈ្មោះនៅណោះ ប៉ុន្មានអីប៉ុន្មានហើយយកមកហ្នឹង ដែលយកទៅសម្លាប់ហ្នឹង វាត្រូវគ្នាអត់ មានចំនួនប៉ុន្មានអីប៉ុន្មាន ហ្នឹងគេរាប់តាមហ្នឹង ទៅដឹងហើយអាហ្នឹង។

**ស៖** នៅពេលដែលគាត់ធ្វើការទូទាត់ចំនួនចេញពីសៀវភៅរបស់លោក ធៀបទៅនឹងចំនួនផ្សេង

ទៀតនោះ តើលោកមានវត្តមាននៅជាមួយគាត់ហ្នឹងទេ?

**ផ៖** បាទ ខ្ញុំគឺអត់មាននៅទេ ហុចឲ្យគាត់ហើយ ខ្ញុំមកវិញមក។

**ស៖** ឥឡូវត្រឡប់ទៅនិយាយអំពីការដឹកជញ្ជូនទៅជើងឯក។ នៅពេលលោកទៅដល់ជើងឯក តើគេដាក់អ្នកទោសចុះពីឡាន ដោយរបៀបណា ហើយគេយកទៅដាក់នៅកន្លែងណា?

**ផ៖** បាទ ដូចខ្ញុំជម្រាបអំមិញអ៊ីចឹង ឡានទៅដល់អែបក្បែរផ្ទះហ្នឹងទៅ គេបើកទ្វារបន្ទប់ហ្នឹង បន្ទប់ធំនៅខាងក្រោមផ្ទះហ្នឹង។ ផ្ទះហ្នឹងវ៉ែជញ្ជាំងក្តារ គេធ្វើបន្ទប់ធំអ៊ីចឹង។ ដល់ពេលនេះ គេយកកៅអីមួយដាក់ ហើយលើឡានហ្នឹងគឺពីរនាក់ សម្រាប់យកអ្នកទោសដាក់ឲ្យចុះ នៅនឹងដីពីរនាក់ ចាំទទួលអ្នកទោសឲ្យចុះជាន់កៅអីហ្នឹង ចុះមកនឹងដីមក បានគេបណ្តើរយកចូលទៅក្នុងបន្ទប់ហ្នឹង។

[១០:៥៨:៣១]

**ស៖** ហើយនៅពេលហ្នឹងអ្នកទោស នៅតែគេដាក់ខ្នោះ ហើយនិងចងរុំមុខដដែលឬ នៅពេលគេនាំចូលទៅផ្ទះហ្នឹង?

**ផ៖** បាទ អ្នកទោស គឺជាប់ខ្នោះនៅនឹងដៃ ឬមួយក៏ចងខ្សែជាប់ស្លាបសេកហ្នឹង ហើយមុខគេចងឲ្យជិត តាំងពីភ្នំពេញនេះទៅ ពីទួលស្លែងទៅ អត់ឲ្យអ្នកទោសស្គាល់ផ្លូវ ស្គាល់អីទេ។

**ស៖** តើលោកនៅនឹកឃើញពីម៉ាស៊ីនភ្លើងមួយដែលគេប្រើនៅផ្ទះនោះដែរទេ?

**ផ៖** បាទ ខ្ញុំនឹកឃើញថា ម៉ាស៊ីនភ្លើងមួយនោះ គឺម៉ាស៊ីនម៉ាស្ទូតមួយ គេទុកសម្រាប់ដែល យកអ្នកទោសទៅហ្នឹង គេបញ្ឆេះម៉ាស៊ីនភ្លើងហ្នឹង។

**ស៖** តើម៉ាស៊ីនភ្លើងហ្នឹងនៅពេលគេបញ្ឆេះវាទៅ វាឮខ្លាំងទេលោក? <នៅពេលបញ្ឆេះម៉ាស៊ីនហ្នឹង តើគេអាចឮសំឡេងអ្វីកើតឡើងនៅខាងក្រៅផ្ទះដែរទេ?>

**ផ៖** បាទ ម៉ាស៊ីននោះគឺបញ្ឆេះទៅឮខ្លាំង។ គេដាក់ជិតអាអុងម៉ុងនោះ ហើយផ្ទះនោះក៏នៅជិតអុងម៉ុងនោះដែរ។ បញ្ឆេះម៉ាស៊ីនហ្នឹង គឺអ្នកទោសយកចេញទៅ អត់មានឮសូរថា យកសម្លាប់ឯណាសម្លាប់ឯណា អត់ដឹង ព្រោះឮសូរម៉ាស៊ីនភ្លើងខ្លាំងបាទ។

**ស៖** <នោះជាអ្វីដែលខ្ញុំចង់និយាយជាមួយលោកនៅពេល>បន្ទាប់<>ទៀត។ <តើ>គេនាំអ្នកទោសចេញពីផ្ទះហ្នឹងយកទៅសំដៅរណ្តៅដើម្បីសម្លាប់ហ្នឹង តើដំណើរការហ្នឹងគេធ្វើដោយរបៀបណាដែរ? <តើលោកដឹងទេ?>

[១១:០០:៤៣]

**ឆ៖** បាទ ពេលដែលគេបញ្ចេញពីក្នុងផ្ទះហ្នឹងទៅ គឺបណ្ដើរម្នាក់មួយៗ ទៅដល់មានភ្លើងមួយគឺខ្ញុំមានកៅអីមួយ ខ្ញុំអង្គុយកត់ឈ្មោះ ដាក់ក្រដាសនៅលើកៅអីហ្នឹងទៅ ហើយខ្ញុំអង្គុយកត់លើ អង្គុយកត់លើក្រដាសហ្នឹង។ ហើយគេកត់ឈ្មោះហើយ គេបញ្ជូនអ្នកទោសយកទៅសម្លាប់។ ទៅដល់អាកន្លែងរណ្ដៅហ្នឹង គេឱ្យអង្គុយហើយ គេវ៉ៃពីក្រោយទៅ វ៉ៃកញ្ចឹងក។

**ស៖** លោកបានឆ្លើយថា នៅដំណាក់កាលនេះគឺលោកកត់ឈ្មោះអ្នកទោស។ លោកគ្រាន់តែរាប់ចំនួនអ្នកទោសទេ ឬក៏លោកសរសេរឈ្មោះអ្នកទោសពេញតែម្ដង?

**ឆ៖** បាទ សរសេរលេខ១ លេខ២ លេខ៣អីចឹងទៅ ប៉ុន្តែឈ្មោះគឺយកទៅមួយ សួរឈ្មោះហើយកត់ ឈ្មោះហ្នឹងហើយដាក់លេខ១ ឈ្មោះមួយទៀតឈ្មោះអី សរសេរឈ្មោះហ្នឹង ដាក់លេខ២អីចឹង គឺទាំងមានឈ្មោះ ទាំងមានចំនួនលេខក្នុងហ្នឹង។

**ស៖** តើអ្នកណា<ជាអ្នក>យកអ្នកទោស<>ដើរ<កាត់តាម>កៅអី<ដែលលោកអង្គុយ> ហើយ<បណ្ដើរយក>ទៅ<>កន្លែងសម្លាប់<>?

**ឆ៖** បាទ ខ្ញុំជម្រាបថា ទាំងអស់គ្នា។ គឺយកចុះពីលើឡាន ក៏នាំគ្នាជួយយកចុះពីលើឡានមកហើយយកចូលទៅក្នុងបន្ទប់ហ្នឹងទៅ។ ពេលដល់ហើយ បានយកចេញម្ដងមួយៗទៅ។ ព្រោះពេលហ្នឹងគឺ តាហ៊ី ក៏គាត់ទៅហ្នឹង រៀបចំការសម្លាប់ រៀបចំឱ្យបណ្ដើរអ្នកទោសម្ដងមួយៗ ក៏គាត់រៀបចំរបស់គាត់។

[១១:០២:៥៩]

**ស៖** នៅពេលគេយកបណ្ដើរអ្នកទោសទៅសំដៅរណ្ដៅនោះ តើមានអ្នកទោសណាដឹង ឬមានសញ្ញាណណាមួយ ឬក៏លោកកត់សម្គាល់ឃើញថាមានសញ្ញាណណាមួយចេញពីអ្នកទោស ដឹងថាគេយកគាត់ទៅសម្លាប់ទេ? <តើពួកគេមាននិយាយ ឬក៏ធ្វើអ្វីមួយដែលបញ្ជាក់ថា ពួកគេដឹងថា ពួកគេនឹងត្រូវគេសម្លាប់ទេ?>

**ឆ៖** ខ្ញុំអត់ដឹងដែរ ប៉ុន្តែឱ្យប្រាប់ថាយកទៅផ្ទះថ្មី កត់ឈ្មោះហើយទៅផ្ទះថ្មីបាទ។ គឺគេឱ្យដាក់បទបញ្ជាអីចឹង។

**ស៖** ឥឡូវនេះខ្ញុំសូមសួរលោកពីចំណុចមួយដែល តយ តេង គាត់ឆ្លើយ<ពីចំណុចនេះ>គឺនៅថ្ងៃទី២១ ខែមេសា នៅមុនម៉ោង០៣:៣៦រសៀល គាត់និយាយអំពីការបណ្ដើរអ្នកទោសចេញពីផ្ទះហ្នឹងសំដៅទៅរណ្ដៅ<សម្លាប់>។ គាត់បានឆ្លើយថា អ្នកទោសខ្លួនឯងហ្នឹងបានដឹងថា នេះគឺជាចុងបញ្ចប់នៃ

ជីវិតរបស់ខ្លួនហើយ។ សូមដកស្រង់៖ "ពួកគេបានស្រែកទ្រហោយំនៅពេលដែលបញ្ជូនចេញ ហើយគេ <លើកដៃសំពះ>អង្វរក <សូមទុកជីវិតឲ្យពួកគេ ប្រហែល>គេដឹង<>ហើយ។" បញ្ចប់ការដកស្រង់។ ខ្លួនលោកផ្ទាល់នេះ ខ្ញុំសួរថាតើលោកដែលធ្លាប់ជួបប្រទះ ឃើញ ឮអ្នកទោសហ្នឹងស្រែកទ្រហោយំអង្វរសូមឲ្យទុកជីវិតនោះទេ?

**ឆ៖** បាទ ខ្ញុំអត់ឮដែរ ប៉ុន្តែឮសួរស្រែក ឮសួរអីឮ។ ប៉ុន្តែកត់ឈ្មោះ រវល់តែគិតតែកត់ឈ្មោះ មិនមែនគិតតែរឿងទៅនោះឯណា។ ប៉ុន្តែឮ ៗគេស្រែកគេអីឮ។

**ស៖** នៅពេលដែលលោកឮគេស្រែក<យំ>ហ្នឹង <តើលោកឮគេនិយាយអីទេ? តើជាការយំរៀបរាប់> ឬក៏<គ្រាន់តែ>ស្រែក<យំតែប៉ុណ្ណោះ>?

[១១:០៤:៥៣]

**ឆ៖** បាទ អាក្រក់ស្តាប់។ ខ្លះកាន់ទៅបណ្តើរទៅយំ កត់ឈ្មោះហើយបែបដឹងថាខ្លួនស្លាប់ យំ។ ហើយពួកខ្ញុំចេះកត់ហើយ ចេះប្រាប់ថា គេអត់យកទៅណា គេឲ្យទៅផ្ទះថ្មីៗ។ គេឲ្យភូតអីចឹងទៅ ដើម្បីកុំឲ្យអ្នកទោសដឹងថាខ្លួន គេយកទៅសម្លាប់។

**ស៖** ឥឡូវនេះខ្ញុំសុំចូលពីល្បិចកលនៃការសម្លាប់វិញម្តង។ តើគេ<>សម្លាប់មនុស្សនៅជើងឯកនោះ<របៀបម៉េចដែរ>?

**ឆ៖** បាទ គេយកទៅកត់ឈ្មោះហើយអីចឹងទៅ គេយកទៅដល់ បណ្តើរទៅដល់មាត់រណ្តៅហ្នឹង ហើយគេឲ្យអង្គុយចោងហោងទៅ ហើយគេយកដែក ដែកខ្នោះហ្នឹងវៃកញ្ចឹងកពីក្រោយ។ វៃកញ្ចឹងកពីក្រោយហើយ ក៏គេអារក អារអី។ ហើយអាអាវណាល្អៗ គេឲ្យសម្រាតយកមកវិញ។ ហើយអាណាអាវចាស់ៗ គេអត់ឲ្យដោះទេ។ តាហ៊ី អ្នកដាក់បទបញ្ជាថា ឲ្យយកអាណាល្អៗមកទុក គក់អីឲ្យអ្នកទោសដទៃទៀតពាក់។ ហើយក៏គេវះពោះវះអី ដោះខ្នោះដោះអី វះពោះវះអី បោះចូលទៅក្នុងរណ្តៅហ្នឹង។

**ស៖** តើលោកដឹងដែរថា គេប្រើ<អ្វី>ក្នុងការកាត់ផ្តាច់បំពង់ក <និងវះពោះ>អ្នកទោសនោះ? គេប្រើកាំបិតអ្វីដើម្បីកាត់ផ្តាច់បំពង់កអ្នកទោសនោះ?

**ឆ៖** បាទ នៅកន្លែងនោះគឺមានកាំបិតចិតត្នោត។ កាំបិតចិតត្នោតហ្នឹង គេវៃដួលព្រួសហើយ គេអារកបណ្តោយទៅ។

[១១:០៧:៣០]

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** ចំពោះវិធីសម្លាប់មនុស្សនេះ តើគេមានបានបង្រៀន<ទេ? តើមាននរណាម្នាក់ប្រាប់លោក ឬក៏ប្រាប់អ្នកយាមថា “នេះជាបច្ចេកទេសសម្លាប់មនុស្សដ៏ត្រឹមត្រូវ។ ដំបូង>វាយពីខាងក្រោយលលាដ៍ក្បាល វាយកញ្ចឹងក <ដោយប្រើដែកវែង ហើយបន្ទាប់មក>អារកអីជាដើម តើ<>គេ<ធ្លាប់>បង្រៀន<លោក>ទេ?

**ឆៈ** បាទ គឺគេបង្រៀនគឺ តាឌុច, តាហ៊ី អ្នកបង្រៀនការសម្លាប់មនុស្សហ្នឹង ព្រោះគាត់ធ្លាប់ដកពិសោធន៍ ដូច តាឌុច គាត់ធ្លាប់ដកពិសោធន៍រឿងអស់ហ្នឹង។ អ៊ីចឹងគាត់បង្រៀនថា គេឲ្យវ៉ៃចំកន្លែងនេះ វ៉ៃខុសពីហ្នឹងអត់ងាប់ទេ។ អ៊ីចឹងវ៉ៃហើយសន្លប់ សន្លប់ហើយអារក អាករហើយដោះអាវចេញ បើថាល្អដោះយកទុកវិញ ហើយរះពោះ វះអី បោះចូលទៅក្នុងរណ្ដៅហ្នឹង។

**សៈ** តើការណែនាំបែបនេះ គេណែនាំផ្ទាល់នៅឯជើងឯកហ្នឹងតែម្ដង ឬក៏គេបង្ហាត់បង្ហាញបង្រៀននៅកន្លែងណាមួយផ្សេង?

**ឆៈ** បាទ តាំងពីនៅទួលស្លែងរហូតទៅជើងឯកនោះ។ ជើងឯកក៏គេប្រាប់អ៊ីចឹង ទួលស្លែងក៏គេប្រាប់អ៊ីចឹងដែរ។

**សៈ** លោកបានឆ្លើយថា ហ៊ី ក៏មានវត្តមាននៅឯជើងឯកដែរ។ <តើគាត់>មានវត្តមាន<រាល់ពេលលោកនៅទីនោះ> ឬក៏គាត់មានវត្តមាន<ម្ដងម្កាលទេ>?

**ឆៈ** បាទ តាហ៊ី ជិះឡានទៅជាមួយពួកខ្ញុំ។ ដូច តាឌុច អាហ្នឹងឡានរបស់គាត់ផ្សេង ឡានហ្ស៊ីបរបស់គាត់ផ្សេង។ តាហ៊ី គាត់ដឹកអ្នកទោសទៅជាមួយពួកខ្ញុំហ្នឹង។

**សៈ** ខ្ញុំសុំសួរបញ្ជាក់ឲ្យច្បាស់។ រាល់ពេលដែលលោកទៅជើងឯក ហ៊ី ទៅជាមួយគ្នារាល់ជើងអ៊ីចឹងដែរ ឬក៏ ហ៊ី ទៅដោយពេលទេ?

**ឆៈ** បាទ គាត់ទៅរាល់ពេលតែម្ដង បាទ។

**សៈ** ចុះ ឌុច វិញ ឌុច ទៅជើងឯកញឹកញាប់ប៉ុនណាដែរ?

[១១:១០:១០]

**ឆៈ** តាឌុច អត់ហ៊ាន អត់សូវទៅទេ តាឌុច តែ តាហ៊ី ទេ ព្រោះតែយកទៅគឺ តាហ៊ី ទៅ យកទៅ តាហ៊ី ហើយ។

**សៈ** តើលោកចាំទេថា ឌុច នេះទៅជើងឯកបានប៉ុន្មានដងដែរ?

**ឆៈ** ប្រហែលបីដង។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**ស៖** ខ្ញុំចង់សួរលោក <អ្នកណាពិតប្រាកដជាអ្នក>សម្លាប់<មនុស្ស>នេះ តើលោក <និង> អ្នកដែលមកជាមួយលោក ឬក៏សមមិត្ត តេង <និងអ្នក>ដែល<ស្នាក់>នៅទីនោះ<ជាមួយគាត់> ឬក៏ <អ្នកដែល>មានវត្តមានទាំងអស់គ្នានៅទីនោះ<>នោះ?

**ឆ៖** បាទ កម្លាំងនោះដែលចេញពីនេះទៅគឺ តាហ៊ី ចាត់ចែង ចែកឲ្យពួកខ្ញុំទៅពីនេះទៅប៉ុន្មាននាក់ គឺយាមជុំវិញកន្លែងដែលគេសម្លាប់ហ្នឹង តាមរបងហ្នឹង ហើយនិងបណ្ដើរអ្នកទោសយកទៅឲ្យពួកបងតេង ហ្នឹងអ្នកសម្លាប់។ ហើយចាត់ចែងរបៀបយ៉ាងម៉េចទៀត ខ្ញុំអត់បានដឹងទេ ព្រោះខ្ញុំកាន់តែបញ្ជីចាំកត់ឈ្មោះគេដែលគេបញ្ជូនយកទៅ។

**ស៖** តើលោកធ្លាប់ -- ខ្ញុំមិនសួរជាលក្ខណៈប្រចាំទេ តើមានពេលណាមួយហ្នឹងលោកសម្លាប់អ្នកទោសម្នាក់ ឬក៏ពីរនាក់អីទេនៅជើងឯកនោះ?

**ឆ៖** បាទ ពេលនោះគឺ--

**លោក ម៉ម រិទ្ធា៖**

សូមទោសលោកប្រធាន សូមការអនុញ្ញាតពីលោកប្រធាន ដើម្បីប្រឹក្សាសំណួរនេះជាមួយសាក្សី។

*(សាក្សីប្រឹក្សាជាមួយនឹងមេធាវីប្រឹក្សា)*

**លោក ហ៊ឹម ហ៊ុយ៖**

**ឆ៖** បាទ គឺៗខ្ញុំថាមិនឆ្លើយ។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** មិនជាបញ្ហាអីទេលោកសាក្សី។

[១១:១៣:០២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

អរគុណលោកប្រធាន។ ខ្ញុំជឿជាក់ថា ចំពោះចំណុចនេះគឺសាក្សី គឺមិនមានសិទ្ធិបដិសេធឆ្លើយទៅនឹងសំណួរនេះទេ ដោយសារមានហេតុផលពីរដូចដែលខ្ញុំបញ្ជាក់៖ ទី១) ហេតុផលទី១ គឺថាពាក់ព័ន្ធទៅនឹងខ្លឹមសារនៃចម្លើយរបស់គាត់មកទល់នឹងពេលនេះនោះ គឺមានលក្ខណៈខុសប្លែកគ្នា ពាក់ព័ន្ធទៅ

នឹងទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ពាក់ព័ន្ធទៅនឹងការសម្លាប់ និងការរៀបចំ។ បើយើងគិតពីច្បាប់ព្រហ្មទណ្ឌនោះ គឺមានន័យថា គឺគាត់<ក៏>មាន<ពិរុទ្ធភាពដែរទោះជាគាត់មិនបាន>សម្លាប់<ដោយផ្ទាល់ក៏ដោយ>នៅពេលនោះ។ ហើយចំណុចទី២ គឺពាក់ព័ន្ធទៅនឹងលោកសាក្សី<>នេះ គឺគាត់ត្រូវបានគេកាត់ទោសបន្ទាប់ពីឆ្នាំ១៩៧៩ <ចំពោះការជាប់>ពាក់ព័ន្ធទៅនឹងការសម្លាប់នៅជើងឯកហ្នឹង<>។ <ករណីនោះ>មិនមានគ្រោះថ្នាក់<ទាក់ទងនឹងការ>កាត់ទោសគាត់មួយសាទៀតទេ។ <ចំពោះគាត់ គឺមិនមានគ្រោះថ្នាក់ក្នុងការកាត់ទោសម្តងទៀតទេ។ បើសិនជាក្នុងករណីនេះ ហើយក្នុងឧទាហរណ៍ជាក់ស្តែងនេះ គឺគាត់មិនមានសិទ្ធិ>បដិសេធក្នុងការមិនឆ្លើយទៅនឹងសំណួរ<នៅលើមូលដ្ឋានថា គាត់អាចឆ្លើយដាក់បន្ទុកលើខ្លួនឯងនោះទេ។ ដូច្នេះនៅទីនេះ យើងមាន>ស្ថានភាព<មួយច្បាស់លាស់ខ្លាំងណាស់>។ អ៊ីចឹងជាទូទៅ គឺយើងមិនជំទាស់<ទេ បើសិនជាសាក្សី>បដិសេធ<មិន>ឆ្លើយ<ដោយខ្លាចថា ឆ្លើយដាក់បន្ទុកលើខ្លួនឯងនោះ។ ប៉ុន្តែចំពោះ ហ៊ឹម ហ៊ុយ គឺអត់មានគ្រោះថ្នាក់អ្វីទាំងអស់ ទាំងអង្គហេតុ ទាំងអង្គច្បាប់> ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១១:១៥:១៨]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ លោកមេធាវី កូប៉េ <តើ>លោកយោងទៅនឹងការកាត់ទោសពីមុនមករបស់សាក្សីរូបនេះ <ឬ?> តើលោកមានឯកសារយោងអី<ផ្តល់ឲ្យយើង>ទេ? <តើលោក>អាចផ្ទៀងផ្ទាត់<បានទេ? តើយើងកំពុងនិយាយពី>រឿងអីដែរ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនមានឯកសារយោងអី<ច្បាស់លាស់ទេនៅពេល>ឥឡូវនេះ <ប៉ុន្តែខ្ញុំនឹងរកបាននៅពេលឆាប់ៗនេះលោកចៅក្រមឡាវ៉ែន៍។> គាត់ផ្ទាល់ហ្នឹង គឺនៅក្នុងពេលណាមួយនោះ គឺនៅក្នុងដើមឆ្នាំ៨0នេះ គឺគាត់បានបញ្ជាក់ថា គាត់ត្រូវបានគេកាត់ទោសរយ:ពេល២៤ខែពីបទល្មើសដែលគាត់បានប្រព្រឹត្តនោះ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើ<លោក>ដឹងទេលោកមេធាវី កូប៉េ ថាតើ<>គាត់ហ្នឹងត្រូវបានគេកាត់ទោសទេ<រឿងអ្វី>?

<តើយើងមានមធ្យោបាយណា ដើម្បីឲ្យប្រាកដថាគាត់ត្រូវបានគេកាត់ទោស ពិតជាពាក់ព័ន្ធនឹងរឿងនោះ?>

**លោក វ៉ិចទ័រ កូប៉េះ**

ខ្ញុំមិនមានសាលក្រមបញ្ជាក់ឲ្យច្បាស់ទៅលើចំណុចនេះ<ទេ បើសិននោះជាអ្វីដែលលោកស្រីចៅក្រមចង់និយាយ។> ប៉ុន្តែលោកសាក្សី<ខ្លួនឯង>ហ្នឹង <បានផ្ដល់ភស្ដុតាង>ថា គាត់ត្រូវបានគេកាត់ទោស ឬក៏ផ្ដន្ទាទោសពាក់ព័ន្ធទៅនឹងបទល្មើសដែលកើតមានឡើងនៅក្នុងជើងឯកនោះ <ហើយនិងការពាក់ព័ន្ធរបស់គាត់ជាទូទៅទៅនឹង ស-២១>។

[១១:១៦:៣៥]

**លោក ត្រាវីស ហ្វារ៖**

សូម<និយាយដោយសង្ខេប>លោកប្រធាន <នេះពិតជាបញ្ហាមួយសម្រាប់អង្គជំនុំជម្រះ។> តាមរយៈការសង្កេតរបស់ខ្ញុំនោះ គឺខ្ញុំយល់ថា <>គោលការណ៍<នៃការកាត់ទោសពីរដង> គឺវាបញ្ជាក់ច្បាស់ហើយ។ <លោកចៅក្រមដឹង>ហើយ វាមិន<ពាក់ព័ន្ធ>ទៅដល់អង្គហេតុ <ឬព្រឹត្តិការណ៍ណាទេ ប៉ុន្តែគឺវា>ពាក់ព័ន្ធទៅនឹងការផ្ដន្ទាទោសទៅលើសកម្មភាព ក៏ដូចជាការទទួលខុសត្រូវ។ <ដូច្នេះ> ហើយ <បើ>មិនដឹង<ថា>ផ្ដន្ទាទោស<លើអ្វីឲ្យជាក់លាក់ទេ វាពិបាកណាស់ក្នុងការនិយាយថា គ្មានគ្រោះថ្នាក់សម្រាប់សាក្សីនោះ>។ <ដូចខ្ញុំនិយាយអីចឹង ខ្ញុំយល់ថា នេះជាបញ្ហាមួយសម្រាប់អង្គជំនុំជម្រះ>។

**លោក វ៉ិចទ័រ កូប៉េះ**

ការពិត ខ្ញុំមានឯកសារយោងហើយ លោកប្រធាន។ គឺ E3/1918 គឺ<អត្ថបទរបស់ទស្សនាវដ្ដី "ស្វែងរកការពិត" របស់>មជ្ឈមណ្ឌលឯកសារកម្ពុជា <> "ហ៊ឹម ហ៊ុយ <អនុប្រធានផ្នែកសន្តិសុខ> ត្រូវបានគេដាក់ទោស<>រយៈពេល២ឆ្នាំ <នៅ>ពន្ធនាគារ<ខេត្តកណ្ដាល>។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើ<វាមានផ្ដល់ព័ត៌មានណាបន្ថែមទៀត>ទេ ថាហេតុអីបានជាគាត់ត្រូវបានគេផ្ដន្ទាទោស? តើមានសាលក្រម<ទេ? វាហាក់ដូចជាខ្វះព័ត៌មានដូចដែលខ្ញុំរំពឹងទុក នោះជាអ្វីដែលលោកមាន។>

**លោក វ៉ិចទ័រ កូប៉េះ**

ខ្ញុំចង់<>ចាប់ផ្ដើមសួរទៅលើសាក្សី ថាតើគាត់ត្រូវបានផ្ដន្ទាទោសទៅលើបទអីខ្លះ? <ខ្ញុំបាន

ត្រៀមសួរសំណួរពិសេសនេះជាមុនហើយ ដើម្បីរាំង>ការ<>បដិសេធមិនឆ្លើយនឹងសំណួរនេះ។ <ដូច្នេះ ជាការពិត ខ្ញុំ>គិត<ថា មធ្យោបាយតែមួយគត់ ដើម្បីរកឲ្យឃើញច្បាស់លាស់>នោះ គឺយើងនឹងសួរគាត់ ថាតើគាត់<ដឹងអ្វីខ្លះពី>ការផ្តន្ទាទោស<គាត់ឲ្យ>ជាប់ពន្ធនាគារ២ឆ្នាំ<>នោះ។

[១១:១៨:២២]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:១៨:៣៦]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ក្លូឌា ហ្វេនស៍៖**

**ស៖** ខ្ញុំមានសំណួរមួយ។ តើលោកមានឯកសារជាលាយលក្ខណ៍អក្សរ ពាក់ព័ន្ធទៅនឹងសាលក្រមដែលមេធាវីបានបញ្ជាក់អម្បាញ់មិញនេះដែរឬទេ? គឺអាចជាឯកសារថតចម្លង ពាក់ព័ន្ធទៅនឹងសាលក្រមនេះ?

**លោក ហ៊ឹម ហ៊ុយ៖**

**ឆ៖** បាទ ខ្ញុំ ពេលឆ្នាំ៨១ហ្នឹង គឺខាងនគរបាលស្រុកចាប់ខ្ញុំទៅ ខ្ញុំជាប់ឃុំឃាំងប្រហែលជា២ខែ ឬមួយ៣ខែ បានបញ្ជូនខ្ញុំឲ្យទៅធ្វើស្រូវនៅព្រំដែនវៀតណាម បាទ។ រហូតបាន១០ខែ បានស្រូវឡើងមក គឺក្រោយមក ក៏ខាងនគរបាលស្រុកឲ្យខ្ញុំទៅផ្ទះទៅ បាទ។

**ស៖** តើលោកមានចាំ<ពី>ការកាត់ទោស<នោះ>ទេ? ថាតើចៅក្រមនោះមានប្រកាសថាលោកហ្នឹងមានទោសដោយសារតែលោកបានសម្លាប់អ្នកទោសនៅមន្ទីរសន្តិសុខស-២១ ហើយចេញសាលក្រមថា លោកត្រូវផ្តន្ទាទោសអីទេ?

**ឆ៖** បាទ ពេលនោះ គឺគេចោទខ្ញុំថា ខ្ញុំប្រធានគុកទួលស្លែង ខ្ញុំថាខ្ញុំមិនមែនប្រធានគុកទួលស្លែង បើខ្ញុំប្រធានគុកទួលស្លែង គឺខ្ញុំអត់ចូលស្រុកទេ សុខចិត្តសម្លាប់ខ្លួនឯង ព្រោះខ្ញុំជាអ្នករងគ្រោះនៅកន្លែងនោះដែរ គេចខ្លួនរហូតបាទ ទៅព្រៃ ក៏គេចខ្លួនមក នាំកម្លាំងរត់មកវិញ អត់នៅជាមួយពួកគេបាទ។

[១១:២០:២៩]

**ស៖** ខ្ញុំយល់ហើយ។ តើមានការកាត់ក្តី សវនាការអីចូលរួមត្រឹមត្រូវដែរទេ? តើលោកយល់ទេថា ពាក្យដូចជាសវនាការ មានការរៀបចំសវនាការ មានចៅក្រមសួរដេញដោលលោកអីដែរឬទេ?

**ឆ៖** បាទ កាលនោះអត់មានអត់អីទេ គឺឲ្យខ្ញុំទៅផ្ទះបណ្តោយ។

**ស៖** បើខ្ញុំយល់មិនខុសនោះទេ។ តើមានន័យថា លោកមិនចាំអំពីថាមានសវនាការ ហើយមិនចាំខ្លឹមសារថា មានសាលដីកាអីត្រឹមត្រូវនោះទេ សាលក្រមអីត្រឹមត្រូវនោះទេ បាទត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំអត់យល់។

**ប្រធានអង្គជំនុំ៖**

សំណួរអីចេះ សួរថាតើលោកដែលជាប់ឃុំ ជាប់គុកកាលពីឆ្នាំ១៩៨១នោះ តើការជាប់គុករបស់លោកនោះមានឆ្លងកាត់តុលាការប្រជាជន តុលាការកម្ពុជាហ្នឹងកាត់ទោសលោកដែរឬទេ? ឬក៏លោកជាប់គុកហ្នឹងគ្រាន់តែនគរបាលហៅលោកទៅ យកទៅដាក់គុកលោក ហើយក្រោយមកក៏បានបញ្ជូនទៅធ្វើស្រែនៅព្រំដែនកម្ពុជាវៀតណាម?

**លោក ហ៊ឹម ហ៊ុយ៖**

**ឆ៖** បាទ ពេលនោះក៏យកខ្ញុំទៅដាក់គុក២ខែអីចឹងទៅ បានបញ្ជូនខ្ញុំឲ្យទៅធ្វើស្រូវ។ ដល់ធ្វើស្រូវបានគេយកខ្ញុំមកសួរចម្លើយ។ បាទសួរចម្លើយហើយ ក៏នៅគុកបានប៉ុន្មានខែទៀត បានគេឲ្យមកធ្វើស្រូវវិញ។ ធ្វើស្រូវហើយ ឡើងមកវិញ បានប៉ុន្មានខែ បានឲ្យខ្ញុំទៅផ្ទះបណ្ដោយ។ ខ្ញុំអត់ដឹងដែរ។

[១១:២២:២៥]

**ប្រធានអង្គជំនុំ៖**

អីចឹងលោកអត់មានដែលបានឆ្លងកាត់តុលាការកាត់ទោសលោកដែរទេ? ស្រុកលោកគឺនៅខេត្តនៅកោះធំ អីចឹងមានតែតុលាការខេត្តកណ្ដាលទេ ដែលមានសមត្ថកិច្ចកាត់ក្ដីលោក ពីព្រោះសម្បត្តិអាជ្ញាធរតុលាការដែនដី សួរថាលោកដែលឆ្លងកាត់តុលាការខេត្តកណ្ដាលកាត់ទោសលោកដែរទេ? ដែលលោកបានទទួលជាប់គុកនៅស្នងការ -- នៅអធិការនគរបាលកោះធំនោះ? លោកយល់ទេ ថាលោកមានឆ្លងកាត់តុលាការកាត់ទោសលោកទេ ដែលអំឡុងពេលដែលលោកជាប់គុកនៅអធិការនគរបាលនោះ?

**លោក ហ៊ឹម ហ៊ុយ៖**

**ឆ៖** ខ្ញុំៗអត់ដឹងដែរ គេឲ្យទៅផ្ទះ ទៅផ្ទះទៅ។

**ប្រធានអង្គជំនុំ៖**

យើងសម្រាប់ជម្រាបជូនភាគីថា តាមដែលបទពិសោធន៍ដែលយើងធ្វើចៅក្រមច្រើនឆ្នាំហើយ។ ហើយយើងបានធ្វើការនៅក្រសួងយុត្តិធម៌តាំងពីឆ្នាំ៨២មក អត្ថិភាពនៃតុលាការកម្ពុជាគឺបង្កើតឡើងបើយល់មិនច្រឡំទេគឺ ក្រោយឆ្នាំ១៩៨២ទេ។ ហើយធ្វើសកម្មភាពដែលអាចប្រព្រឹត្តទៅបានរហូតដល់

១៩៨៤។ នេះតាមការចងចាំ ហើយយើងនិងស្វះស្វែងរកឯកសារនេះ ដើម្បីដាក់ពិនិត្យ ដាក់បញ្ចូលទៅក្នុងរឿង ដើម្បីបញ្ជាក់ជូនជាផ្លូវការ នូវឯកសារនៃក្រឹត្យច្បាប់បង្កើតនៅតុលាការប្រជាជនកម្ពុជាដំបូងនៅក្រោយឆ្នាំ១៩៧៩។

[១១:២៤:៣៣]

បាទ ហើយតាមសំណួរនេះ ហើយផ្អែកលើមូលដ្ឋានមួយចំនួន យើងយល់ថា អង្គជំនុំជម្រះយល់ថាការដែលមិនឆ្លើយតបនឹងសំណួរដែលនាំឲ្យដាក់បន្ទុកលើខ្លួនឯងនេះ គឺជាការត្រឹមត្រូវហើយ។ ដូច្នេះគឺអង្គជំនុំជម្រះមិនមាន មិនត្រូវមានភារកិច្ចបង្ខំឲ្យសាក្សីនេះឆ្លើយផ្ទុយនឹងកាតព្វកិច្ចទូទៅនៃសាក្សីដែលត្រូវផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះទេ។ អំពីសិទ្ធិ នូវសិទ្ធិសាក្សីដែលមិនឆ្លើយតបនឹងសំណួរ ឬក៏សុំឲ្យធ្វើការរៀបរាប់ណាដែលនាំឲ្យដាក់បន្ទុកលើខ្លួនឯងនោះទេ។

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិអញ្ជើញបន្តការតាំងសំណួរ អាចមានពីរសំណួរ ឬបីសំណួរទៀត យើងនឹងសម្រាក។

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** លោកសាក្សី ឥឡូវនេះខ្ញុំចូលទៅសួរលោកអំពីសិទ្ធិអំណាចត្រួតត្រាទៅលើស-២១ អំពី<អ្នកនៅពីលើ> ឌុច និងអំពី<អ្នកនៅពីលើ>ស-២១។ លោកដឹងទេ អ្នកណាជាមេរបស់ ឌុច?

**លោក ហ៊ឹម ហ៊ុយ៖**

**ឆ៖** បាទ ពីមុនមកគឺ សុន សេន មេរបស់ តាឌុច។

**ស៖** តើលោកដឹងទេ សុន សេន ធ្វើជា<មេ>របស់ ឌុច ហ្នឹងអស់រយៈពេលប៉ុន្មានដែរ? <តើលោកអាចប្រាប់បានទេ ធ្វើម៉េចទើបលោកដឹងរឿងនោះ?>

[១១:២៦:១៨]

**ឆ៖** តាំងពីមុនមក ដឹងធ្វើម៉េចតាំងពីអង្គាល់មក។ ប៉ុន្តែដល់គាត់ទៅវ៉ៃជាមួយនៅឯវៀតណាមទៅ ហើយការងារហ្នឹងមិនដឹងទៅលើអ្នកណាអ្នកណីទៀត ក៏ខ្ញុំអត់ដឹងដែរ ព្រោះខ្ញុំមិនយកចិត្តទុកដាក់ពីកន្លែងអស់ហ្នឹងទេ ប៉ុន្តែដឹងច្បាស់ជាងគេគឺ សុន សេន ហ្នឹងឯង។

**ស៖** ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ពីចម្លើយមុនរបស់លោក <តើ>លោក<យល់>ថានៅពេល<>

សុន សេន <>បាន<>ទៅត្រួតពិនិត្យការវាយប្រយុទ្ធជាមួយនឹងវៀតណាម <>គាត់<ឈប់ធ្វើ>ជាមេរបស់ ឌុច <ទៀតហើយ តើអ៊ីចឹងមែនទេ>?

**ឆ៖** បាទ គឺគាត់នាំកម្លាំងទ័ពទៅវ៉ៃជាមួយវៀតណាម ហើយក៏គាត់នៅគ្រប់គ្រងស-២១ ហ្នឹងដែរ។

**ស៖** តើមានមូលហេតុអី ដែលនាំឱ្យលោកនិយាយថា នៅពេលដែលគាត់ទៅដឹកនាំទ័ពវាយប្រយុទ្ធជាមួយនឹងកងទ័ពវៀតណាម ហើយ<>គាត់<ឈប់>ធ្វើជាមេរបស់ ឌុច<> មានសំអាងអីមានមូលហេតុអីអាចឱ្យលោកឆ្លើយយ៉ាងដូច្នេះបាន?

**ឆ៖** បាទ ពេលនោះគឺខ្ញុំសំអាងលើ សុន សេន មកប្រជុំរៀនសូត្រពួកខ្ញុំ។ ពេលនោះគឺខ្ញុំនឹកឃើញថា គាត់មេរបស់ តាឌុច ហើយ។ ហើយពេលហ្នឹងក៏កងទ័ពហ្នឹងក៏វ៉ៃជាមួយវៀតណាមផង អ៊ីចឹងខ្ញុំនឹកឃើញថា កន្លែងនេះខ្ញុំនៅអត់បានទេ អ៊ីចឹងខ្ញុំលើកដៃសុំគាត់ទៅទ័ពវិញ សុខចិត្តទៅច្បាំង អត់នៅនេះទេ នៅនេះខ្លាចងាប់។ អ៊ីចឹងទៅច្បាំងហ្នឹងងាប់តែម្នាក់ខ្ញុំ កុំឱ្យគេចាប់ទាំងខ្សែដូចចាប់ខ្លួនបានអ៊ីចឹងគេចាប់ម៉ែឪខ្ញុំទៀត។ អ៊ីចឹងខ្ញុំសុខចិត្តគេចខ្លួនពីហ្នឹង តែ សុន សេន អត់ឱ្យខ្ញុំទៅ។

[១១:២៨:២១]

**ស៖** លោកបានឆ្លើយថា លោកបានឃើញគាត់នៅស-២១។ លោកនៅចាំទេ ថាលោកបានឃើញ សុន សេន នៅឯស-២១ ហ្នឹងបានប៉ុន្មានដងដែរ?

**ឆ៖** បាទ ខ្ញុំជួបឃើញគាត់មកម្តង រៀនសូត្រពួកខ្ញុំហ្នឹង។

**ស៖** តើលោកនៅចាំពេលវេលាទេ ពេលណាដែរ ពេលដែលលោកឃើញគាត់នៅឯស-២១នោះ?

**ឆ៖** ខ្ញុំមិនចាំដែរ ប៉ុន្តែក្នុងឆ្នាំ៧៧ ពេលដែលឆ្នាំដែលវ៉ៃជាមួយវៀតណាមហ្នឹង។

**លោក ត្រាវីស ហ្វារ៖**

លោកប្រធាន ខ្ញុំនៅសល់សំណួរដែលត្រូវប្រើប្រាស់ពេលវេលាប្រហែលជា១០នាទីទៀត ប៉ុន្តែមើលទៅឃើញឃើញថាដល់ម៉ោងល្ហមនឹងឈប់សម្រាកហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនាវេលាម៉ោងមួយកន្លះរសៀល។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣០ នាទី ដល់ម៉ោង ១៣:២៩ នាទី)*

[១៣:២៩:២៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយបន្តទៅនេះ ផ្តល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញា តំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ ហើយសូមបញ្ជាក់ថា សហព្រះរាជអាជ្ញារួមទាំងក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅសល់ពេលវេលាតែមួយវគ្គនៃថ្ងៃសវនាការនៅរសៀលនេះ សូមជ្រាប។

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** លោកសាក្សី មុនពេលឈប់សម្រាកបាយថ្ងៃត្រង់ ខ្ញុំបានសួរលោកអំពីមេកោយរបស់ ឌុច ហើយលោកថា មេរបស់ ឌុច ហ្នឹងគឺ សុន សេន យ៉ាងហោចណាស់ក៏មួយរយៈដែរ។ ហើយនៅពេលនោះ គេបានចាត់តាំងឲ្យ សុន សេន ទៅត្រួតបញ្ជាការវាយប្រយុទ្ធជាមួយនឹងកងទ័ពវៀតណាម<នៅបូព៌ា>។ ឥឡូវហ្នឹងខ្ញុំសុំសួរចម្លើយមួយដែលលោកឆ្លើយជូនមន្ត្រីស៊ើបអង្កេតគឺ E3/5155, ERN ជាភាសាអង់គ្លេស 00161591, ខ្មែរ 00146638, បារាំង 00148083។ នេះគឺជាចម្លើយរបស់លោកសូមដកស្រង់៖ "តាសុន សេន ពីមុនគាត់គឺថាត្រួតត្រាលើ ឌុច។ ក្រោយមកទៀត តាខៀវ បាត់ទៅ ខ្ញុំ

មិនដឹងអ្នកដទៃទៀតទេ។ ខ្ញុំដឹង<រឿងនេះ ព្រោះ>មានម្តងនោះគាត់មកនៅក្នុងឆ្នាំ១៩៧៧ ខ្ញុំសុំគាត់ទៅធ្វើទ័ពវិញ ហើយតាំងពីនោះមក ខ្ញុំមិនដែលឃើញគាត់ត្រឡប់មកវិញទេ។ សំណួរសួរថា៖ តើ សុន សេន បាត់ខ្លួនតាំងពីពេលណាទៅ លោកដឹងទេ? លោកឆ្លើយថា៖ ខ្ញុំដឹងថា នៅឆ្នាំ១៩៧៧ ម្តងនោះគាត់មកបង្រៀនពួកយើង។ ហើយក្រោយមក ខ្ញុំលែងឃើញគាត់ទៀតហើយ។" បញ្ចប់ការដកស្រង់។ សំណួររបស់ខ្ញុំ គឺថា លោកបាននិយាយសំដៅទៅមនុស្សម្នាក់ឈ្មោះ សុន សេន ហើយក៏លោកនិយាយឈ្មោះម្នាក់ទៀត ឈ្មោះថា តាខៀវ។ តើ សុន សេន និង តាខៀវ ជាមនុស្សតែមួយ ឬក៏ជាមនុស្សផ្សេងគ្នា?

[១៣:៣២:២០]

**លោក ហ៊ឹម ហ៊ុយ៖**

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកថា តាឌុច ហៅ សុន សេន ហៅ ខៀវ ព្រោះគាត់ថា តាខៀវ ហ្នឹងហើយ សុន សេន នោះ។

**ស៖** ចំណុចមួយទៀតដែលខ្ញុំចាប់អារម្មណ៍ លោកថា តាខៀវ ក៏បាត់ទៅ។ តើពាក្យថា "បាត់តាខៀវ" ទៅហ្នឹងលោកចង់និយាយថាម៉េច?

**ឆ៖** បាទខ្ញុំសូមជម្រាបថា ខ្ញុំបានជួបគាត់មកបង្រៀនពួកខ្ញុំហ្នឹង កាលឆ្នាំ៧៧ហ្នឹងគឺ សុន សេន ហៅ ខៀវ ហ្នឹងគឺគាត់មកបង្រៀនពួកខ្ញុំឆ្នាំ៧៧។ ក្រោយមកទៀត ក៏គាត់អត់មានបានមកបង្រៀនខ្ញុំទៀតទេ គឺគាត់ទៅសមរភូមិ បាទច្បាំងជាមួយវៀតណាមណោះ។ តែការគ្រប់គ្រងគឺនៅតែ សុន សេន ហៅ ខៀវ ហ្នឹងដដែល ដែលគ្រប់គ្រងលើ តាឌុច ហ្នឹងបាទ។

**ស៖** ហេតុអ្វីបានជាលោកប៉ាននិយាយ លោកសំអាងអីថា នៅពេលគាត់ទៅបាត់ទៅ ក៏នៅតែ តាខៀវ ហ្នឹងដដែលជាមេរបស់ ឌុច ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា គាត់មិនប្រកាសថា អ្នកណាមេគាត់តទៀតទេ គឺមានតែ សុន សេន ហ្នឹងហើយដែលជាមេរបស់គាត់។

**ស៖** ខ្ញុំចង់សួរលោកឲ្យជាក់លាក់ តើលោកដែលឮសួរគេនិយាយពាក្យថា បងទី១, បងទី២ ដែរទេ ពេលដែលលោកធ្វើការនៅ ស-២១ នោះ?

**ឆ៖** បាទ តាឌុច ហៅ បងទី១, បងទី២។ បងទី១ គឺ ប៉ុល ពត។ បងទី២ គឺ នួន ជា បាទ។

**ស៖** ហើយថាតើលោកចាំអ្វីខ្លះដែរ ពាក្យសម្តីដែល ឌុច និយាយបងទី២ហ្នឹង គាត់និយាយអ្វី

បន្ថែមឲ្យបានវែងឆ្ងាយខ្លះដែរ ពេលលោកនៅស-២១ នោះ?

**ឆ៖** បាទ គាត់អត់មាននិយាយអីទៀតទេ គ្រាន់តែនិយាយថា បងទី១, បងទី២ ទម្លាប់ឮហៅអ៊ីចឹង ហើយខ្ញុំក៏ឮសួរអ៊ីចឹង ក៏ហៅទី១ ទី២ អ៊ីចឹងដែរទៅ។

**ស៖** ប៉ុន្តែខ្ញុំចង់ឲ្យលោកផ្តោតពេលវេលាតែពេលលោកនៅស-២១ទេ។ <តើលោកបានឮតា> ឌុច ប្រើថាបងទី១ បងទី២ <ទេ?> ហើយបើគាត់ប្រើថាបងទី១ បងទី២អ៊ីចឹង គាត់ប្រើពាក្យនេះនៅ<ក្នុងបរិបទអីដែរ>?

**ឆ៖** បាទ ពេលដែលគាត់ហៅពួកខ្ញុំរៀនសូត្រហ្នឹង គាត់ហៅបងទី១ បងទី២អ៊ីចឹងទៅ។

[១៣:៣៥:៤៩]

**ស៖** ខ្ញុំសូមសួរពីសក្ខីកម្មរបស់សាក្សីម្នាក់ផ្សេងទៀត ហើយដែល<គាត់និយាយ>ពាក់ព័ន្ធទៅនឹង ឌុច និយាយថាបងទី១ បងទី២នៅពេលវគ្គរៀនសូត្រ។ <នេះ>គឺ<ប្រតិចារឹក>នៅថ្ងៃ<>២៧ មេសា បន្ទាប់ពីម៉ោង<១០:៥៧> ព្រឹកគឺ ប្រាក់ ខន ដែលជាអ្នកសួរចម្លើយនៅស-២១។ ហើយគាត់បានមកផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះគាត់ត្រូវបានសួរសំណួរដូចតទៅ សូមដកស្រង់៖ “នៅក្នុងពេលរៀនសូត្រ ឬពេលប្រជុំមួយខែពីរដង ឬមួយខែម្តងហ្នឹងគឺ <តើ> ឌុច <ធ្លាប់>បានប្រាប់ថាអ្នកណាជាមេរបស់គាត់ដែលគាត់ត្រូវទទួលខុសត្រូវចំពោះមុខ ហើយគាត់ត្រូវរាយការណ៍ លោកដឹងដែរទេ? ហើយប្រាក់ ខន ឆ្លើយថា៖ គាត់មិនដែលនិយាយឈ្មោះមេគាត់ឲ្យចំៗទេ។ គាត់និយាយទៅមេៗហ្នឹងថាជាបងទី១ បងទី២។ សួរ៖ តើគាត់និយាយយ៉ាងដូចម្តេចដែរពាក់ព័ន្ធនឹងបងទី១ បងទី២? តើគាត់និយាយញឹកញាប់ទេ? បើនិយាយញឹកញាប់ តើគាត់និយាយថាម៉េច? ឆ្លើយ៖ និយាយពីបងទី១ និងបងទី២ គាត់និយាយពីរបាយការណ៍ដែលគាត់ផ្ញើទៅទាំងពីរ <មិនដឹងថា>បងទាំងពីរទទួល <ឬ>មិនទទួល<នោះទេ>។” បញ្ចប់ការដកស្រង់។

តើនេះវាជួយរំឮកដល់ការចងចាំរបស់លោកទេ ដែលនៅវគ្គរៀនសូត្រហ្នឹង ឌុច បាននិយាយឈ្មោះបងទី១ និងបងទី២? តើជួយរំឭកដល់ការចងចាំថាវាពិតជាបងទី១ និងបងទី២ហើយដែលជាមេរបស់គាត់? តើជួយរំឭកដល់ការចងចាំលោកទេ?

[១៣:៣៧:៣៧]

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា ការហៅបងទី១ បងទី២នេះ គឺពេលដែលរៀនសូត្រពួកខ្ញុំ គាត់ហៅអ៊ីចឹងមែន។ តែដល់ពេលថាអ្នកណាមេតទៅទៀត គឺខ្ញុំអត់ដឹងទេ ព្រោះក្រុមសួរចម្លើយ គេប្រជុំការងារ

របស់គេផ្សេងពីក្រុមពួកការពារ។ បាទបើជុំរួមគ្នាបានគាត់ហៅ ដល់ពេលប្រជុំ ថាអ្នកណាជាមេបន្ត ទៀត បងទី១ បងទី២ គឺខ្ញុំអត់បានដឹងទេ។

**ស៖** ខ្ញុំសូមសួរលោកមួយសំណួរទៀត ពាក់ព័ន្ធនឹងចំណុចនេះដើម្បីឱ្យយល់ច្បាស់។ លោកបាន ឆ្លើយថា តាឌុច បានប្រើពាក្យបងទី១ បងទី២ នៅក្នុងអង្គប្រជុំនេះ។ តើលោកនៅចាំថាគាត់ធ្លាប់និយាយ ឱ្យចំថា បងទី១ និងបងទី២ ពិតជាមេរបស់គាត់ ឬក៏លោកមិនចាំទេ?

**ឆ៖** បាទ គឺខ្ញុំអត់បានឮសួរនិយាយថា ជាមេរបស់គាត់ទេ ប៉ុន្តែគាត់ថាបងទី១ បងទី២ ខ្ញុំថា អ្នកណា មានតែ ប៉ុល ពត ហើយ តានួន ជា ហ្នឹងជាបងទី១ បងទី២។ តែត្រង់ថាមេរបៀបយ៉ាងម៉េច គឺខ្ញុំអត់ដឹងទេ ព្រោះការប្រជុំនោះ ជួនកាលអ្នកសួរចម្លើយប្រជុំជាមួយពួក តាឌុច ផ្សេងអ៊ីចឹងទៅ។ ដល់ រៀនសូត្ររួមគ្នាបាន រួមគ្នានិយាយពីរឿងថាបងទី១ បងទី២អ៊ីចឹង តែប៉ុណ្ណឹងបាទ។

**ស៖** បាទ សូមសួរឱ្យច្បាស់ម្តងទៀត។ លោកទើបតែនិយាយថា ឌុច ហ្នឹងនិយាយថាបងទី១ គឺ ប៉ុល ពត ឯបងទី២គឺ នួន ជា។ តើពាក្យនេះលោកស្តាប់ឮ ឌុច និយាយនៅពេលលោកធ្វើការឯស-២១ នោះឬ?

**ឆ៖** បាទ ពេលដែលខ្ញុំនៅធ្វើការស-២១ហ្នឹង គឺពេលដែលគេហៅរួមគ្នារៀនសូត្រនៅកន្លែង សាលារៀននយោបាយគេមួយនៅខាងត្បូងផ្ទះ តាឌុច ហ្នឹងបាទ។

[១៣:៤០:០៥]

**ស៖** ប៉ុន្តែឈ្មោះបងទី២ដែលកំណត់ថាជា នួន ជា នោះ តើនេះគឺជាអ្វីដែល ឌុច បានប្រាប់ទៅ លោកក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះឬ? ឬក៏ថា សួរម្យ៉ាងទៀតថា លោកដឹងពិតថា <នេះជាអ្វី ដែលលោកបាន>ដឹងនៅពេលដែលលោកធ្វើការនៅស-២១នោះ <ហើយ>មិនមែន<ជាអ្វីដែល>លោក ដឹងក្រោយរបបនោះមកទេ?

**ឆ៖** បាទ ខ្ញុំសុំបញ្ជាក់ថា គឺខ្ញុំដឹងដែលខ្ញុំនៅធ្វើការនៅស-២១ ពេលដែល តាឌុច ហៅពួកខ្ញុំរៀន សូត្រហ្នឹង គឺគាត់ហៅ បងទី១ បងទី២ គឺលោក ប៉ុល ពត ហើយលោក តានួន ជា ហ្នឹង បងទី១ ទី២ ហ្នឹង បាទ។

**ស៖** ប្រធានបទថ្មីមួយទៀត តើលោកធ្លាប់ដែលឮសួរគេនិយាយពាក្យថា “មន្ទីរ៨៧០” ដែរទេ នៅពេលដែលលោកធ្វើការនៅស-២១?

**ឆ៖** បាទ ខ្ញុំឮសួរ តាឌុច នុំងនិយាយថា មន្ទីរ៨៧០ តែខ្ញុំមិនដឹងថាមន្ទីរ៨៧០របស់អ្នកណា

ហើយកន្លែងណា ខ្ញុំអត់ដែលស្គាល់ដែរ។

**ស៖** តើលោក<បាន>ឮ ឌុច និយាយ<អ្វីខ្លះអំ>ពី<>មន្ទីរ៨៧០<>?

**ឆ៖** បាទ នៅពេលរៀនសូត្រហ្នឹងតែម្ដង បាទ។

**ស៖** តើលោកនៅនឹកឃើញគាត់និយាយ<អ្វីទេអំពីមន្ទីរ៨៧០នោះ និយាយក្នុងប្រធានបទអីដែរ?> ថាហេតុអីបានជាគាត់លើកឈ្មោះមន្ទីរ៨៧០ នេះយកមកនិយាយ?

**ឆ៖** បាទ ខ្ញុំអត់ដឹងដែរ។

**ស៖** តើលោកឮគាត់និយាយតែក្នុងពេលរៀនសូត្រហ្នឹងតែម្ដងទេ ឬក៏ឮនៅពេលរៀនសូត្រហ្នឹងច្រើនដង?

[១៣:៤២:៣៨]

**ឆ៖** បាទ រៀនសូត្រពេលណា គឺគាត់និយាយថា ឈ្មោះលេខប៉ុន្មាននេះអំមិញហ្នឹង បាទ។

**ស៖** ដោយសារថាគាត់តែងតែលើកមកនិយាយរៀងរាល់វគ្គរៀនសូត្រ។ ខ្ញុំសុំឲ្យលោកនឹកឡើងវិញមើល ថាតើគាត់និយាយអ្វីខ្លះដែរអំពីមន្ទីរ៨៧០នេះ?

**ឆ៖** គាត់អត់មាននិយាយអីតទេ គ្រាន់ថាបងទី១ បងទី២ ហើយមន្ទីរ៨៧០ហ្នឹង។ ខ្ញុំដឹងតែប៉ុណ្ណឹង ខ្ញុំមានបានដឹងអីតទៅទៀតទេ។ បានដឹងថាគាត់ហ្នឹងជាមេដឹកនាំរបស់ តាឌុច ហ្នឹងទៀតហើយ។

**ស៖** ខ្ញុំព្យាយាមម្ដងទៀត។ នៅពេលគាត់និយាយឈ្មោះកន្លែងនេះ <តើ>គាត់និយាយ<>ថា <ជាកន្លែង>ផ្គត់ផ្គង់សម្ភារៈអីមក <ឬក៏ថា>ជាកន្លែងដែល<ណែនាំ និង>បញ្ជាមកគាត់ ឬក៏ជាកន្លែងដែលគាត់ត្រូវទទួលខុសត្រូវចំពោះមុខមន្ទីរហ្នឹងទៅលើផ្នែកណាមួយ?

**ឆ៖** បាទ ខ្ញុំសុំជម្រាបថា ខ្ញុំអត់ដឹងទេ ព្រោះមិនមែនការងាររបស់គាត់ អ៎!របស់ខ្ញុំទេ គឺការងាររបស់គាត់ទេ។

**លោក ត្រាវីស ហ្វារ៖**

បាទ សូមអរគុណក្នុងការឆ្លើយនឹងសំណួររបស់ខ្ញុំ។ ខ្ញុំសុំប្រគល់នាទីនេះជូនទៅសហមេធាវីនាំមុខតំណាំងដើមបណ្ដឹងរដ្ឋប្បវេណី។

[១៣:៤៤:៣០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីមានឱកាសសួរដេញ

ដោលចំពោះសាក្សីរូបនេះ។

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគីដើមបណ្ដឹងរដ្ឋប្បវេណី និងសាធារណជន។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ ជម្រាបសួរលោក ហ៊ីម ហ៊ុយ។ ខ្ញុំបាទឈ្មោះ ពេជ អង្គ ជាមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ជាមួយនឹងលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ដែលអង្គុយជិតខ្ញុំនេះ។ ហើយខ្ញុំមានសំណួរមួយចំនួនដើម្បីសួរទៅលោក ដើម្បីឱ្យលោកបំភ្លឺ ឆ្លើយជូនអង្គសវនាការ។ ជាបឋមពាក់ព័ន្ធទៅនឹងពេលដែលលោកចាប់ផ្ដើមធ្វើការនៅមន្ទីរស-២១ ថាតើលោកអាចបញ្ជាក់បានទេ ថាតើលោកចាប់ផ្ដើមធ្វើការនៅស-២១នោះ គឺពីឆ្នាំណាមកដែរ? ហើយនៅកន្លែងណាដែរ?

**លោក ហ៊ីម ហ៊ុយ៖**

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ថា គឺមិនចាំខែថ្ងៃទេ ប៉ុន្តែដឹងថាឆ្នាំ៧៦ហ្នឹង គេយកខ្ញុំមកកន្លែងហ្នឹង គឺនៅទួលស្លែងហ្នឹងហើយបាទ។

[១៣:៤៥:៤៨]

**ស៖** តើពេលនោះជាពេលដែលទួលស្លែងទើបចាប់ដំណើរការមែនទេ?

**ឆ៖** បាទ ពេលនោះគឺពួក តាឌុច ហ្នឹងគេនៅហ្នឹងយូរហើយ ប៉ុន្តែនៅខាងលិច ហើយទួលស្លែងគេទើបចាប់ដំណើរការក្រោយដែលខ្ចីអង្គភាពពួកខ្ញុំពី៧០៣ យកមករៀបចំកន្លែងហ្នឹង។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សួរថា លោកបានបញ្ជាក់ថា លោកជាអ្នកយាមនៅខ្លោងទ្វារមួយនៅជិតវិទ្យុសំបុកឃ្មុំ ចាំទទួលអ្នកទោសចូលមក។ ក្នុងចំណោមការងារផ្សេងៗទៀតរបស់លោក អ៊ីចឹងតើលោកអាចដឹងដែរទេថា នៅក្នុងស-២១ ហ្នឹង តើមានខ្លោងទ្វារចេញចូលប៉ុន្មានដែរ?

**ឆ៖** បាទ នៅស-២១ហ្នឹងមានខ្លោងទ្វារច្រើន ប៉ុន្តែបិទ ខាងជើងក៏បិទ ខាងលិចក៏បិទ ទុកតែច្រកមួយតាមផ្លូវរបស់ខ្ញុំហ្នឹង គឺកន្លែងប៉ុស្តិ៍សំបុកឃ្មុំហ្នឹងហើយបាទ។

**ស៖** អ៊ីចឹងមានន័យថា ភាគច្រើនឱ្យតែមានការចេញចូលតាមច្រកដែលលោកនៅនុ៎ង គឺលោកដឹង អ៊ីចឹងមែនទេថា អ្នកណាចេញ អ្នកណាចូលអ៊ីចឹង?

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ ជួនកាលច្រកមានតែមួយ ពីកើតហ្នឹងមកមានតែច្រកមួយហ្នឹងទេ។ ជួនកាលពួកខ្ញុំអត់បានដឹងដែរ មានឡានគេពីអង្គភាពណាគេដឹកចូលទៅដល់មុខគុកហ្នឹងតែម្ដង ខ្លោងទ្វារគុក។ បាទ ដល់អ៊ីចឹង តាហ៊ី អី ឃើញអ៊ីចឹងមកឡូឡាពួកខ្ញុំថា អត់មានអ្នកណាយាមអ្នកណាអី ឱ្យឡានគេចូលដល់ហ្នឹង។ តែខ្ញុំអត់ចាំថាអង្គភាពណាចូលទៅដល់ហ្នឹងទេ ដឹកអ្នកទោសចូលទៅ។

[១៣:៤៨:០១]

**ស៖** បាទអ៊ីចឹង តើករណីដែលឡានចូលទៅដល់ខាងក្នុងហ្នឹងដែលលោកមានប្រសាសន៍អម្បាញ់មិញជាករណីលើកលែងតិចតួច ឬក៏មានច្រើនលើកដែរ ដែលឡានរបស់អង្គភាពក្រៅគេចូលទៅដល់ក្នុងផ្ទាល់តែម្ដង?

**ឆ៖** បាទ គឺមិនមែនតិចទេដែលគេ ដែលពួកខ្ញុំប្រហែសអត់មើល រវល់តែចិញ្ចឹមសត្វ ដើរមើលសត្វ ឱ្យចំណីសត្វនោះ ដល់អ៊ីចឹងអត់មានអ្នកនៅយាម មានតែអ្នកដេកអ្នកអីអ៊ីចឹង។ អ៊ីចឹង ដល់ពេលអ៊ីចឹងទៅឡានគេចូលទៅផុត អត់មានអ្នកយាមឃាំងអត់ឱ្យគេទៅ គេអត់ឃើញមនុស្សអ៊ីចឹងគេចូលទៅដល់នោះបណ្ដោយ។

**ស៖** ជាទូទៅឡានដែលចូលមកស-២១ ឡានខាងក្រៅ ឬក៏ឡានដឹកមនុស្សពីខាងក្រៅមក ជាឡានរបស់ស-២១ ដែលលោកបានមានប្រសាសន៍ហ្នឹង ថាតើឡានទាំងអស់នោះដឹកមនុស្សចូលមកក្នុងអំឡុងពេលណាដែរ? ពេលថ្ងៃ ឬក៏ពេលយប់? ហើយចន្លោះពីម៉ោងប៉ុន្មានទៅម៉ោងប៉ុន្មាន លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ គឺមានពេលថ្ងៃ ដឹកចូលមកពេញថ្ងៃ ប្រហែលជាម៉ោងដប់មួយ ដប់ពីរហ្នឹងដែលដឹកចូលមក។

**ស៖** ចុះៗពេលយប់មានដែលដឹកចូលមកទៀតទេ?

**ឆ៖** បាទ គឺពេលយប់គឺអត់ដឹងចូលមកទេ ព្រោះពេលយប់ពួកខ្ញុំយាម។

**ស៖** បាទ អ៊ីចឹងខ្ញុំចង់សួរអំពីឡានរបស់អ្នកក្រៅ របស់តំបន់ផ្សេងដែលដឹកមនុស្សចូលមកលោកដែលនៅយាមជាប់នៅទីនោះ ភាគច្រើនលោកនៅទីនោះ លោកអាចបញ្ជាក់បានទេ តើញឹកញាប់យ៉ាងណាដែលឡានមកពីក្រៅដឹកមនុស្សចូលមកកន្លែងលោកហ្នឹង? តើលោកអាចនិយាយបានទេ ក្នុងរយៈពេលប៉ុន្មានថ្ងៃម្ដង មួយថ្ងៃម្ដង ឬក៏ថាពីរបីថ្ងៃម្ដង ឬក៏មួយអាទិត្យម្ដង លោកអាចបញ្ជាក់បានទេ?

[១៣:៥០:២៧]

**ឆ៖** បាទ ពេលដែលដឹកចូលមកហ្នឹង គឺមានឡាន៣១០ កងពល៣១០ ហើយនិងភូមិភាគឧត្តរ ដែលដឹកចូលមកកន្លែងហ្នឹង។ ជួនកាលខាង១៧០ កងពលខាងភូមិភាគបូព៌ាបាទ ហើយនិង៧០៣។

**ស៖** អ៊ីចឹងមានន័យថា លោកមានប្រសាសន៍អម្បាញ់មិញជាឡានដដែលៗ ឬក៏ថាមានឡាន ប្លែកៗដែលលោកមិនដែល មិនសូវដែលឃើញដឹកមនុស្សមកដែរ?

**ឆ៖** បាទ សូមជម្រាបថា ឡាននោះគឺមិនមែនឡានដដែលទេ គឺឡានប្លែកៗ។ តែបើឡានដដែល មានតែ៣១០មួយទេ ដែលបញ្ជូនមនុស្ស គឺឡានដដែលៗ។

**ស៖** លោកអាចបញ្ជាក់បានទេ តើមានពេលណាមួយដែលថាឡាន ក្រុមណាមួយមកច្រើន ឧបមាថា លោកបានមានប្រសាសន៍អំពីឡាន៣១០ ថាតើឡាន៣១០ហ្នឹងមកច្រើនក្នុងអំឡុងពេលខែណា ឆ្នាំណា លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ ខ្ញុំអត់ចាំដែរ ព្រោះជួនកាលគេមក ម្តង ពីរដងអ៊ីចឹងទៅក្នុងមួយថ្ងៃ ឬមួយក៏ប្រាំថ្ងៃគេ មកម្តងទៀតមក។ ក្រោយមកទៀត គឺយូរទៅបានគេមកទៀតមក ព្រោះខ្ញុំអត់ចាំថ្ងៃ ចាំអីទេ បាទ។

**ស៖** លោកអាចបញ្ជាក់បានទេ ឡាន៣១០ហ្នឹង កងពល៣១០ហ្នឹង នៅកន្លែងណាដែរលោក?

**ឆ៖** បាទ ខ្ញុំសូមជ្រាបថា ខ្ញុំអត់ដឹងទីតាំងគេនៅកន្លែងណាទេ បាទ។

**ស៖** ចុះលោកមានដែលឃើញឡាននៅខាងតំបន់១ឧត្តរ ឬក៏ថាតំបន់បូព៌ា តើមាន ពួកគាត់មាន ឡានណាមួយជាក់លាក់របស់គាត់ទេ?

[១៣:៥៣:១៣]

**ឆ៖** បាទពេលនោះគឺដូចថា ខាងបូព៌ាអ៊ីចឹង គឺឡានមានតែអាស៊ីនចិន ហើយនិងអាកាត់-អាកាត់ ចិនហ្នឹង ព្រោះឡានពេលនោះ គឺបើកសុទ្ធឡានរបស់ចិនទាំងអស់។ ដូចឧត្តរក៏អ៊ីចឹងដែរ ហើយជួនកាល មានឡានអាកាត់-អាកាត់ របស់អាមេរិកពីមុនមកអ៊ីចឹងដែរ។

**ស៖** ហើយលោកអាចប៉ាន់ស្មានបានទេ ឡានដែលដឹកមនុស្សពីភូមិភាគ ឬក៏ពីតំបន់ចូលមក ស-២១ហ្នឹង ឡានហ្នឹងអាចផ្ទុកមនុស្សបានប៉ុន្មាននាក់? ឬក៏លោកអាចឆ្លើយអ៊ីចេះថា ជាធម្មតាមនុស្ស ប៉ុន្មាននាក់ដែលដឹកតាមឡានមកម្តងៗ លោកអាចប៉ាន់ស្មានបានទេ?

**ឆ៖** បាទ ប៉ាន់ស្មាន ក្នុងអ្នកដឹកមក ដូចឡានអាកាត់-អាកាត់អាមេរិក ឬក៏អាកាត់ចិនអ៊ីចឹងគឺ បាន១០នាក់ទៅ២០នាក់ ដែលយកមក។

**ស៖** បាទ អរគុណ។ ចុះឡានរបស់ស-២១ លោកអាចបញ្ជាក់បានទេ ស-២១ មានឡានណាខ្លះ

ដែលត្រូវដឹកមនុស្ស យកពីក្រៅយកមកក្នុង? តើមានឡានប៉ុន្មានគ្រឿង ហើយមានប្រភេទឡានអីខ្លះ?

**ឆ៖** បាទ ឡានមានប្រាំគ្រឿង អាស៊ីនចិនមួយ អាកាត់-អាកាត់ចិនពីរ ហើយនិងឡង់រ៉ូវែរពីរ។ ពេលទៅដឹកនៅក្រៅហ្នឹង គឺឡានឡង់រ៉ូវែរ ទៅដឹកនៅក្រៅ បាទ។

**ស៖** អ៊ីចឹងឡានហ្នឹង អាចដឹកមនុស្សបានប្រហែលជាប៉ុន្មាននាក់ដែរ ឬបាទ?

**ឆ៖** បាទ ឡង់រ៉ូវែរ ដឹកបានចំនួនគ្នា១០នាក់ដែរ ក្នុងឡានមួយ។

**ស៖** នៅៗពេលដែលដឹកមនុស្សចូលមកស-២១ តើលោកមានៗមនុស្សប៉ុន្មាននាក់ដែលមកជាមួយឡានដែលជាសន្តិសុខ ដែលទៅជាមួយឡានដើម្បីជញ្ជូនមនុស្សមកស-២១?

[១៣:៥៦:០៨]

**ឆ៖** បាទ គឺទៅ ដូចទៅបាត់ដំបងអ៊ីចឹង ទៅបាត់ដំបងអ៊ីចឹង គឺឡានមានឡង់រ៉ូវែរពីរគ្រឿងទៅ បាទ។ ឡានមួយការពារអ្នកទោស ហើយឡានមួយទៀត ចំនួនគ្នាបួននាក់ អ្នកមុខពីរនាក់ អ្នកក្រោយពីរនាក់។

**ស៖** បាទ ក្រៅពីទៅដល់បាត់ដំបង ថាតើឡានហ្នឹងមានបានចូល ទៅទទួលមនុស្សពីតំបន់ផ្សេងទៀតទេ?

**ឆ៖** បាទ ពេលទៅហ្នឹង គឺទៅទទួលនៅតែកន្លែងបាត់ដំបងហ្នឹង នៅកន្លែងសាលារៀនគេ។ គេចាប់ហើយ យើងទៅដល់ លើកអ្នកហ្នឹងយកមកដាក់ឡាន ដាក់អី បិទទ្វារនាំគ្នាចេញមកវិញមក ពេលយប់ បាទ ពេលយប់។

**ស៖** ចុះមានពេលផ្សេងទៀតដែលឡានស-២១ ទៅទទួលមនុស្សពីកន្លែងផ្សេងទៀតមកទេ ក្រៅពីនៅខេត្តបាត់ដំបង?

**ឆ៖** បាទ មានទទួលនៅឯស្វាយរៀងក៏មាន នៅតាមកន្លែងឃ្លាំងរដ្ឋ ឃ្លាំងអីហ្នឹងក៏ឡានស-២១ ទៅយក។

**ស៖** អ៊ីចឹងមានន័យថា ឃ្លាំងរដ្ឋហ្នឹង លោកអាចបញ្ជាក់បានទេ នៅៗកន្លែងណា នៅភ្នំពេញ ឬក៏ថានៅតាមខេត្ត?

**ឆ៖** បាទ គឺនៅក្នុងភ្នំពេញ។

[១៣:៥៨:១៧]

**ស៖** តើមានពេលណាមួយ មានឡានរបស់ស-២១ ទៅទទួលកម្មករកាត់ដេរនៅផ្សារអូរឫស្សី

ទេ ឬក៏អ្នកជាងម៉ាស៊ីនកាត់ដេរនៅផ្សារអូរឫស្សីមានពេលណាមួយទេ?

**ឆ៖** បាទ គឺខ្ញុំអត់បានចាំដែរ ព្រោះជួនកាលខ្ញុំទៅ ជួនកាលពួកគេទៅ បាទ ជាមួយ តាហ៊ី ជាមួយអីហ្នឹង គេទៅៗ។

**ស៖** បាទ អរគុណច្រើន។ ចង់សួរបញ្ជាក់ចុងក្រោយបន្តិច ពាក់ព័ន្ធទៅនឹងការដឹកមនុស្សមកជើងឯកដោយឡានរបស់ជើងឯក។ តើគេមានបែងចែកជាក្រុមសម្រាប់ទៅដឹកទេ? លោកមានៗប្រសាសន៍ថាអម្បាញ់មិញ ជួនកាលមានលោកទៅ ជួនកាលមាន តាហ៊ី ទៅ ថាតើមានប៉ុន្មានក្រុមពីជើងឯកហ្នឹង ដែលគេបែងចែកសម្រាប់ទៅយកមនុស្សចូលស-២១ម្តងៗ?

**ឆ៖** បាទ អត់មានយកពីជើងឯកមកទេ គឺយកពីស-២១ ទៅជើងឯក។

**ស៖** បាទ សុំទោសៗ ខ្ញុំច្រឡំ។ យកពីខាងក្រៅ យកមកចូលស-២១ ថាតើមាននៅស-២១ហ្នឹងមានមនុស្សប៉ុន្មានក្រុមដែលដូរវេនគ្នាទៅយកមនុស្សពីខាងក្រៅ ចូលមកស-២១? សុំទោស ខ្ញុំច្រឡំអម្បាញ់មិញ។

**ឆ៖** សូមលោកបញ្ជាក់ម្តងទៀត ខ្ញុំស្តាប់អត់បានដែរ។

**ស៖** លោកបានមានប្រសាសន៍ថា លោក ជួនកាលលោកទៅយកមនុស្សពីខាងក្រៅ តាមរយៈឡានស-២១ ហ្នឹងយកមកដាក់នៅក្នុងគុកស-២១។ ហើយជួនកាល តាហ៊ី គាត់ទៅ។ អ៊ីចឹងថាតើក្រុមដែលទៅយកមនុស្សពីខាងក្រៅចូលមកស-២១ ដូចលោកហ្នឹង គេមានបែងចែកជាប៉ុន្មានក្រុមទេ?

[១៤:០០:៤៩]

**ឆ៖** បាទ គឺយកកម្លាំងពីខាងក្នុងមកជួយ ហើយនិងកម្លាំងពួកខ្ញុំដែលនៅចាំទទួលអ្នកទោសហ្នឹងខ្លះទៅ។ បាទ យកការពារឡាន ហើយនិងយកមនុស្សមកដាក់តាមឡាន ដើម្បីការពារសុវត្ថិភាពមកតាមផ្លូវ។

**ស៖** បាទ អ៊ីចឹងបើខ្ញុំនិយាយថា មិនមានការបែងចែកជាក្រុមជាក់លាក់ថា លើកនេះក្រុមនេះលើកនោះក្រុមផ្សេងអីទេអ៊ីចឹង តែបើខ្ញុំសន្និដ្ឋានថាមិនមានការបែងចែកក្រុមជាក់លាក់អ៊ីចឹង តើខ្ញុំអាចនិយាយអ៊ីចឹងត្រូវទេលោក?

**ឆ៖** បាទ លោកមានប្រសាសន៍ហ្នឹងត្រូវហើយ ព្រោះគេយកមក យកមករួមគ្នា ហើយទៅដឹកជញ្ជូនយកមកហ្នឹងបាទ ព្រោះកម្លាំងខាងក្រៅក៏ខ្វះដែរ ព្រោះចាប់អស់គ្នាច្រើនហើយ។

**ស៖** ខ្ញុំចង់សួរបញ្ជាក់ទៀត នៅពេលដែលយកមនុស្សពីបាត់ដំបង ឬក៏ថាយកមនុស្សពីស្វាយ

រៀងចូលមកស-២១ ថាតើពេលនោះមាននរណាម្នាក់ក្នុងចំណោមលោកដែលជាអ្នកទៅយកគេមកហ្នឹង បានប្រាប់ជាព័ត៌មានទៅដល់អ្នកទោសហ្នឹង ថាតើអ្នកទោសហ្នឹងមានសិទ្ធិអ្វីខ្លះ សិទ្ធិនៅក្នុងការនិយាយស្តី សិទ្ធិនៅក្នុងការតវ៉ាអីផ្សេងៗ? ថាតើមាននរណាគេម្នាក់និយាយអំពីសិទ្ធិនេះប្រាប់ទៅដល់អ្នកទោសដែរឬទេ?

**ឆ៖** បាទ គឺអត់មាននរណានិយាយ គ្រាន់តែថាជិះឡានហើយ កុំមាត់កុំអី តែប៉ុណ្ណឹង។

**ស៖** តើលោកធ្លាប់ធ្វើការងារហ្នឹងផ្ទាល់? តើលោកបានឃើញថាមានអ្នកទោសណាគាត់និយាយគ្នា ឬក៏ឡូឡា ឬក៏ជជែកគ្នាក្នុងពេលចាប់ ឬក្នុងពេលធ្វើដំណើរមកដល់ស-២១ ទេ?

**ឆ៖** បាទ គឺអត់មានទេបាទ។

[១៤:០៣:១០]

**ស៖** លោកមានបានពិនិត្យមើលស្ថានភាពរបស់អ្នកទោសហ្នឹង ថាតើអ្នកទោសហ្នឹងគាត់មានស្ថានភាពភ័យខ្លាចទេ នៅពេលដែលគេចាប់គាត់មក?

**ឆ៖** បាទ អ្នកទោសគឺមានស្ថានភាពភ័យខ្លាច ឡើងញាក់ខ្លួនទទ្រើកបាទ។

**ស៖** ហើយមានដែលមានអ្នកយាមណាមួយនៅតាមឡាន បានវ៉ៃដំទៅលើអ្នកទោសក្នុងពេលធ្វើដំណើរពីកន្លែងចាប់មករហូតទៅដល់ស-២១ ដែរឬទេ?

**ឆ៖** បាទ គឺគេមានច្បាប់មួយថា មិនឲ្យធ្វើអីអ្នកទោសហ្នឹងទេ គឺធ្វើម៉េចយកមកឲ្យបានស្រួលបួល ព្រោះសុទ្ធតែយកមក គេនឹងត្រូវសួរចម្លើយ។

**ស៖** អ្នកទោស ករណីដែលធ្វើដំណើរពីខេត្តបាត់ដំបង ឬពីស្វាយរៀង មកដល់ស-២១ ថាតើដែលមានអ្នកទោសគាត់ទាមទាររក គាត់និយាយថាគាត់ហេវហត់ណាស់ ឬក៏ថាគាត់ស្រេកទឹក គាត់មានស្នើសុំឲ្យមានទឹកអីបរិភោគ? ហើយមានករណីបែបនេះ ថាតើមានការផ្តល់ទឹក ឬក៏ជាអាហារអ្វីដល់គាត់សម្រាប់បរិភោគដែរឬទេ?

**ឆ៖** បាទ គឺពេលធ្វើដំណើរមក គឺអត់មានទាមទារទឹក ទាមទារអីទេ ព្រោះបើកឡានប្រញាប់តែទាំងអស់ អត់មាននៅរញ៉េរញ៉ៃអីទេបាទ ព្រោះពេលយប់។

[១៤:០៥:០៤]

**ស៖** បាទ សូមអរគុណ ហើយអ្នកទោសដែលៗមក លោកមានប្រសាសន៍ថា មានទាំងអ្នកខ្លះ មានទាំងប្រពន្ធ មានទាំងកូន ហើយមានករណីដែលកូនៗហ្នឹងមានយំតាមឡាន លោកមានបានធ្លាប់ជួប

ប្រទះបញ្ហានេះទេ?

**ឆ៖** បាទ គឺខ្ញុំអត់បានជួបប្រទះទេ មានតែគេទេដឹកយកមកទាំងម៉ែទាំងឪ ទាំងប្រពន្ធហ្នឹង គឺអង្គភាពគេដែលដឹកមក។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់ចូលទៅដល់ចំណុចមួយទៀតដែលលោកនៅមន្ទីរសន្តិសុខ នៅយាមនៅមន្ទីរសន្តិសុខ ឬក៏ជាអ្នកបញ្ជូនមនុស្សទៅជើងឯក ខ្ញុំនិយាយអំពីការបញ្ចេញមនុស្សពីស-២១ ទៅជើងឯកវិញ។ ខ្ញុំចង់សួរលោកអំពីភាពញឹកញាប់ ថាតើវាញឹកញាប់ទេ ដែលមានឡានដឹកតាមខ្លោងទ្វារដែលលោកយាមទៅជើងឯក? លោកអាចបញ្ជាក់ថា មានប៉ុន្មានថ្ងៃម្តង លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ វាអត់ទៀតទេ ជួនកាលគេសួរចម្លើយបានច្រើនអ៊ីចឹងទៅ ចប់អ៊ីចឹងទៅ មានចំនួនប៉ុន្មាន គេនឹងដឹកចេញទៅ ជួនកាលកន្លះខែ ទៅ១ខែ បានដឹកទៅម្តង។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំយល់ឃើញថា មានបញ្ហាបកប្រែ ដោយសារមិនចំចំណុច ដូចមិនត្រឹមត្រូវ ព្រោះពាក់ព័ន្ធពីការបញ្ជូនពីកន្លែងចាប់មកព្រៃស ហើយពេលបកហ្នឹងគឺនិយាយអំពីការបញ្ជូន ដឹកបញ្ជូនហ្នឹងពីព្រៃសទៅជើងឯកទៅវិញ។

[១៤:០៧:១៤]

**លោក ពេជ អង្គ៖**

ខ្ញុំសួរអម្បាញ់មិញអំពីការបញ្ជូនមនុស្សពីស-២១ទៅជើងឯក ដោយសារគាត់ជាអ្នកយាមនៅខ្លោងទ្វារចេញរបស់ស-២១។ អ៊ីចឹងប្រហែលជាអាចមាន ខ្ញុំនិយាយច្រឡំ ឬក៏ការបកប្រែច្រឡំ។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** ខ្ញុំសួរបន្តទៀត អំពីការអប់រំដល់អ្នកដែលជាបុគ្គលិកសន្តិសុខរបស់ស-២១។ ក្នុងនាមជាអ្នកសន្តិសុខហ្នឹង ឬក៏ថាអ្នកផ្សេងៗទៀតដែលនៅក្រុមដូចលោក ឬក៏ធ្វើការដូចលោកហ្នឹង ថាតើពួកគាត់បានធ្វើ បានទទួលការបណ្តុះបណ្តាលអ្វីខ្លះ លោកអាចបញ្ជាក់បានទេ?

**លោក ហ៊ីម ហ៊ុយ៖**

**ឆ៖** បាទ គេអប់រំពួកទូទៅទាំងអស់គ្នា គឺថាយើងជាកូនចៅរបស់អង្គការ គោរពអង្គការ អ្នកណាមិនដើរតាមកង់ប្រវត្តិសាស្ត្រ កង់ប្រវត្តិសាស្ត្រនឹងកម្ទេចចោល។ អ្នកណាដែលចាប់យកមកហើយហ្នឹងជាខ្មាំងរបស់អង្គការហើយ។

01297802



**សះ** តើគេមានបណ្តុះបណ្តាលលោកអំពី -- នៅពេលដែលថាជួបជាមួយអ្នកទោស ថាតើត្រូវនិយាយអំពី ជម្រាបអំពីសិទ្ធិរបស់អ្នកទោសទៅអ្នកទោសដែរឬទេ? ត្រូវគោរពសិទ្ធិអ្នកទោសអ្វីខ្លះ? គេមានបានបង្រៀនលោកអំពីបញ្ហានេះទេ នៅពេលដែលលោកទទួលការបណ្តុះបណ្តាលពី ហ៊ី ឬក៏ពី ឌុច ឬក៏ពី សុន សេន?

**ឆះ** បាទ ដូចខ្ញុំបានជម្រាបអ៊ីចឹងគឺថា អ្នកទោសដែលចូលមកហើយ គឺគ្មានសិទ្ធិទេ គឺគេចោទថាជាខ្មាំងហើយ។ ចោទថាជាខ្មាំងហើយ អ្នកទោសមានសិទ្ធិអីណាទៀត។

[១៤:០៩:១៥]

**សះ** អ៊ីចឹងប្រសិនថាខ្ញុំសន្និដ្ឋាន គឺជម្រាបជូនលោកវិញ ថាតើត្រឹមត្រូវទេដែលថា ពេលដែលលោកទទួលការបណ្តុះបណ្តាលអំពី ហ៊ី ក្តី, ឌុច ក្តី ឬ សុន សេន ក្តី នៅស-២១នោះ គឺលោកមិនដែលបានបណ្តុះបណ្តាលអំពីការគោរពសិទ្ធិរបស់អ្នកទោសនោះទេ។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

**ឆះ** បាទ ខ្ញុំសូមជម្រាបថា មិនមែនតែខ្ញុំទេ ទូទៅទាំងអស់គ្នា។ តែគេចាប់អ្នកណាមក នុំងជាខ្មាំងហើយ គឺគេមិនឲ្យគោរពសិទ្ធិអ្នកណាអ្នកណីប៉ុន្មានទេ។ បើអ្នកណាហ៊ានទៅគោរពសិទ្ធិ ឲ្យអ្នកទោសមានសិទ្ធិមានអី គឺអ្នកហ្នឹង ដឹង គេនឹងចាប់ខ្លួនទៀត។

**សះ** តើមានករណីដែលគេចាប់ខ្លួនអ្នកដែលធ្វើអ្វីមួយ ដូចលោកមានប្រសាសន៍អម្បាញ់មិញទៅដល់អ្នកទោសទេ អ្នកដែលគោរពសិទ្ធិទៅដល់អ្នកទោសហ្នឹង? តើមានអ្នកណាម្នាក់មានបញ្ហា ដោយសារបញ្ហាដែលគាត់គោរពសិទ្ធិទៅលើអ្នកទោសទេ?

**ឆះ** បាទ ក៏ខ្ញុំអត់បានដឹងដែរ ព្រោះខ្ញុំនៅខាងក្រៅណោះ។ ប៉ុន្តែអ្នកណាមួយដែលយកចិត្តទុកដាក់ជាមួយអ្នកទោស ក៏គេត្រូវតែតាមដាន។ ហើយតែលួចបាយ លួចអីឲ្យអ្នកទោស ក៏គេហៅទៅប្រជុំបើមិនកែប្រែ គេនឹងចាប់ដាក់គុក។

**សះ** បាទ អរគុណ។ ហើយសំណួរមួយទៀត លោកជាអ្នកសន្តិសុខផងដែរ សន្តិសុខនៅស-២១ តើលោកមានចូលរួមនៅក្នុងការហាត់វាយអី ហាត់ការ៉ាតេដូ ឬក៏ហាត់ស៊ីនៅកន្លែងស-២១ទេ ឬក៏ថា មានការបណ្តុះបណ្តាលអំពីការហ្វឹកហាត់បែបនេះ នៅស-២១ ដែរឬទេ?

**ឆះ** បាទ ពេលនោះគឺ តាហ៊ី អ្នកបង្រៀនហាត់ការ៉ាតេហ្នឹង ហើយខ្ញុំក៏ហាត់ដែរ ហាត់ដែរ។ ដល់គេវៃបែកមាត់ ខ្ញុំឈប់ហាត់បណ្តោយ។ បាទ ស្នាមមាត់មកទល់ឥឡូវ។

[១៤:១១:៤១]

**ស៖** លោកអាចពន្យល់បានទេ មូលហេតុអ្វីបានជាចាំបាច់ឲ្យអ្នកសន្តិសុខដូចរូបលោក ឬក៏អ្នកដទៃទៀតហ្នឹង ទទួលបាននូវការហ្វឹកហាត់ការ៉ាតេដូ នៅស-២១?

**ឆ៖** បាទ ការហាត់ហ្នឹងគឺ តាហ៊ី អ្នកបង្ហាត់ ឲ្យពួកខ្ញុំទាំងអស់គ្នាហ្នឹងហាត់ ដើម្បីចាប់អ្នកទោសបាទ។ បើកាលណាមិនហាត់ទេ គឺទៅចាប់គេម៉េចបាន។

**ស៖** អ៊ីចឹងមានន័យថា ហាត់ដើម្បីឲ្យខ្លួនអាចធ្វើការរបស់ខ្លួនដោយមានប្រសិទ្ធភាព អ៊ីចឹងមែនទេ?

**ឆ៖** បាទ គឺហាត់ហ្នឹង គឺធ្វើម៉េចកុំឲ្យអ្នកទោសតដៃបាន គឺយើងត្រូវហាត់ចេះក្បាច់អស់ហ្នឹង យើងត្រូវចាប់ តែចាប់បាន ចាប់បានតែម្តង។

**ស៖** បាទ អរគុណ។ ខ្ញុំមុននឹងចូលទៅដល់ជើងឯក ខ្ញុំមានសំណួរមួយសួរបញ្ជាក់បន្ថែមបន្តិច។ លោកបានឆ្លើយជាមួយតំណាងសហព្រះរាជអាជ្ញាអន្តរជាតិច្រើនហើយ អំពីមនុស្សដែលគេ -- កូនតូចដែលគេសម្លាប់នៅស-២១ ឬក៏កុមារដែលគេសម្លាប់នៅស-២១។ នៅពេលដែលគេយកកុមារពីជាន់ខាងលើនៃស-២១ មកខាងក្រោម ហើយបន្ទាប់មកលោកបានមានប្រសាសន៍ថា មុននឹងឲ្យឪពុកម្តាយចេញទៅ គឺគេសម្លាប់កូនហើយស្រេចហើយ បានគេយកឪពុកម្តាយ យកទៅជើងឯក។ អ៊ីចឹងមានករណីណាមួយដែលគេយកឪពុកម្តាយ យកទៅជើងឯងហើយ ហើយគេ បានគេសម្លាប់កូនៗ កុមារនៅក្រោយទេនៅស-២១ ហ្នឹង?

[១៤:១៣:៤៧]

**ឆ៖** បាទ គឺអត់មានទេ។

**ស៖** លោកថា អត់មាន ឬក៏លោកថា លោកអត់ដឹង លោកអាចបញ្ជាក់បានទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

**លោក ហ៊ឹម ហ៊ុយ៖**

**ឆ៖** បាទ គឺគេត្រូវយកកូនទៅមុនហើយ បានគេយកម្តាយឪពុកទៅ បើអ៊ីចឹងគឺស្រែកផ្អើលពេញកន្លែងគុកហ្នឹង។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ ឥឡូវខ្ញុំចូលសួរទៅដល់ករណីជើងឯក។ ខ្ញុំអត់នៅសល់សំណួរច្រើនទេ ហើយបន្ទាប់

មកសហការីខ្ញុំនឹងសួរលោកបន្តទៀត។ នៅជើងឯក លោកមានប្រសាសន៍ថា មនុស្សគេសម្លាប់ដោយគេវាយកញ្ចឹងក រួចគេអារក ហើយគេវះពោះបន្តទៀត បានបោះចូលក្នុងរណ្តៅ។ នៅពេលដែលវាយកញ្ចឹងក និងអារករួចហើយ ចាំបាច់ -- ហេតុអីបានចាំបាច់ត្រូវវះពោះបន្តទៀត ទៅលើអ្នកទោស?

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ប្រាប់ថា តាហ៊ី, តាឌុច ហ្នឹងឲ្យថាវ៉ៃហើយ ឲ្យអារក អាករហើយបានវះពោះ។ បើកាលណាមិនវះពោះ គឺហើមមួយរបើករណ្តៅហ្នឹងតែម្តង អ៊ីចឹងស្អុយគេដឹង។

**ស៖** បាទ អ៊ីចឹង បាទ អ៊ីចឹងអរគុណ។ ខ្ញុំសួរសំណួរមួយទៀត ថាតើនៅជើងឯកហ្នឹងលោកមានបានដឹងទេថា នៅពេលដែលបញ្ជូនមនុស្សចេញពីស-២១ទៅ មានករណីណាដែលថាគេមានទារកគេបញ្ជូនទៅជាមួយទេ ហើយសម្លាប់នៅជើងឯក លោកមានដឹងទេ?

[១៤:១៦:១០]

**ឆ៖** បាទ ពេលដែលខ្ញុំបញ្ជូនទៅ គឺខ្ញុំអត់មានបានយកទាំងកុមារទាំងអីទៅទេ តែខុសពីខ្ញុំដឹងតែយកពីកន្លែងណា ហើយយកចេញពីស-២១ ក៏មិនដឹងដែរ ព្រោះខ្ញុំអត់ទៅ។ ការងារដែលគេទៅ គឺដូចប៉េង, ដូច ផល ហ្នឹង គេចាត់ឲ្យទៅ ក៏ខ្ញុំអត់ដឹង។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សួរបញ្ជាក់ថែមបន្តិចទៀតដែរអំពីបញ្ហានៅជើងឯកហ្នឹង។ លោកបាននិយាយអំពីបែបបទនៅក្នុងការកត់ត្រាឈ្មោះអ្នកទោសដែលត្រូវយកទៅសម្លាប់នៅជើងឯក។ លោកអាចបញ្ជាក់បានទេ ការកត់ត្រាហ្នឹង គឺកត់ត្រានៅពេលដែលបញ្ចេញមនុស្សយកចេញពីផ្ទះឈើដើម្បីយកដើរតម្រង់ទៅរណ្តៅ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ពេលយកអ្នកទោសចេញពីផ្ទះហ្នឹងទៅ គឺសំដៅទៅកន្លែងគាត់នៅក្បែរភ្លើងមានកៅអីមួយអង្គុយនឹងដី ហើយកត់ក្រដាសហ្នឹង។ កត់ឈ្មោះហើយ បានគេយករណ្តៅបណ្តោយ។

**ស៖** បាទ អ៊ីចឹងភ្លើង អំពូលភ្លើងដែលលោកមានប្រសាសន៍អម្បាញ់មិញ វានៅឆ្ងាយពីផ្ទះហ្នឹងទេ?

**ឆ៖** បាទ គឺនៅឆ្ងាយពីផ្ទះ។

**ស៖** បាទ អរគុណ។ ហើយការកត់ត្រាបែបនេះ គឺលោកមានបញ្ជីឈ្មោះហើយស្រេច ហើយគ្រាន់តែគូសជិតឈ្មោះនោះ ឬក៏លោកសរសេរឈ្មោះរបស់អ្នកទោសសាជាថ្មី?

[១៤:១៨:១៨]

**ឆ៖** បាទ ដូចខ្ញុំបញ្ជាក់ថ្ងៃមិញហើយ គឺខ្ញុំកត់ឈ្មោះ ហើយនិងចុះលេខ, លេខ១ លេខ២ លេខ

៣ រៀងរហូត។

**ស៖** ចុះលោកមានបានផ្ទៀងផ្ទាត់ជាមួយបញ្ជីបញ្ជូនមកពីទួលស្លែងដែរឬទេ?

**ឆ៖** បាទ ឈ្មោះដែលចេញពីមន្ទីរទួលស្លែងមកហ្នឹង គឺឈ្មោះនៅលើ បងធី ណោះ ហើយគាត់ឱ្យខ្ញុំមកកត់ឈ្មោះនេះម្ដងទៀត ដើម្បីគាត់យកទៅទូរជាមួយគ្នា។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹង ជាទូទៅគឺការងារហ្នឹង គឺការកត់ឈ្មោះហ្នឹង គឺធ្វើយ៉ាងអ៊ីចឹងមែនទេ វាមានន័យថា នៅពេលដែលបញ្ជូនមនុស្សចេញពីផ្ទះឈើហើយ ហើយលោកកត់ឈ្មោះហើយលោកក៏ត្រឡប់មកស-២១វិញ អ៊ីចឹងគ្រប់ពេលគឺការកត់ឈ្មោះ គឺកត់ឈ្មោះមនុស្សពេលចេញពីផ្ទះឈើបាទអ៊ីចឹងមែនទេ?

**ឆ៖** បាទ គឺកត់ឈ្មោះហើយ គេបញ្ជូនយកទៅសម្លាប់ទៅ ហើយអស់ ខ្ញុំយកឈ្មោះហ្នឹងឡើងឡាន។ ដល់ឡាន អ៎! ដល់ទួលស្លែងវិញ គឺយកឈ្មោះហ្នឹងទៅឱ្យបង សួស ធី ហ្នឹង។

**ស៖** អ៊ីចឹង តើលោកមានបានផ្ទៀតផ្ទាត់ថែមទៀតថា មនុស្សដែលបានសម្លាប់នៅរណ្ដៅហ្នឹងគាត់បានស្លាប់ហើយដែរឬទេ ទាំងអស់គ្នាបានស្លាប់ហើយដែរឬទេ? តើលោកមានបានធ្វើយ៉ាងដូច្នេះទេ?

**ឆ៖** ខ្ញុំអត់មានបាននិយាយទេ គ្រាន់ថា បានឈ្មោះយកទៅឱ្យគាត់ទៅ ខ្ញុំមកកន្លែងខ្ញុំវិញមក។

[១៤:២០:០៩]

**ស៖** ខ្ញុំនៅសល់សំណួរចុងក្រោយ ហើយបន្ទាប់មកសហការីខ្ញុំនឹងសួរបន្តពីលោក។ នៅពេលដែលលោកធ្វើការនៅស-២១ ហើយការងារជាច្រើនដែលលោកបានធ្វើក្នុងក្របខ័ណ្ឌឆ្នាំ៧៦ រហូតដល់ ៧៩ ថាតើលោកមានអារម្មណ៍យ៉ាងណា ឬក៏មានវិប្បដិសារីយ៉ាងណាដែរចំពោះការងាររបស់លោក? ថាតើលោកមានដែរឬទេ? លោកអាចបញ្ជាក់អំពីបញ្ហានេះបានទេ ដើម្បីឱ្យអ្នកផ្សេងទៀត គេអាចឮអំពីសកម្មភាពរបស់លោក -- អារម្មណ៍របស់លោកដែរ?

**ឆ៖** បាទ ខ្ញុំសុំជម្រាបថា ពេលដែលខ្ញុំធ្វើការនៅស-២១ហ្នឹង ដូច សុន សេន គាត់មកប្រជុំរៀនសូត្រពួកខ្ញុំហ្នឹង នឹកឃើញថា បើខ្ញុំនៅគុកនេះ ជៀសមិនផុតពីរឿងគេចាប់ដាក់គុកសម្លាប់ចោល ព្រោះពីមុនមកខ្ញុំឱ្យ -- ខ្ញុំរត់បីដង រៀនសាលាសេរី ពីរដង។ ក្រោយមកទៀត ៧៥១រំដោះភ្នំពេញហ្នឹង ថ្ងៃ ១៦ ឱ្យស័ក្តិ៥ រួចខ្លួន។ មួយទៀតថ្ងៃ១៧ មេសា ថ្ងៃចប់ ឱ្យកាំភ្លើងខាង លន់ នល់ បាទ។ ដល់អ៊ីចឹងគេយកមកចូលកន្លែងស-២១គឺភ័យខ្លួន តែបែកការណ៍គឺត្រូវគេចាប់ខ្លួនខ្ញុំ។ ព្រោះអារម្មណ៍ហ្នឹងហើយ បាន

ខ្ញុំសុំ សុន សេន ទៅទ័ពវិញហ្នឹង សុខចិត្តងាប់ម្នាក់ឯងកុំឱ្យជាប់ជាខ្សែសង្វាក់គ្រួសាររបស់ខ្ញុំ។ បាទ ក្រោយមកទៀត អស់ជម្រើស១ មានផែនការមួយចង់គាស់គុកប្រមូលកម្លាំងអ្នកពាក់ព័ន្ធ។ ទទួលថ្ងៃមួយ គឺបែកការណ៍ត្រឹម ណុប នួន ចាប់ ណុប នួន ទៅ។ ណុប នួន ឆ្លើយដាក់ខ្ញុំថា ខ្ញុំរៀបចំផែនការគាស់គុក។ តាឌុច ដឹងខ្ញុំ ក៏ តាឌុច ពេលរៀនសូត្រ ហៅខ្ញុំសួរ។ មិត្តហ៊ុយឯង, ណុប នួន ឆ្លើយដាក់ មិត្តហ៊ុយ ឯង។ ហ៊ុយ ឯងប្រុងរៀបចំនូវការបះបោរ។ ខ្ញុំសើចដាក់គាត់ ខ្ញុំថា ខ្ញុំណាធ្វើអីចឹងបង។ ណុប នួន ឆ្លើយផ្តេសផ្តាសតើ។ ខ្ញុំឯណាទៅដឹងអ៊ីចឹង។ ប៉ុន្តែពីមុនមកគឺខ្ញុំ ៣ថ្ងៃឃ្លាំងកាំភ្លើងហ្នឹងនៅលើ តាហ៊ីកាន់កាប់។ ខ្ញុំសុំកូនសោពីនីរសារ តាហ៊ី ចូលមើលកាំភ្លើង ពីរថ្ងៃបីថ្ងៃបួនថ្ងៃ ចូលមើលកាំភ្លើង។ ដល់ តាឌុច ដឹងខ្ញុំអ៊ីចឹង ក៏ឱ្យនីរសារគេ យកឡានដឹកកាំភ្លើងហ្នឹងចេញពីឃ្លាំងអស់ ទៅសេនាធិការ។ ចុងក្រោយបំផុត គឺខ្ញុំទៅធ្វើស្រែ នៅខាងត្បូងជើងឯកហ្នឹង រហូតដល់បែក៧៩ហ្នឹង។ គេកែនខ្ញុំឱ្យទៅព្រៃទៅព្រៃក្រោយមក ខ្ញុំបានអារុធបានអី ក៏ខ្ញុំនាំកម្លាំងរត់គេចពីពួក តាឌុច ហ្នឹងទៀត។ រហូតមកផ្ទះសម្បែង មកគ្នាជិត២០នាក់ គឺស្លាប់តាមផ្លូវ។ ដល់យូរៗទៅ នៅខ្ញុំតែម្នាក់ឯង គេមកផុតអស់រលីង ខ្ញុំឈឺ បានប្រជាជនយកខ្ញុំមករហូត បានរស់ទាល់សព្វថ្ងៃនេះ។

[១៤:២៣:១២]

**ស៖** បាទ ចុះដែលថាលោកទៅជញ្ជូនមនុស្សពីតាមខេត្តផ្សេងៗ ឬក៏លោកបញ្ជូនមនុស្សពីទួលស្លែង យកទៅជើងឯក ដើម្បីឱ្យគេសម្លាប់ហ្នឹង ថាតើអារម្មណ៍របស់លោកហ្នឹង មានយ៉ាងដូចម្តេចដែរ ដែលថា មានមនុស្សរងគ្រោះដោយសារទួលស្លែងហ្នឹង ហើយលោកធ្វើការនៅទួលស្លែងហ្នឹងដែរ ថាលោកមានអារម្មណ៍យ៉ាងណាដែរ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណី ដូចជាតាំងសំណួរហ្នឹង មិនសមស្របទេ គាត់ជាសាក្សី។ អង្គហេតុដែលគាត់ដឹងហ្នឹង គឺឆ្លុះបញ្ចាំងពីរឿងពិតដែលអង្គជំនុំជម្រះអាចយកធ្វើជាភ័ស្តុតាងបាន។ សំណួរពីអារម្មណ៍ដូច្នេះ គឺមិនមែនគោលដៅដែលត្រូវសួរទេ។ សំណួរនេះសមស្រប គឺសួរជនជាប់ចោទទេ។ នៅពេលជនជាប់ចោទសារភាពដែលជាស្ថានសម្រាលទោល ដល់ក្នុងការពិចារណាសម្រេចអំពីទោស។ ហើយសំណួរខ្លះគឺជាជនរងគ្រោះទេ ព្រោះគាត់ជាជនរងគ្រោះ ទើបអាចសួរបាន។ ដូច្នេះសាក្សីមិនបាច់ឆ្លើយតបនឹងសំណួរនេះទេ។ ហើយសុំលោកកំហិតសំណួររបស់លោក ដែនកំណត់ត្រឹមតែប្រភេទសំណួរទាំងឡាយដែលអាចប្រើប្រាស់ ចំពោះមុខ ឧទាហរណ៍ចំពោះសាក្សីបានហើយ ជៀសវាងច្របូក

ច្របល់រវាងសំណួរមិនច្បាស់លាស់ដែលត្រូវសួរទៅរបៀបជាគោលដៅនៃដើមបណ្តឹងរដ្ឋប្បវេណី ឬក៏ជនជាប់ចោទ បែរជាសំណួរទៅសាក្សីនោះ។

[១៤:២៤:៤០]

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំអស់សំណួរហើយ សុំផ្ទេរវេទិកាជូនសហការីរបស់ខ្ញុំ លោកស្រី ម៉ារី ហ្គីរ៉ូដ៍។ សុំលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ជម្រាបសួរលោកសាក្សី <ខ្ញុំ>ឈ្មោះ ម៉ារី ហ្គីរ៉ូដ៍។ ខ្ញុំជាមួយលោក ពេជ អង្គ តំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរលោកនៅរសៀលនេះ។ កាលពី<ព្រឹក>មិញហ្នឹងលោកបានឆ្លើយជូនសហព្រះរាជអាជ្ញាថា លោកទៅស្វាយរៀងពីរដង ដើម្បីទៅយកអ្នកទោស។ លោកមានបញ្ហាជាមួយនឹងកាសស្តាប់របស់លោក ឬក៏យ៉ាងម៉េចលោកសាក្សី?

លោកសាក្សី លោកស្តាប់ខ្ញុំឮទេ? ខ្ញុំសូមសួរសំណួរឡើងវិញ កាលពីព្រឹកមិញនេះលោកឆ្លើយថា លោកបានទៅស្វាយរៀងពីរដង ដើម្បីទៅយកជនជាតិវៀតណាមមកស-២១។ ដូច្នេះខ្ញុំចង់ដឹងថា ពេលដែលលោកទៅពីរដងហ្នឹង អ្នកដែលលោកយកមកហ្នឹងសុទ្ធតែជាយោធា ឬក៏មានជនស៊ីវិលដែរក្នុងចំណោមជនជាតិវៀតណាមដែលលោកនាំយកមកស-២១ នេះ?

**លោក ហ៊ឹម ហ៊ុយ៖**

**ឆ៖** បាទ ខ្ញុំអត់ដឹងថា អ្នកណាទាហានណាអីទេ ប៉ុន្តែគេថាគេចាប់បានទាហានវៀតណាមប្រាំនាក់ គេឱ្យយកឡានទៅយកហ្នឹង។

[១៤:២៧:១៩]

**ស៖** លោកអាចរៀបរាប់ឱ្យបានលម្អិតបន្តិច អំពីពេលដែលលោកទៅយក<អ្នកទោស>នៅស្វាយរៀងហ្នឹង<បានទេ?> តើលោកទៅយកនៅកន្លែងណាឱ្យប្រាកដ? <តើពួក>គេ<>នៅកន្លែង

ណា? <តើអ្នកទាំងនោះត្រូវបានគេចាប់ឃុំខ្លួនហើយមែនទេ? តើធ្វើម៉េចទើបលោកដឹងថា ពួកគេជាទាហាន ឬមិនមែនទាហាននោះ?> តើលោកចាំយ៉ាងម៉េចខ្លះអំពីការធ្វើដំណើរទាំងពីរលើក<ទៅខេត្តស្វាយរៀង>ដែលទៅយកជនជាតិវៀតណាមមក ស-២១ នេះ?

**ឆ៖** បាទ គឺទៅយកនៅខាងត្បូងសាលាខេត្ត កន្លែងនោះដូចជាសាលារៀននៅខាងត្បូងសាលាខេត្តហ្នឹង គឺគេនៅឃាមហ្នឹង គេចងជាប់នៅកន្លែងគេហ្នឹង ហើយនិងដាក់ខ្នោះផងអីផងនៅហ្នឹង។ ដល់ពួកខ្ញុំទៅ ក៏ពួកខ្ញុំដូរដាក់ខ្នោះពួកខ្ញុំមក ក៏លើកដាក់ឡានយកមកបណ្ដោយ។

**ស៖** តើអ្នកទាំងអស់ហ្នឹងមានពាក់ឯកសណ្ឋានទេ? <តើធ្វើម៉េចទើប>លោកអាចបែងចែកថាជាជនស៊ីវិល ឬក៏ទាហាននោះ?

**ឆ៖** បាទ គឺមានឯកសណ្ឋានខោអាវទាហាន ហើយមួកកូប។

**ស៖** ក្រោយពីលោកនាំអ្នកទោសមកដល់ស-២១ តើគេមានបែបបទអីខុសគ្នាទេចំពោះអ្នកទោសជាជនជាតិវៀតណាម និងអ្នកទោសផ្សេងទៀតនោះ? លោកនៅចងចាំទេថា គេធ្វើយ៉ាងម៉េចខ្លះពេលលោកនាំអ្នកទោសវៀតណាមទាំងអស់នុ៎ងមកដល់ស-២១ ហើយនោះ?

**ឆ៖** បាទ គឺខ្ញុំបញ្ជូនមកដល់បន្ទប់គេហ្នឹងគឺកន្លែង បងធី ហ្នឹងគឺខ្ញុំប្រគល់ឲ្យគេហ្នឹងទៅ ហើយខ្ញុំចេញទៅកន្លែងខ្ញុំវិញសិន រឿងធ្វើម៉េចទៀតក៏ខ្ញុំអត់ដឹងដែរ។

[១៤:២៩:៣៣]

**ស៖** សាក្សីពីររូបបានមកផ្ដល់សក្ខីកម្មនៅក្នុងសវនាការនេះ ដែលគាត់និយាយអំពី<ភាពយន្តដែលប្រហែលជាថតពី>អ្នកទោសទាហានវៀតណាមដែលមកដល់ស-២១។ ឧទាហរណ៍ដូចជាប្រាក់ ខន នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ នៅម៉ោង០៣:៥៦ គាត់បាននិយាយអំពីហេតុការណ៍បែបនេះ គឺទាហានវៀតណាមត្រូវបានគេដាក់នៅមុខអគារ "ក", "ខ" ហើយគេថត<ជាខ្សែភាពយន្ត>។ ហើយ ឡាច មាន ហ្នឹងក៏បាននិយាយដែរនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ គឺនៅម៉ោង១០:៤៩នាទី គាត់ក៏និយាយផងដែរថា អ្នកទោសដែលនាំមកស-២១ហ្នឹងត្រូវបានគេថត<ជាខ្សែភាពយន្ត> ហើយក្រោយមកគេចាក់បង្ហាញនៅក្នុងវគ្គរៀនសូត្ររបស់បុគ្គលិកស-២១។ តើលោកចាំទេ<អំពីរឿងនេះ? តើលោកនៅចាំរឿងអីទេ ទាក់ទងនឹងខ្សែភាពយន្ត ដែលនិយាយអំពីការមកដល់ និងចម្លើយសារភាពរបស់>អ្នកទោស<វៀតណាមនៅ ស-២១នោះ>?

**ឆ៖** បាទជាការត្រឹមត្រូវហើយ ខ្ញុំនឹកឃើញ ព្រោះចាប់មកដល់ហើយ គេឲ្យឈរទាំងជួរអីចឹង

គេថតទៅ បាទ។ ថត ហើយគេថតជាកុន គេបញ្ចាំងកុនឲ្យអ្នកនៅស-២១ហ្នឹងមើល មានអ្នកខ្លះពាក់ផ្កាយ មានអ្នកខ្លះស័ក្តិ បាទ អ្នកខ្លះអត់មានស័ក្តិទេ មានតែខោអាវ ហើយនិងមួកកូបអីហ្នឹងពាក់។

**ស៖** តើលោកចាំអ្វីខ្លះអំពីកុននេះ? តើ<មានតែការថត>កុន<នៃការមកដល់របស់>អ្នកទោសវៀតណាម<> ឬ<ក៏លោកបានទទួល>ព័ត៌មានអីផ្សេងទៀតនៅក្នុង<អំឡុងពេលវគ្គរៀនសូត្រនោះ>?

**ឆ៖** បាទ កុននេះ គឺពេលដែលគេថតរឿងហ្នឹងហើយ ដល់ពេលគេសួរចម្លើយ សួរអីក៏ខ្ញុំអត់ដឹងដែរ ប៉ុន្តែដល់ពេលសម្លាប់ ក៏គេថតអាហ្នឹងយកមករួមគ្នាបញ្ចាំងមើលទៀត បាទ។

**ស៖** ដូច្នេះកុននេះបង្ហាញពីការមកដល់<របស់>អ្នកទោស ការសួរចម្លើយអ្នកទោស ហើយនិងមានបង្ហាញអំពីការសម្លាប់អ្នកទោសផងដែរ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ គឺអ៊ីចឹងមែន។

[១៤:៣២:៣៧]

**ស៖** តើកុននេះ គេថតតែរូបអ្នកទោសវៀតណាមហ្នឹង ឬក៏<លោកបានឃើញកុនផ្សេងទៀតពាក់ព័ន្ធនឹងការមកដល់ ការ>សួរចម្លើយ <និងការសម្លាប់>អ្នកទោសផ្សេងទៀត<នៅស-២១>ដែលមិនមែនជា<ទាហាន>ជនជាតិវៀតណាម?

**ឆ៖** បាទ ខ្ញុំអត់ចាំទេ។ ចាំតែឃើញថា គេថត ពេលយកមកហ្នឹងឲ្យពាក់មួកកូប មួកអី ណាមានផ្កាយពាក់ផ្កាយ ណាស័ក្តិពាក់ស័ក្តិ ណាខោអាវធម្មតាៗ ពាក់មួកកូបហ្នឹង ហើយគេថត។ ដល់ពេលសួរចម្លើយ ក៏ខ្ញុំអត់បានដឹងដែរ ដឹងតែពេលគេសម្លាប់ ក៏គេថតយកមករួមគ្នាទាំងអស់ មកបញ្ចាំងមើលហ្នឹងបាទ។

**ស៖** លោកចាំថាតើអ្នកទោសវៀតណាមទាំងអស់នេះ ត្រូវបានសម្លាប់នៅកន្លែងណាទេ? នៅស-២១ ឬក៏នៅជើងឯក? លោកនៅនឹកឃើញទេ?

**ឆ៖** បាទអត់មាននៅជើងឯកទេ អ្នកទោសហ្នឹងគឺស្លាប់នៅកន្លែងទួលស្លែងហ្នឹងទាំងអស់។

**ស៖** សូមអរគុណ។ ខ្ញុំនៅសល់៥នាទីទៀត ដូច្នេះខ្ញុំសួរសំណួរខ្លីៗមួយចំនួនតូចទៀត។ នៅសម័យនោះ ពេលដែលលោកបំពេញការងារនៅស-២១ តើលោកធ្លាប់ឮគេនិយាយអំពីបញ្ហាខុសសីលធម៌ទេ? តើគេមានប្រើពាក្យ “ខុសសីលធម៌” នេះនៅស-២១ ទេ?

**ឆ៖** បាទ មានអ្នកយាមម្នាក់ក្មេង បានរំលោភអ្នកទោសស្ត្រីម្នាក់។ ពេលនោះវាខូចសីលធម៌ជាមួយអ្នកទោស ក៏គេចាប់ខ្លួនដាក់គុកសម្លាប់ចោលដែរ។

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** លោកចាំឈ្មោះអ្នកយាម<វ័យក្មេង>ហ្នឹងទេ?

[១៤:៣៤:០៩]

**ឆ៖** បាទ ខ្ញុំមិនសូវស្គាល់ឈ្មោះគេទេ អ្នកនៅខាងក្នុងបាទ ពីព្រោះការគ្រប់គ្រងរបស់ ប៉េង។

**ស៖** តើលោកដឹងហេតុការណ៍ហ្នឹងដោយរបៀបណា? លោកឃើញដោយខ្លួនឯងផ្ទាល់ភ្នែក ឬក៏មិត្តភក្តិណាម្នាក់របស់លោកនិយាយរឿងនេះប្រាប់លោក? ម៉េចបានជាលោកដឹងថា អ្នកយាម<វ័យ>ក្មេងហ្នឹងបានរំលោភអ្នកទោសស្រី?

**ឆ៖** បាទ អ្នកយាមនៅក្នុងហ្នឹងឯងនិយាយប្រាប់ ឬមួយក៏ ប៉េង ក៏មិនដឹង ព្រោះខ្ញុំភ្លេចដែរ ព្រោះខ្ញុំនៅខាងក្រៅ គេថាអ្នកយាមរំលោភអ្នកទោស អាហ្នឹងត្រូវតែមានទោសខ្លួនឯង ហើយក៏ចាប់ដាក់គុកដែរទៅ។

**ស៖** ក្រៅពីហេតុការណ៍នេះ តើលោកធ្លាប់ឮអំពីហេតុការណ៍ណាផ្សេងស្រដៀងគ្នានេះទៀតដែរឬទេ<ពេលដែលលោកធ្វើការនៅស-២១នោះ>? មានអ្នកយាមណាផ្សេងទៀតបានប្រព្រឹត្តខុសសីលធម៌ក្នុងលក្ខណៈដូចគ្នានេះដែរឬទេ ហើយត្រូវបានគេដាក់ទណ្ឌកម្មទេ?

**ឆ៖** បាទ គឺខ្ញុំអត់ដឹងដែរ។ ដឹងតែរឿងមួយគឺ អ្នកធ្វើការនៅស-២១ហ្នឹង ដល់គេចាប់ដាក់គុក ហើយដល់ពេលនេះគាត់ គេចាក់សោ គេភ្លេចចាក់សោគាត់រត់រួចទៅ។ ហើយអ្នកយាមក៏មិនដឹងយ៉ាងម៉េចដែរ ព្រោះខ្ញុំភ្លេចដែរហើយ ដឹងគេចាប់ខ្លួនដែរអត់។ បាទ គាត់រត់ទៅដល់វៀតណាម។ ដល់ក្រោយមកទៀតគាត់បែក៧៩ គាត់ចូលធ្វើប៉ូលិសនៅខេត្តកណ្ដាល ប៉ុន្តែបច្ចុប្បន្ននេះថាគាត់ស្លាប់ហើយ។

**ស៖** លោកប្រធាន សូមអនុញ្ញាតឱ្យខ្ញុំសួរសំណួរចុងក្រោយ។ តើហេតុអ្វីបានជាអ្នកយាមនេះត្រូវបានចាប់ដាក់គុក? ខ្ញុំ<សន្មតថា វាជាប់ពាក់ព័ន្ធនឹងបញ្ហាសីលធម៌ ប៉ុន្តែតើខ្ញុំធ្វើសេចក្ដីសន្និដ្ឋានខុសទេដឹង? តើបុគ្គលនោះ>ត្រូវបានគេដាក់ឃុំហ្នឹង ដោយសារតែគាត់បានប្រព្រឹត្តខុសសីលធម៌ហ្នឹងមែនទេ?

[១៤:៣៨:០១]

**ឆ៖** បាទ មួយដែលគេចាប់ដាក់គុក ដោយសារសីលធម៌ជាមួយអ្នកទោស។ ហើយមួយទៀតមិនដឹងគេចាប់ដែរអត់ទេ ព្រោះអ្នកធ្វើការហ្នឹងគេចាប់ដាក់គុកហើយឱ្យរត់រួច អ្នកយាមហ្នឹងក៏មិនយ៉ាងម៉េចដែរ ព្រោះខ្ញុំវាភ្លេចដែរហើយ។ ហើយអ្នកយាមក្មេងដែលរំលោភនារីហ្នឹង គឺក៏មិនបានរស់ដែរ គឺត្រូវជាប់គុកហើយ គេត្រូវសម្លាប់ចោលហើយ គេមិនឱ្យអ្នកណាមានគំរូតទៅទៀតទេ។

**ស៖** តើលោកស្គាល់ឈ្មោះ ឬក៏មានព័ត៌មានអ្វីពាក់ព័ន្ធទៅនឹង<ជនរងគ្រោះ>ដែលត្រូវបានគេ <សម្លាប់>ហ្នឹងទេ?

**ឆ៖** បាទ គឺខ្ញុំអត់ស្គាល់អត់អីទេ។ បាទ តែបញ្ជូនឲ្យគេ ខ្ញុំដឹងតែបញ្ជូនឲ្យគេទៅ អ្នកណា ឈ្មោះអីៗ ក៏ខ្ញុំអត់ដឹងដែរ ព្រោះខ្ញុំអត់មានទៅកាន់កាប់នៅកន្លែងហ្នឹង នៅខាងក្រៅ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកប្រធាន ខ្ញុំគិតថាខ្ញុំអស់ពេលទៅហើយ។ សូមអរគុណលោកប្រធាន។ សូមអរគុណលោក សាក្សីដែលបានឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេល នេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់ សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់ កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤០ នាទី ដល់ម៉ោង ១៥:០០ នាទី)*

[១៥:០០:០៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

សូមអញ្ជើញលោកស្រីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមធ្វើការកត់សម្គាល់ខ្លីមួយ ព្រោះថាប្រហែលជាមានបញ្ហាបក ប្រែជាភាសាអង់គ្លេស និងជាភាសាបារាំង ទាក់ទងទៅនឹងចម្លើយចុងក្រោយរបស់លោកសាក្សី។ ខ្ញុំគិត ថាជាការសំខាន់ក្នុងការស្វែងរកការពិត <ដែលសាក្សីអាច>ប្រាប់ឈ្មោះអ្នកយាមចុងក្រោយដែលគាត់ បាននិយាយអម្បាញ់មិញនេះ ដែលគាត់ហ្នឹងទំនងជារត់ទៅវៀតណាម ហើយត្រឡប់មកប្រទេសខ្មែរ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

វិញ ពីព្រោះថានៅក្នុងការបកប្រែនោះមិនសូវច្បាស់។ អ៊ីចឹងខ្ញុំសូមឲ្យគាត់ផ្តល់ឈ្មោះអ្នកយាមដែលគាត់និយាយអម្បាញ់មិញ ដែលបានរត់ទៅវៀតណាមហើយ ហើយគាត់ទើបនឹងស្លាប់ថ្មីៗនេះហើយដែរទេ អ្នកយាមហ្នឹងនោះ។ <តើ>លោកប្រធានអនុញ្ញាតឲ្យខ្ញុំចោទសំណួរនេះទៅគាត់ <ឬក៏សួរ>តាមរយៈលោកប្រធាន<?>

[១៥:០១:៣១]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ហើយសាក្សីឆ្លើយតបនឹងសំណួរនេះ បើសិនជាលោកចាំ តើលោកស្គាល់ឈ្មោះអ្នកយាមដែលថាមានបញ្ហា ហើយរត់ទៅគេចខ្លួនទៅវៀតណាម ហើយត្រឡប់មក ក្រោយមកត្រឡប់មកវិញមកធ្វើនគរបាលខេត្តកណ្តាល ហើយក្រោយមកទទួលមរណភាពហើយទៅនោះ តើគាត់ឈ្មោះអី?

**លោក ហ៊ឹម ហ៊ុយ៖**

**ឆ៖** បាទ គាត់ឈ្មោះ បងចយ។ គាត់ជាអ្នកការពារនៅស-២១ហ្នឹង ខាងផ្នែកការពារ។ ហើយគាត់បានរត់រួចពីគុកហ្នឹងទៅ គាត់ទៅដល់វៀតណាម គាត់ចេញពីវៀតណាមមកវិញ បែក៧៩ គាត់ធ្វើប៉ូលិសនៅខេត្តកណ្តាល។ សព្វថ្ងៃនេះគឺគាត់ស្លាប់ហើយ។ តែខ្ញុំអត់ដែលបានជួបគ្នារហូតតាំងពីមក គឺសោម ម៉េត ប្រាប់ខ្ញុំ។ ម៉េត គេបានជួបគ្នាជាមួយគាត់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយមុននឹងផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីមានឱកាសសួរដេញដោលសាក្សីរូបនេះ លោកចៅក្រម ហ្វ្រង់ម៉ាក ទំនងជាមានសំណួរមួយចំនួនចង់សួរសាក្សីរូបនេះ។ សូមអញ្ជើញលោកចៅក្រម ហ្វ្រង់ម៉ាក ឡាវែន៍!

[១៥:០២:៥៥]

**ចៅក្រម ហ្វ្រង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ហ្វ្រង់ម៉ាក ឡាវែន៍៖**

**ស៖** លោកសាក្សី ខ្ញុំមានសំណួរមួយចំនួនសួរបន្តទៅលោក។ ជាបឋមខ្ញុំសូមត្រឡប់មកនិយាយអំពីភាពយន្តដែលលោកបាននិយាយកាលពីរសៀលនេះៗ។ ពីភាពយន្ត ខ្មែរភាពយន្តថតជនជាតិ

វៀតណាមដែលបានមកដល់មន្ទីរស-២១។ លោកនិយាយថា ក្នុងខ្សែភាពយន្តនោះវាជាការសង្ខេប គឺថតពេលដែលជនជាតិវៀតណាមចូលមក ហើយពេលសួរចម្លើយ<ពួកគេ> ហើយក្រោយមកថតពេលសម្លាប់ពួកគាត់ដែរ។ តើលោកនៅចាំដែរឬទេ ថាតើនៅក្នុងខ្សែភាពយន្តនោះ គេប្រើវិធីសាស្ត្រសួរចម្លើយអ្វីខ្លះទៅលើពួកគាត់? តើគេមានប្រើទារុណកម្មដែរឬទេ? ហើយគេមានថតពេលគេធ្វើទារុណ-កម្មជនជាតិវៀតណាមទាំងអស់នុ៎ងដែរឬទេ?

**លោក ហ៊ឹម ហ៊ុយ៖**

**ឆ៖** បាទ ជាការពិតហើយគឺអ្នកដែលចាប់យកមក ទាហានវៀតណាមហ្នឹងគឺគេធ្វើទារុណកម្ម បាទ ឃើញឈាមខ្លួនឈាមអី។ ហើយការថតហ្នឹង មានតែពួក អេន ហើយដែលអ្នកថត។ អីៗទៀត ក៏ខ្ញុំអត់បានដឹងដែរ។

**ស៖** តើលោកចង់និយាយថា នៅក្នុងខ្សែភាពយន្តហ្នឹង យើងឃើញអ្នកសួរចម្លើយកំពុងតែធ្វើទារុណកម្ម ឬក៏លោកចង់និយាយថានៅក្នុងខ្សែភាពយន្តហ្នឹង យើងឃើញអ្នកទោសជនជាតិវៀតណាមដែលមានស្នាមប្រឡាក់ឈាម<នៅលើខោអាវពួកគេ និងមានរបួស>ដោយសារគេវាយ<>អីជាដើមនោះ? តើលោកចង់និយាយអ្វីទៅឲ្យពិតប្រាកដ?

[១៥:០៤:៥២]

**ឆ៖** បាទ ខ្ញុំឃើញគេបណ្ដើរដែលពេលដែលខ្ញុំចូលទៅកន្លែង បងធី អ៊ីចឹង បណ្ដើរអ្នកទោសយកទៅ ចូលអ៊ីចឹងទៅ ឃើញគេបណ្ដើរជនជាតិវៀតណាមហ្នឹង យកទៅសួរចម្លើយ ឃើញរបួសស្នាមខ្នង ស្នាមអីហ្នឹង។ ត្រង់ថាកន្លែងសួរកន្លែងអី គឺខ្ញុំអត់បាន អត់មានសិទ្ធិអីទៅដល់កន្លែងគេទេ ឃើញតែតាមផ្លូវ កន្លែងខ្លោងទ្វារ កន្លែងមុខគុកហ្នឹង។

**ស៖** ខ្ញុំសូមត្រឡប់មកនិយាយអំពីខ្សែភាពយន្តហ្នឹងតែម្ដង លោកនិយាយថា គេបានបញ្ចាំងខ្សែភាពយន្តហ្នឹង ពេលវគ្គរៀនសូត្រ។ នៅលើរូបភាពនៃខ្សែភាពយន្តហ្នឹង តើគេឃើញអ្នកទោសកំពុងត្រូវបានគេធ្វើទារុណកម្មដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់បានចាប់អារម្មណ៍ទេ តែឃើញថតទាំងខ្សែៗឲ្យដើរឲ្យអីហ្នឹង ហើយឃើញរូបភាពគេសម្លាប់វះពោះ វះអីហ្នឹង អាហ្នឹងឃើញ។ ត្រង់អាកន្លែងទារុណកម្ម គឺខ្ញុំអត់បានពិនិត្យមើលដែរភ្លេច។

**ស៖** តើលោកចង់និយាយថា នៅក្នុងខ្សែភាពយន្តនោះ យើងឃើញការសម្លាប់អ្នកទោសទាំង

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អស់នោះដែរ? តើនៅក្នុងខ្សែភាពយន្តនោះ យើងឃើញគេវះពោះអ្នកទោសហ្នឹងដែរ ឬក៏<ជាអ្វីដែល> លោកឃើញ<>នៅក្រៅខ្សែភាពយន្តទេ?

[១៥:០៦:៤៣]

**ផ៖** បាទ ឃើញនៅក្នុងខ្សែភាពយន្តហ្នឹង។ គឺពួក អេន អ្នកថតយកមក ជាខ្សែមក គេយកកុនយកអីមករៀបចំបញ្ចាំងឱ្យមើលហ្នឹង។ ពេលដែលថតហើយអស់ សម្រេចដល់ពេលចប់សួរចម្លើយហើយនិងយកទៅសម្លាប់ហ្នឹង គេនឹងចាប់ផ្ដើមយកឯកសារហ្នឹងមកបញ្ចាំងឱ្យមើល។

**ស៖** នៅពេលដែលគេបញ្ចាំងកុនហ្នឹង លោកនិយាយថា គេបញ្ចាំងនៅវគ្គរៀនសូត្រ តើកាលនោះ គេអត្ថាធិប្បាយយ៉ាងម៉េចដែរអំពីខ្សែភាពយន្តហ្នឹង? <តើមាននរណាបញ្ចេញមតិយោបល់អីចំពោះកុនហ្នឹងទេ?> ហើយអ្នកណាខ្លះមានវត្តមាននៅពេលដែលគេបញ្ចាំងកុនហ្នឹង?

**ផ៖** បាទ គឺទាំងអស់គ្នានៅមើលហ្នឹង កន្លែងមុខគុកហ្នឹង។ គេដាក់តាវាងគេប៉ុនណាណើបញ្ចាំងឱ្យមើល តែរឿងចេញសំឡេង ដូចមិនឮសួរចេញសំឡេងអីទេ គ្រាន់តែមើល។ ហើយមិនដឹងថា អ្នកណាគេអ្នកចេញសំឡេង អ្នកបកប្រែ ខ្ញុំអត់ចាំដែរ។

**ស៖** ក្រៅពីខ្សែភាពយន្តនេះ តើលោកធ្លាប់បានឃើញអ្នកថតរូបនៃមន្ទីរស-២១ មកថតរូបសាកសពដែរឬទេ គឺសាកសពអ្នកទោសដែលត្រូវបានគេសម្លាប់? តើលោកមានចាំត្រង់ចំណុចនេះទេ?

**ផ៖** បាទ ខ្ញុំអត់ចាំទេ ប៉ុន្តែឃើញគេយកទៅបញ្ចាំង ហើយរូបថតដែលគេថតដូចថា អ្នកសំខាន់ៗអីចឹង គេថត ផ្ដិតរូបថត ហ្នឹងៗបានឃើញ។ ឃើញវះពោះ វះអីគេថតអាហ្នឹងយកទៅដើម្បីជាភស្តុតាងថា គេបានសម្លាប់ចោលហើយ។

**ស៖** តើលោកមានចាំឈ្មោះឥស្សរជនសំខាន់ៗ ឬអ្នកដឹកនាំសំខាន់ៗដែលលោកបានឃើញនៅក្នុងខ្សែភាពយន្តដែរឬទេ? តើឥស្សរជនទាំងអស់នោះ សុទ្ធតែជាអ្នកទោសនៃមន្ទីរស-២១ ឬក៏ពួកគាត់ជាអ្នកដឹកនាំ អ្នកធំៗ?

[១៥:០៩:២៧]

**ផ៖** បាទ ខ្ញុំឃើញដូច គេថតយកមកអ៊ីចឹងដូចដែល តាប៉ង់ តាអី ក៏ឃើញនៅក្នុងរូបថតហ្នឹងដែរ ហើយដូច ហ៊ូ នឹម អ៊ីចឹង ក៏ក្នុងនៅក្នុងរូបថតហ្នឹងដែរ។

**ស៖** ប្រហែលជាមានបញ្ហាបកប្រែហើយមើលទៅ ខ្ញុំឮអំមិញថាដូចរូបថត ហ៊ូ នឹម ហើយនិងរូបថតរបស់ តាគុន យ៉ាងម៉េច? លោកអាចឆ្លើយម្តងទៀតបានដែរឬទេ? ខ្ញុំស្តាប់ឮអំមិញថាមាន ហ៊ូ

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

នឹម អ៊ីចឹងសូមលោកបញ្ជាក់ ហើយមានរូបថតម្នាក់ទៀត លោកជួយបញ្ជាក់មើលតើរូបថតអ្នកណា?

**ធ៖** បាទ ឃើញរូបថតលោក ហ៊ូ នឹម ហើយនិងលោក រូបថត តាប៉ង់។

**ស៖** ហើយ តាប៉ង់ ហ្នឹងជាអ្នកណាដែរ?

**ធ៖** ខ្ញុំមិនច្បាស់ដែរ ព្រោះ តាប៉ង់, តាហ៊ី ថានៅខាងអីភ័ស្តុភារសេនាធិការអីមិនដឹងទេកាលហ្នឹង។

**ស៖** ជាថ្មីម្តងទៀត តើនៅក្នុងខ្សែភាពយន្តនោះ <លោក>ឃើញអ្នកសួរចម្លើយវាយដំអ្នកទោសវៀតណាមដែរឬទេ? តើនៅក្នុងកុនហ្នឹង <លោក>ឃើញអ្នកសួរចម្លើយវ៉ៃអ្នកទោសវៀតណាមដែរឬទេ?

**ធ៖** បាទ ខ្ញុំអត់ឃើញទេ។ ឃើញតែបណ្តើរឲ្យដើរ ហើយពាក់មួកកូបមួកអីហ្នឹង ពាក់ផ្កាយពាក់អីហ្នឹង ហើយនិងសម្លាប់។

**ស៖** នៅក្នុងកុននោះ តើមានរូបភាពដែលបង្ហាញថា អ្នកទោសទាំងអស់ហ្នឹងកំពុងសារភាពដែរឬទេ?

**ធ៖** បាទ អត់មានទេ អត់មានឃើញទេ។ បាទគឺអត់មានឃើញទេ។

[១៥:១២:៣០]

**ស៖** តើលោកចាំអំពីកាលបរិច្ឆេទដែលលោកមើលកុនហ្នឹងដែរឬទេ? តើនៅពេលដំបូងនៅពេលលោកចូលធ្វើការនៅមន្ទីរស-២១ ឬក៏នៅពេលលោកធ្វើការជិតចប់ហើយនៅមន្ទីរស-២១ហ្នឹង?

**ធ៖** បាទ ខ្ញុំអត់ចាំដែរ។ ពេលនោះគឺពេលដែលរៀនសូត្រ ដូចថាថ្ងៃ១៧ មេសាអីអ៊ីចឹង គេយកកុនហ្នឹងទៅបញ្ចាំងឲ្យមើលបាទ ១៧ មេសា គេហៅប្រជុំរៀនសូត្រទៅ គេបញ្ចាំងកុនយប់ហ្នឹងឲ្យមើលទៀត។

**ស៖** អ៊ីចឹងគឺជាខ្សែភាពយន្តដែលគេបញ្ចាំងឲ្យមើលនៅថ្ងៃទី១៧ មេសា ដើម្បីប្រារព្ធពិធីបុណ្យជាតិ១៧ មេសា អ៊ីចឹងមែនទេ?

**ធ៖** បាទ អ៊ីចឹងមែន។

**ស៖** លោក អម្បាញ់មិញលោកបាននិយាយថា អ្នកណាក៏មានវត្តមាននៅទីហ្នឹងដែរ។ អ៊ីចឹងលោកអាចជម្រាបជូនតុលាការបានដែរឬទេ ថាគេបញ្ចាំងខ្សែភាពយន្តនៅកន្លែងណា? តើជាបន្ទប់បញ្ចាំងកុនដែលគេធ្លាប់តែបញ្ចាំងនៅទីហ្នឹង ឬក៏កន្លែងណាមួយផ្សេងទៀត? ហើយបើមានមនុស្សមើល

នោះ តើមានប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា នៅមុខគុកហ្នឹង តាមផ្លូវហ្នឹង គេបញ្ចាំងហ្នឹង ហើយកាលហ្នឹងមកតាំងពីព្រៃស តាំងអ្នកសួរចម្លើយ រួមអ្នកធ្វើការនៅកន្លែងហ្នឹងទាំងអស់ គឺនាំគ្នាមើលកុនហ្នឹងបាទ។

**ស៖** អ៊ីចឹងគឺបានន័យថា ការបញ្ចាំងនៅកណ្ដាលវាល? តើលោកអាចប៉ាន់ប្រមាណចំនួនអ្នកមើលបានដែរឬទេ? តើមានសាមសែសិបនាក់ ឬក៏រាប់រយនាក់ ដែលមើលការបញ្ចាំងកុនហ្នឹង?

**ឆ៖** បាទ គឺអ្នកមើលហ្នឹងគឺរាប់រយនាក់ អ្នកធ្វើការនៅកន្លែងហ្នឹង ហើយមកពីព្រៃស ព្រៃអី។

**ស៖** តើអង្គាល់បញ្ចាំងកុនហ្នឹង ឌុច មានវត្តមានដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់ចាប់អារម្មណ៍ដែរ ប៉ុន្តែប្រហែលជាគាត់នៅហ្នឹងដែរ ព្រោះពេលហ្នឹងគាត់បង្រៀនសូត្រគេហើយ ថ្ងៃ១៧ មេសា ដល់ហើយក៏គាត់ចេញមកមើលជាមួយ តាហ៊ី ជាមួយអីហ្នឹងដែរមើលទាំងអស់គ្នា។

**ស៖** តើអ្នកដឹកនាំមានវត្តមាននៅទីនុំងដែរឬទេ? ឧទាហរណ៍ដូចជា សុន សេន ជាដើម។

**ឆ៖** បាទ អត់មានទេ។ មានតែ តាឌុច, តាហ៊ី ហ្នឹង ហើយពួកអ្នកធ្វើការនៅកន្លែងហ្នឹង ហើយមកពីព្រៃស។

[១៥:១៦:២១]

**ស៖** តើលោកមានចាំពីវត្តមានអ្នកទោសបស្ចិមប្រទេសដែរឬទេ នៅមន្ទីរស-២១?

**ឆ៖** បាទ គឺមានពីរនាក់ មាឌធំៗ គេថាអាមេរិកាំងៗ។

**ស៖** តើលោកដឹងដែរឬទេ ថាតើពួកគាត់ត្រូវបានគេសម្លាប់ដែរឬទេ? ហើយបើគេសម្លាប់គាត់នោះ តើគេសម្លាប់គាត់តាមរបៀបណាដែរ?

**ឆ៖** បាទ គេយកគាត់មកសម្លាប់នៅផ្លូវចំបេប្លេហ៏មហ្នឹង ចំហៀងខាងកើត អំខាងលិច អំខាងជើងផ្លូវហ្នឹង មានផ្លូវទទឹងមួយទៅជើងត្បូងហ្នឹងទៀត ម្ដុំហ្នឹងបាទ។ ពេលនោះគឺគេឲ្យជីករណ្ដៅកប់ តែតាឌុច បញ្ជាថាឲ្យៗ តាហ៊ី ហ្នឹងកុំឲ្យកប់ ឲ្យគរឈើដុត ព្រោះជនជាតិបរទេសអត់ឲ្យកប់ទេ គេថាជាតិឧស្ម័នជាតិអីគេ។ ពេលនោះ គឺពួកខ្ញុំដើរយាមជុំវិញៗបរិវេណហ្នឹងទាំងអស់ គឺមានអ្នកដែលចូល ចង់លេងមន្ទីរស-២១ហ្នឹង។ ថ្ងៃមួយគឺបានដុត ផ្ទះខាងកើតៗលូទឹកស្អុយ កន្លែងខាងកើតផ្ទះខ្ញុំហ្នឹង ហើយពួកអ្នកយាមនៅឯផ្លូវណោះទៀត ក្មេងៗយាមហ្នឹងក៏តាមដេញចាប់កាំភ្លើងចាប់អី ក៏ពួកខ្ញុំយាមទៅម្ដងបីនាក់ ម្ដងបីនាក់ ដើរព័ទ្ធជុំវិញហ្នឹង ឃើញគេដុតនៅកន្លែងហ្នឹង។

**ស៖** បើសិនជាខ្ញុំយល់មិនច្រឡំទេ គឺថាអ្នកទោសនៃមន្ទីរស-២១ ទាំងអស់ហ្នឹងត្រូវបានគេកប់ ក៏ប៉ុន្តែអ្នកទោសមកពីបស្ចិមប្រទេសទាំងអស់ហ្នឹងត្រូវបានដុត។ អ៊ីចឹងខ្ញុំសួរលោកថា ហេតុអីបានគេដុតអ្នកទោសនៃបស្ចិមប្រទេសទាំងអស់ហ្នឹង? លោកអាចពន្យល់ជូនតុលាការបានទេ?

**ឆ៖** បាទ គេដូចញ តាហ៊ី និយាយថា តាឌុច ថាអត់ឲ្យដុតទេ ដុតអីអត់បានទេ ព្រោះដូចថាជាតិឧស្ម័នជាតិអីគេ។ គេឲ្យពួកអ្នកអស់ហ្នឹងដើរប្រមូលអូសប្រមូលឈើ ប្រមូលអីយកគរដុត ដុតលើផ្លូវជាតិហ្នឹង។

[១៥:១៩:២៨]

**ប្រធានអង្គជំនុំ៖**

ស្តាប់ខ្មែរទៅដូចជាពិបាកស្តាប់ គេអត់ឲ្យដុតទេ ដល់ពេលបញ្ជាពី ឌុច មកថាឲ្យរកឈើ រកអូសមកទៅដាក់គរដុតនៅលើផ្លូវជាតិ។ មិនឲ្យដុត ឬក៏មិនឲ្យកប់ មិនឲ្យកប់ទេ ហើយសម្រេចថាឲ្យដុត អាហ្នឹងវាៗខុសគ្នា។ បើលោកនិយាយមុនហ្នឹង ភាសាខ្មែរហ្នឹងគឺមិនឲ្យដុត ហើយក្រោយមកគឺបញ្ជាឲ្យរកអូសដុតហ្នឹង គឺវាៗអត់ត្រូវ។ អង្គហេតុហ្នឹងគឺវាមិនអាចជឿបានទេ វាមិនៗទំនងទាល់តែសោះ។ លោកយល់ឆ្លើយសំណួរចុងក្រោយនេះឲ្យបានច្បាស់លាស់សាឡើងវិញ។

**លោក ហ៊ឹម ហ៊ុយ៖**

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា តាហ៊ី ឲ្យកប់ តែដល់ហើយទទួលបញ្ជាពី តាឌុច មកថា អត់ឲ្យកប់ទេ ឲ្យរកអុសរកអី គរដុតលើផ្លូវជាតិហ្នឹងទៅ ព្រោះជាតិបរទេសគឺជាតិឧស្ម័នគេថាជាតិឧស្ម័ន។ អ៊ីចឹងគេ ឃើញគេនាំគ្នាប្រមូលអុស ៗផ្ទះអុសអីណា ប្រមូលយកមក ជួនកាលលេងអាជញ្ជាំងអីហ្នឹងរុះយកមក ដាក់គរដុតនៅលើផ្លូវជាតិហ្នឹង។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** លោកសាក្សី តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ បើតាមការចងចាំរបស់លោក តើអ្នកយាមដែលក្មេងជាងគេបំផុតនៅមន្ទីរស-២១ នោះមានអាយុប៉ុន្មានដែរ?

**ឆ៖** បាទ ប្រហែលជា១៥ទេ ប៉ុណ្ណឹង។

[១៥:២១:៤០]

**ស៖** តើលោកមានចាំដែរឬទេ ថាតើមានការរៀបការរួម សម្រាប់បុគ្គលិកមន្ទីរស-២១ដែរឬទេ គឺរៀបការម្តងច្រើនគូ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា អ្នកដែលរៀបការរៀបនៅមន្ទីរស-២១ហ្នឹង គឺមានចំនួនប្រហែលជាប្រាំមួយគូបាទ។ ពេលនោះគឺយកណោះ ពីកាត់ដេរយកមករៀបជាមួយពួកអ្នកនៅធ្វើការស-២១ហ្នឹង កម្មាភិបាលហ្នឹង។ ពេលល្ងាចយប់ហ្នឹង គេជប់លៀង គេមានទឹកដូងមានអីហូប ហើយនិងមាន់និងអីគេខ្លះមិនដឹងទេ ខ្ញុំវាភ្លេចដែរ។ ថ្ងៃហ្នឹងក៏ តាឌុច សួរខ្ញុំដែរ ពេលខ្ញុំទៅទាន់ពេលហ្នឹងសួរខ្ញុំ ចង់បានគ្រួសារដែរអត់? ខ្ញុំថា អ្ហឺ ដឹងយកគ្រួសារមកអីទេបង អត់ចង់បានទេ។ នឹកឃើញថា បើកាលណាខ្ញុំយកគ្រួសារ គឺទ្រូក្បាលពីរ អ៊ីចឹងខ្ញុំអត់យកទេ។ អ្នកដែលរៀបប៉ុន្មានហ្នឹងគឺស្លាប់ទាំងអស់ នៅតែ ប៉ុន មួយអីនៅតែ ប៉ុន មួយទេ ក្រៅពីហ្នឹងស្លាប់ទាំងអស់ ស្លាប់ទាំងប្ដី ទាំងប្រពន្ធ ទាំងកូន។

**ស៖** លោកមានបានចូលរួមក្នុងពិធីរៀបការទាំងប្រាំមួយគូហ្នឹងដែរឬទេ?

**ឆ៖** បាទ ដូចខ្ញុំជម្រាបអំមិញអ៊ីចឹង ខ្ញុំបានទៅចុងក្រោយគេ ព្រោះខ្ញុំអត់ដឹងដែរ ដើរទៅជួបគេគេកំពុងរៀបហ្នឹងបាទ។ គេមានតុវែងគេ គេដាក់ម្ហូបដាក់ម្ហា មានដូងកាប់ដូងអីគេ គេហូបតាំងពីបងហ៊ុយស្រែ អីហ្នឹង ក៏រៀបនៅពេលហ្នឹងជាមួយគ្នាដែរ បាទ។ ហើយក៏បានបាយ បានអីជាមួយគេហ្នឹងទៅ។ ហើយបាន តាឌុច សួរខ្ញុំ "មិត្តហ៊ុយឯង ចង់រៀបគ្រួសារដែរអត់?" ខ្ញុំថា "ខ្ញុំអត់ចង់បាន មិនដឹងយកមកធ្វើអីទេបង។" នឹកឃើញថាបើយកទៅគឺ ទ្រូក្បាលពីរហើយ បើនៅម្នាក់ឯងស្រណុកជាង។ បាទ ដូចខ្ញុំជម្រាបអ៊ីចឹងថា អ្នកដែលរៀបហ្នឹងគឺស្លាប់ទាំងអស់នៅសល់តែ ប៉ុន ហើយប្រពន្ធហ្នឹងមួយទេ ដែលរត់ទៅព្រៃបាន ក្រៅពីហ្នឹងចាប់នៅទួលស្លែងទាំងអស់។

[១៥:២៤:៣២]

**ស៖** បើតាមលោកដឹង តើអ្នកដែលបានរៀបការនៅថ្ងៃនោះ ពួកគាត់ទាំងអស់ហ្នឹងសុទ្ធតែស្គាល់គ្នា ស្គាល់គូស្រករបស់ខ្លួនហ្នឹងពីមុនមកហើយ ឬក៏អត់ទេ?

**ឆ៖** បាទ គឺខ្ញុំ មិនៗដែលស្គាល់គ្នាទេពួកហ្នឹង តែគេចាប់ជាគូបណ្ដោយទៅ។

**ស៖** តើអ្នកណាជាអ្នកសម្រេចចាត់ចែងរៀបការហ្នឹង?

**ឆ៖** បាទ អ្នកសម្រេចចាត់ចែងហ្នឹងគឺតាឌុច។ បាទ នៅពីរនាក់គឺ តាហ៊ី មួយក៏ប្រពន្ធនៅហើយនែ៎ តាប៉ុន ហ្នឹងមួយក៏ប្រពន្ធនៅ។ បាទ នៅពីរនាក់ ក្រៅពីហ្នឹងស្លាប់អស់។

**ស៖** តើលោកដឹងដែរឬទេ ថាតើក្រៅពីមន្ទីរស-២១ មានកន្លែងឃុំឃាំងផ្សេងទៀត នៅភ្នំពេញដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ។

សះ តើលោកធ្លាប់ឮនិយាយអំពីគុកមួយដែលស្ថិតនៅជិតវត្តភ្នំដែរឬទេ?

ឆះ បាទ ខ្ញុំអត់បានដឹងដែរ។

សះ អម្បាញ់មិញនេះ លោកបាននិយាយអំពីអ្នកយាមម្នាក់ដែលក្លាយជាអ្នកទោសក្រោយមក ហើយក្រោយមក បានគាត់បានរត់គេចខ្លួន។ តើលោកដឹងដែរឬទេ ថាមានករណីបែបនេះដែរឬទេ គឺថាអ្នក<ទោស>នៅមន្ទីរស-២១ហ្នឹង គាត់រត់ចេញពីមន្ទីរស-២១?

[១៥:២៦:៥៤]

ឆះ បាទ សូមលោកមួយសាទៀត បាទ។

សះ អម្បាញ់មិញនេះ លោកបាននិយាយអំពីមនុស្សម្នាក់ដែលឈ្មោះ ចយ។ លោកនិយាយថា គាត់រត់រួចពី<ស-២១>។ អ៊ីចឹងខ្ញុំចង់ដឹងថា បើតាមការដឹងឮរបស់លោកនោះ លោកមានដឹងថា មានករណីហ្នឹងផ្សេងទៀតដែរឬទេ គឺថាអ្នកទោសនៅមន្ទីរស-២១ហ្នឹង គាត់អាចរត់រួចពីមន្ទីរស-២១ហ្នឹង លោកមានដឹង មានករណីផ្សេងទៀត ក្រៅពីករណី ចយ ហ្នឹងទេ?

ឆះ បាទ អត់មានទេ។

សះ តើលោក<ក៏>ធ្វើការជានីរសារដែរឬទេ នៅពេលដែលលោកធ្វើការនៅមន្ទីរស-២១ លោកធ្លាប់នាំសារទៅឱ្យអ្នកផ្សេងដែរឬទេ?

ឆះ បាទ ពេលដែលខ្ញុំទៅយកអ្នកនៅស្វាយរៀងហ្នឹង ជនជាតិវៀតណាមហ្នឹង។ ខ្ញុំបើកឡានមកដល់ក្រោលគោ នីរសាររបស់ តាឌុច ជួបជាមួយខ្ញុំ ឱ្យខ្ញុំជូនវាទៅកន្លែង សុន សេន នៅខាងជើងខេត្តស្វាយរៀង បាទ។ ខ្ញុំក៏ចុះពីឡានទៅ ជូនវាទៅ ទៅដល់កន្លែង សុន សេន ហ្នឹង ហើយយកឯកសារហ្នឹងទៅឱ្យ សុន សេន ហើយក៏បើកឡានមកវិញមក។

សះ តើនៅពេលដែលលោកធ្វើការជាអ្នកយាម ឬក៏ពេលលោកធ្វើការនៅមន្ទីរស-២១នោះ លោកធ្លាប់បានជួបនីរសារដែលមកយកសារ <ឬក៏>នាំសារ<មកឱ្យទេ>? តើបើសិនជាករណីហ្នឹងមាន តើអ្នកទាំងអស់ហ្នឹង គាត់នាំសារទៅអ្នកណាដែរ?

[១៥:២៨:២៦]

ឆះ បាទ ខ្ញុំអត់បានដឹងទេ បាទ។

សះ ពេលលោកធ្វើការនៅមន្ទីរស-២១ តើលោកធ្លាប់ចូលរួមរៀនសូត្រ ឬក៏កិច្ចប្រជុំនៅក្រៅមន្ទីរស-២១ដែរឬទេ? ឧទាហរណ៍ដូចជា ចូលរួមប្រជុំនៅស្ពាតអូឡាំពិក ឬក៏កន្លែងណាផ្សេងទៀតនៅ

01297820



ក្នុងទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** បាទ គឺនៅស្តាតអូឡាំពិកហ្នឹង គេឲ្យពួកខ្ញុំទៅរៀនសូត្រ ព្រោះ សុន សេន មកបង្រៀនសូត្រនៅកន្លែងហ្នឹងបាទ។ នៅខាងត្បូងស្តាតហ្នឹង ទៅរៀនបានម្តងហ្នឹង ក្រោយមកលែងបានទៅ។

**ស៖** តើវគ្គរៀនសូត្រហ្នឹង សម្រាប់តែបុគ្គលិកមន្ទីរស-២១ទេ ឬក៏សម្រាប់អ្នកផ្សេងទៀតដែរ?

**ឆ៖** បាទ គឺរួមគ្នា។ មិនដឹងអង្គភាពណា អង្គភាពណាទេ ណែនមួយសាលាហ្នឹង។ បាទខាងត្បូងស្តាតអូឡាំពិកហ្នឹង។

**ស៖** តើលោកដឹងដែរឬទេ ថាតើអ្នកចូលរួមរៀនសូត្រនៅពេលនោះ គាត់មកពីអង្គភាពណាធ្វើសកម្មភាពអីដែរ? ឧទាហរណ៍ ដូចគាត់មកពីខាងកងពល ឬក៏សុទ្ធតែជាអ្នកធ្វើការនៅក្នុងមន្ទីរសន្តិសុខផ្សេងទៀត? តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ អំពីសកម្មភាពអ្នកចូលរួមក្នុងវគ្គរៀនសូត្រហ្នឹង?

**ឆ៖** បាទ ក្នុងវគ្គហ្នឹងគឺសុទ្ធតែយោធាទាំងអស់បាទ។ សុទ្ធតែយោធាទាំងអស់បាទ។

**ស៖** តើ<មាន>យោធា<ខ្លះ> គាត់ធ្វើការនៅមន្ទីរសន្តិសុខផ្សេងទៀត ឬក៏យ៉ាងណា? ជាដំបូងនោះ ខ្ញុំចង់សួរលោកថា តើលោកដឹងថាមានមន្ទីរសន្តិសុខផ្សេងទៀត ក្រៅពីមន្ទីរសន្តិសុខស-២១ដែរឬទេ?

[១៥:៣២:៣២]

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ។ ការរៀនសូត្រនេះមិនដឹងអ្នកណានៅកន្លែងណា ណានៅកន្លែងណាទេ ទៅដឹងតែទៅដល់ គេបង្រៀនដឹងតែរៀនទៅ។

**ស៖** លោកសាក្សីសំណួរចុងក្រោយ។ តើនៅក្នុងវគ្គរៀនសូត្រហ្នឹង តើគេធ្លាប់ប្រើទស្សនាវដ្តីដែលបោះពុម្ពផ្សាយនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ<ទេ>? ឧទាហរណ៍ ដូចជាយុវជន យុវនារីបដិវត្ត ឬក៏ទស្សនាវដ្តីទង់បដិវត្តជាដើមនេះ គេមានប្រើឯកសារទាំងអស់ហ្នឹង ដើម្បីបង្រៀនអ្នកដែលមកចូលរួមរៀនសូត្រទេ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា ការរៀនសូត្រនេះ គាត់លើកឡើងពីការកសាងប្រទេស ធ្វើស្រូវធ្វើអីហ្នឹង ហើយពីក្បួនបច្ចេកទេសយោធា ការរៀបចំដាក់ខ្សែកងទ័ព គឺដាក់ច្រមុះជ្រូក ដាក់ណោះម៉ុំណោះម៉ុំ ណោះម៉ុំណោះម៉ុំ វែជាមួយវៀតណាមហ្នឹង។ ហ្នឹងជាគាត់ អ្នកបង្រៀនសូត្រ ហើយរឿងខ្មាំងស៊ីរូងផ្ទៃក្នុងអីហ្នឹង គាត់លើកឡើងពីបញ្ហាអស់នេះ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** តើអ្នកណាដែលគេចាត់ទុកថាជាខ្មាំងស៊ីរូងផ្ទៃក្នុង?

**ឆ៖** បាទ គឺ សុន សេន ហ្នឹងឯងអ្នកនិយាយ យើងប្រយ័ត្នជាងគេគឺខ្មាំងស៊ីរូងផ្ទៃក្នុង។ បាទនេះជាសាធារណៈដែលគេលើកឡើងមកអ៊ីចឹង។

**ស៖** តើលោកមានឮគេនិយាយពីទស្សនាវដ្ដីមួយ គេហៅថា ទង់បដិវត្ត ឬក៏យុវជន យុវនារីបដិវត្តដែរឬទេ?

[១៥:៣៥:០០]

**ឆ៖** បាទ គឺនិយាយ។ ទង់បដិវត្តយុវជនយុវនារីហ្នឹង ជាសសរទ្រូងប្រទេសជាតិហ្នឹង គេនិយាយ។

**ស៖** តើលោកដឹងដែរឬទេ ថាតើនៅក្នុងចំណោមបុគ្គលិកមន្ទីរស-២១នោះ ថាអ្នកណាជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា? តើរូបលោកផ្ទាល់ហ្នឹង លោកជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆ៖** បាទគឺខ្ញុំមិនមែនទេ។ អ្នកដែលជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាគឺមាន បងហ៊ី, បងហ៊ុយ ហើយនិង ឌុច។ ដូចអត់មានទេ អស់ហើយបាទ។

**ស៖** ដូច្នេះគឺមានតែពីរបីនាក់ប៉ុណ្ណោះនៃបុគ្គលិកមន្ទីរស-២១ ដែលជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា។ តើខ្ញុំត្រូវយល់យ៉ាងម៉េច យល់ថាមានតែពីរបីហ្នឹងទេ ឬក៏យ៉ាងណា?

**ឆ៖** បាទគឺ ចែម ស្គួន មួយទៀត តែក៏គាត់ក៏គេចាប់សម្លាប់នៅហ្នឹងដែរ។ មួយទៀតគឺ ផល មួយទៀត ហ្នឹងហើយប៉ុន្មាននាក់ហ្នឹង ក្រៅពីហ្នឹងខ្ញុំអត់ដឹង។

**ស៖** បើតាមការចងចាំរបស់លោកនៅពេលដែលលោកធ្វើការនៅមន្ទីរស-២១ តើធ្លាប់មានដែរឬទេ ថាពេលណាមួយមិនមានអាហារហូបចុកគ្រប់គ្រាន់សម្រាប់បុគ្គលិកមន្ទីរស-២១នេះ?

**ឆ៖** បាទ គឺដំបូងដែមក គឺស៊ីបបរទេ។ បានគេឲ្យពួកខ្ញុំដែលយកកម្លាំងពីអង្គភាពមក ទាំងនីរសារនីអីរបស់កម្មាភិបាលដែលគេចាប់ខ្លួនហ្នឹង ទៅធ្វើស្រូវនៅបឹងទំពុននោះ យកមកផ្គត់ផ្គង់កន្លែងហ្នឹង។ ក្រោយមកក៏បាន ធ្វើស្រូវហ្នឹងបានមក ក៏បានហូបបាយហូបអី ប៉ុណ្ណឹង។

[១៥:៣៧:៤៩]

**ស៖** តើបុគ្គលិកមន្ទីរស-២១ ទទួលបានបរិមាណអាហារហូបចុកដូចគ្នានឹងអ្នកទោសដែរឬទេ ឬក៏<>ទាំងបុគ្គលិក ហើយនិងអ្នកទោសហ្នឹងទទួលបានរបបហូបចុកខុសគ្នា?

**ឆ៖** បាទ អ្នកទោសដែលនៅក្នុងហ្នឹង មានតែតាៗ ជាងនៅខាងក្រៅប៉ុន្មានទាក់ហ្នឹងទេ បានហូបបាយ ដូចពួកខ្ញុំ។ ហើយចំណែកពួកខ្ញុំផ្នែកការពារ ហើយនិងសួរចម្លើយក៏បាយខុសគ្នាដែរ។ រោងបាយដោយខ្លួនពីគ្នា ហើយម្ហូបក៏ខុសគ្នាដែរ។ បើខ្ញុំពីរមុខ ខាងសួរចម្លើយគេបីមុខ។ បើគេបីមុខ -- ពីរមុខ ខ្ញុំបានតែមួយមុខទេបាទ។

**ស៖** បើតាមអ្វីដែលលោកឃើញនោះ តើអ្នកទោសហ្នឹងគឺពួកគាត់បានរបបអាហារតិចជាងលោកទៅទៀត ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ អ្នកទោសនុ៎ង តាៗប៉ុន្មានទាក់ហ្នឹង គឺយកបាយ ព្រោះបាយដាំសល់ច្រើនៗណាស់ទាំងម្ហូបទាំងអី។ តែចំពោះអ្នកទោសដែលនៅឃុំឃាំង គឺបបររាវៗឲ្យ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ លោកសាក្សី ខ្ញុំអរគុណ។ ខ្ញុំអស់សំណួរហើយលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកចៅក្រម។ ជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ។ ដំបូងនេះផ្តល់វេទិកាជូនទៅសហមេធាវីការពារលោក នួន ជា។ សូមអញ្ជើញ!

[១៥:៤០:00]

**លោក វ៉ិចទ័រ កូប៉េះ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកសាក្សី។ ខ្ញុំនឹងសួរសំណួរលោក តំណាងឲ្យជនជាប់ចោទ នួន ជា។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** ខ្ញុំសូមចាប់ផ្តើមសួរលោកនូវសំណួរមួយចំនួន ពាក់ព័ន្ធទៅនឹងការដាក់ទណ្ឌកម្មមួយចំនួននៅក្នុងដើមឆ្នាំ១៩៨០។ ខ្ញុំសូមអាននូវសម្រង់ពីឯកសារមួយចំនួន ហើយខ្ញុំនឹងសួរលោកអំពីបញ្ហានេះ។ លោកប្រធានគឺឯកសារ E3/9195 វាជាអត្ថបទដែលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា <ERN ជាភាសាអង់គ្លេស> 00104911 ហើយខ្មែរ 00340092។ អ៊ីចឹងខ្ញុំសូមអានសម្រង់នេះដូចតទៅលោកសាក្សី៖ “នៅដើមឆ្នាំ១៩៨0 ភាគច្រើនសមមិត្តដែលធ្វើការងារនៅស-២១ នេះត្រូវបានគេធ្វើការអប់រំ។

ហើយអ្នកខ្លះគឺត្រូវបានគេបញ្ជូនទៅគុក ហើយ សួស ធី <ដែល>ជាអ្នករក្សាបញ្ជីឈ្មោះ<អ្នកទោស> ត្រូវបានអាជ្ញាធរខេត្តកណ្ដាលឃុំនៅក្នុងគុកដែលមានសន្តិសុខយាមរយៈពេល៤ឆ្នាំ ក្រោយពេលដែល <របបនោះ>បរាជ័យ។ ហើយ ហ៊ឹម ហ៊ុយ <ដែល>ជាអនុប្រធានអង្គភាពយាមល្បាត <>ត្រូវគេដាក់គុកនៅខេត្តកណ្ដាលរយៈពេល២ឆ្នាំដែរ។" សូមបញ្ចប់ការដកស្រង់។ ខ្ញុំសូមចាប់ផ្ដើមសួរលោកសាក្សី តើលោកសាក្សីផ្ទាល់នេះ ត្រូវបានគេអប់រំដែរឬទេ ហើយប្រសិនបើត្រូវបានគេអប់រំ តើលោកត្រូវធ្វើអ្វីខ្លះនៅពេលដែលគេអប់រំនោះ?

[១៥:៤២:៣២]

**ឆ៖** បាទ ការអប់រំនៅកន្លែងគុកនោះ គឺគេឱ្យរែកទឹក បោសសំរាម ទៅកាប់អុស ទៅធ្វើស្រូវលីបាវស្រូវដាក់ឡាន ស្ទូងស្រូវ បាទ អស់ហើយ។

**ស៖** តើនៅពេលដែលគេអប់រំលោកនៅដើមឆ្នាំ១៩៨០នេះ តើលោកត្រូវតែមានការធ្វើស្វ័យ-ទិតៀនដែរឬទេ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា ខ្ញុំបាក់ស្បាតតាំងពីអាពតមក ខ្ញុំលែងតវ៉ាជាមួយអ្នកណាហើយ។

**ប្រធានអង្គជំនុំ៖**

សំណួរមិនសួរអ៊ីចឹងទេ សួរថា នៅអំឡុងពេលទទួលការរងនូវការយកលោកទៅឃុំទុកនៅពន្ធនាគារឱ្យលោកធ្វើការអ៊ីហ្នឹង តើមានរបបស្វ័យទិតៀនដែរទេ នៅក្នុងជំនាន់នោះ ជំនាន់១៩៨០ ឬ៨១ ដែលលោកថា លោកត្រូវគេចាប់ដាក់គុកនៅខេត្តកណ្ដាលនោះ?

**លោក ហ៊ឹម ហ៊ុយ៖**

**ឆ៖** បាទ គឺនៅទាំងអស់គ្នា។ បាទ ស៊ីបាយដេក ស៊ីបាយដេកនៅហ្នឹងទៅ។

**ប្រធានអង្គជំនុំ៖**

លោកដែលយល់អំពីពាក្យទិតៀន ស្វ័យទិតៀន ទេអាររបបហ្នឹង វានៅក្នុងរបបប៉ុលពត របបកម្ពុជាប្រជាធិបតេយ្យមានអាររបបហ្នឹង។ លោកដែលនៅកាលលោកធ្វើការនៅមន្ទីរសន្តិសុខស-២១ ដែលអនុវត្តនូវការកិច្ចប្រជុំផ្ទៃក្នុងដើម្បីមានការអនុវត្តនូវការទិតៀន ស្វ័យទិតៀនដែរឬទេ នៅក្នុងអង្គភាពរបស់លោក កាលពីនៅ ស-២១?

**លោក ហ៊ឹម ហ៊ុយ៖**

**ឆ៖** បាទ កាលនៅស-២១ គេឱ្យប្រជុំរាល់ល្ងាច អត់មានឱ្យដាច់ទេ។ ប្រជុំ ទោះបីអ្នកអត់ខុស

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ក៏ត្រូវតែខុសដែរ បាទ។

**ប្រធានអង្គជំនុំ៖**

ចុះពេលដែលលោកជាប់ឃុំនៅគុកខេត្តកណ្ដាល អំឡុងក្រោយឆ្នាំ៧៩នោះ តើការគេចាត់ឲ្យលោកធ្វើដូចគ្នានេះដែរទេ ទិតៀន ស្វ័យទិតៀននេះ?

**លោក ហ៊ឹម ហ៊ុយ៖**

**ឆ៖** បាទ កាលនោះគឺគ្មានស្វ័យទិតៀនអីទេ គ្រាន់ថាកុំឲ្យរត់ចេញពីកន្លែងគុកហ្នឹង ហើយខំធ្វើការធ្វើអីទៅ ប៉ុណ្ណឹងបាទ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតទៀត លោកមេធាវី វ៉ិចទ័រ កូប៉េ យើងគ្រាន់តែចង់បញ្ជាក់ចម្លើយគាត់ ព្រោះចម្លើយគាត់មិនតបនឹងសំណួររបស់លោក។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមអរគុណលោកប្រធាន។ តើលោកមានចាំអត្ថបទនេះដែរទេ ពាក់ព័ន្ធទៅនឹងនៅពេលដែលលោកហ្នឹង ថាតើលោកត្រូវបានគេដាក់គុករយៈពេល២ឆ្នាំនៅគុកខេត្តកណ្ដាលហ្នឹងដែរឬទេ?

[១៥:៤៦:០៨]

**លោក ហ៊ឹម ហ៊ុយ៖**

**ឆ៖** សូមសំណួរម្ដងទៀតលោក។

**ស៖** មិនអីទេ។ តើដូចជាអ្វីដែលឯកសារ ឬក៏អត្ថបទហ្នឹងបញ្ជាក់ដែរឬទេ ដែលថាលោកត្រូវបានគេដាក់គុកនៅទីនោះ នៅខេត្តកណ្ដាលហ្នឹង រយៈពេល២ឆ្នាំ តើមែនទេ?

**ឆ៖** បាទ។

**ស៖** តើលោកត្រូវបានគេផ្ដន្ទាទោស ឬក៏ដាក់ទណ្ឌកម្មដោយសារតែធ្វើអ្វីដែល<លោកបានធ្វើ>នៅមន្ទីរសន្តិសុខស-២១ ឬក៏នៅឯជើងឯក?

**ឆ៖** ខ្ញុំអត់ដឹងទេ ប៉ុន្តែនៅកន្លែងនោះ គឺខ្ញុំរែកដីរែកអីបាទ។

**ស៖** តើគេមាន<ស្នើ>ឲ្យ<លោក>ធ្វើការងារ<អ្វីជាក់លាក់ទេ> ដើម្បីជាការដោះដូរឲ្យលោកហ្នឹងចេញពីគុកវិញ<នោះ? តើគេ>មាន<ដាក់>លក្ខខណ្ឌ<>ឲ្យលោក<ទេ>មុនពេល<គេដោះលែងលោកឲ្យ>រួចចេញពីគុក<>នោះ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ គេបានដាក់លក្ខខណ្ឌមួយ គឺកុំឲ្យខ្ញុំប្រព្រឹត្តអ៊ីចឹងតទៅទៀត ហើយខ្ញុំធ្វើម៉េចខំចិញ្ចឹមកូនចៅឲ្យបានមានអីហូបគ្រប់គ្រាន់ទៅ។

**ស៖** តើគេមានជំរុញឲ្យលោកនិយាយអំពី<ពេលវេលារបស់លោក>នៅឯមន្ទីរសន្តិសុខស-២១ <ប្រាប់>ទៅ<នរណាទេ ដូចជាប្រាប់ទៅក្រុមអ្នកថតកុន ឬ>អ្នកកាសែត<ជាដើម>?

[១៥:៤៨:៤៤]

**ឆ៖** បាទ ខ្ញុំភ្លេចអស់ហើយលោក។

**ស៖** តើលោកដឹងទេថា <វាជាការត្រឹមត្រូវទេ ដែល>អត្ថបទនេះ<>បញ្ជាក់ថាលោក<> សួស ធី នោះ ត្រូវបានគេឃុំខ្លួននៅក្នុងមន្ទីរសន្តិសុខដែលមានការយាមកាម<>តឹងតែង<>រយៈពេល ៤ឆ្នាំនេះ<>?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម យើងខ្ញុំគិតថាសំណួរដែលបានសួរអម្បាញ់មិញហាក់ទាំងប៉ុន្មាននេះ ដូចជាមិនចូលទៅក្នុងវិសាលភាពនៃសំណុំរឿងទេ។ ហើយប្រសិនបើថា ហើយយើងខ្ញុំសូមជំទាស់ចំពោះសំណួរបែបទាំងនេះ។ ហើយប្រសិនបើលោក កូប៉េ យល់ថាចូលក្នុងវិសាលភាពនៃសំណុំរឿង សូមឲ្យបញ្ជាក់អំពីកថាខណ្ឌនៃដីកាដំណោះស្រាយដែលពាក់ព័ន្ធផង។ សូមអរគុណ។

[១៥:៥០:១១]

**លោក វ៉ិចទ័រ កូប៉េ៖**

គោលបំណងនៃសំណួរនេះ គឺចង់ដឹងទៅលើចំណុចពីរ។ ទី១ វាពាក់ព័ន្ធទៅនឹងភាពជឿជាក់បាន។ <>យើង<កំពុង>ពិនិត្យទៅលើ ថាតើមានការដាក់លក្ខខណ្ឌ<ទៅលើគាត់ ដោយអាជ្ញាធរនៅសម័យនោះទេ ដូចជា>ការជំរុញឲ្យគាត់បញ្ជាក់អំពីព្រឹត្តិការណ៍ដែលកើតឡើងនៅក្នុងមន្ទីរសន្តិសុខស-២១ ក៏ដូចជានៅជើងឯក។ ហើយ<វាក៏ដើម្បីរកឲ្យឃើញផងដែរថា តើគាត់មានសិទ្ធិមិនឆ្លើយដាក់>បន្ទុកទៅលើខ្លួនគាត់<ដែរឬទេ>។ <>ហើយវា<ក៏>ពាក់ព័ន្ធទៅនឹង<អ្វីដែលបានកើតឡើងជាទូទៅ

ចំពោះកម្មាភិបាល និង>អ្នកយាម<>នៅមន្ទីរស-២១ <ផងដែរ ហើយខ្ញុំគិតថាវាពាក់ព័ន្ធទៅនឹងការរកឲ្យឃើញផងដែរ សម្រាប់សាក្សីដែលនឹងចូលមកបន្ទាប់ទៀត ថាតើវាជាការពិតទេ ដែលគាត់>ត្រូវបានគេកាត់ទោសឲ្យជាប់ពន្ធនាគារ<ដែលមានការឃាមកាមតឹងតែង>រយៈពេល៤ឆ្នាំ។ ហើយខ្ញុំមិនចង់<ផ្តែកលើរឿងនេះច្រើនពេកនោះ>ទេ ប៉ុន្តែយើងត្រូវតែដឹងនូវ<>មូលហេតុទាំងឡាយដែលកើតមានពាក់ព័ន្ធទៅនឹងការដាក់ទណ្ឌកម្ម<>ទាក់ទងទៅនឹងអតីតសមមិត្តដែលធ្វើការនៅមន្ទីរសន្តិសុខស-២១។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ប៉ុន្តែលោកមេធាវី លោកនឹងមិន>សូមនូវពេលបន្ថែម<ទេនៅពេលចុងក្រោយនោះ ព្រោះមាន>សំណួរ<>ពាក់ព័ន្ធ<ជាច្រើនផ្សេងទៀត មិនបានសួរឲ្យបានអស់ ទាន់>ពេល។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណដែលលោកស្រីចៅក្រមបានបញ្ជាក់ទៅលើចំណុចនេះម្តងទៀត។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ៊ីចឹងបដិសេធចំពោះការជំទាស់។

[១៥:៥២:០៥]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើលោកដឹងទេថាលោក សួស ធី ហ្នឹងត្រូវបានគេដាក់គុកនៅក្នុងមន្ទីរឃុំឃាំងដែលមានការឃាមកាមតឹងតែងរយៈពេល៤ឆ្នាំ?

**លោក ហ៊ឹម ហ៊ុយ៖**

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកថា តាំងពីរត់ពីព្រៃមកដល់ផ្ទះ គឺគ្មានទាក់ទងជាមួយណាទេ ដឹងតែខំរកស៊ី។ នរណាជាប់គុកណា ខ្ញុំអត់ដឹងដែរ។ ទើបមកដល់កន្លែង រិទ្ធី ប៉ាន់ គាត់ហៅមកជួបគ្នា មកថតភាពយន្ត ថតអីហ្នឹងបានសួរទៅបានគាត់និយាយប្រាប់ រឿងថាគាត់ជាប់គុកនៅណេះនៅណោះហ្នឹង ប៉ុន្តែមិនដឹងជាប់នៅណាទៀតផង។ ហើយក៏ចេញទៅវិញ ដឹងតែរកស៊ីដូចគ្នាទៀត មិនទៅទាក់ទងអីគ្នា មិនទៅជួបគ្នាណា បើម្នាក់ខំតែរកស៊ីចិញ្ចឹមប្រពន្ធកូន រកអង្ករច្រកឆ្នាំងសឹងមិនបាន មានពេលណាទៅទាក់ទង អត់ៗ។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវខ្ញុំសូមបន្តទៅប្រធានបទមួយថ្មីទៀត។ តើលោកមានពេលណាមួយ លោកចាកចេញពីមន្ទីរសន្តិសុខស-២១<ទេ? ខ្ញុំចង់និយាយពីរយៈពេល>មុន<ថ្ងៃ៧ មក

 វា> ឆ្នាំ១៩៧៩ <តើមានពេលណាមួយលោក>ឈប់ធ្វើការ<>ជាអ្នកយាមកាមនៅខាងក្រៅ ឬក៏នៅក្នុងកងពិសេសដែរឬទេ?

**ឆ៖** បាទ ពាក់កណ្ដាលឆ្នាំ៧៨ហ្នឹង ដកខ្ញុំឲ្យទៅធ្វើស្រែ។ បងហ៊ា ថាណានៅស្រែដឹងស្រែ អ្នកណានៅភ្នំពេញដឹងភ្នំពេញ អត់ឲ្យអ្នកណាទាក់ទងគ្នាទៀតទេ។ អ៊ីចឹងខ្ញុំនៅស្រែ ខ្ញុំដឹងធ្វើស្រែទៅ ផ្ដាក់ដីលើកភ្លឺ លើកអី តែចបកាប់បង្គីលើកភ្លឺ លើកអី។ ផ្ដាក់ភ្លៀងមក គឺភ្ជួរដី មានគោមានអីហ្នឹង ភ្ជួរដី។ ភ្ជួរដីហើយ សាបអីទៅ ស្ទូង។ បែកដល់៧៩ហ្នឹងបែក បានពេលបែកហ្នឹងបានគេឲ្យពួកខ្ញុំហ្នឹងមកទទួលពួកនៅភ្នំពេញនេះ ទទួលនៅកន្លែងគេដាក់កាំភ្លើងធំទៅទួលអីគេហ្នឹង ខ្ញុំអត់ស្គាល់ដែរ។ បាទនៅចំច្បារអំពៅហ្នឹង។ ខ្ញុំមក ១អត់ឃើញ ហើយពួកកាំភ្លើងធំក៏ថា រូតចេញៗ កាំភ្លើងបាញ់ទៀតឥឡូវហើយ កាំភ្លើងបាញ់ទៀតឥឡូវហើយ។ ខ្ញុំក៏រូតរត់ទៅវិញ ក៏នាំគ្នារត់ទៅអ៊ីចឹងទៅ ព្រៃសអស់។ បាយអត់មាននរណាស៊ីបាយមួយគ្រាប់ទេ ចោលចានបាយចានអីអស់រលីង រត់។ គេថាយួនចូលដល់ច្បារអំពៅហើយ តិចទៀតគេវាយកន្លែងនេះ កន្លែងនោះ យើងក្រែងចេញមិនរួច ជិតផ្លូវអស់។ នាំគ្នារត់ទៅព្រៃស នាំព្រៃស រត់ទៅទាំងយប់ទៀត ឆ្លងផ្លូវជាតិលេខ៤ទៅលិចទៅ។

[១៥:៥៥:៣៣]

**ស៖** តើ<>លោក<ត្រូវបានគេដក>ចេញពីមន្ទីរសន្តិសុខ២១<ឬ? តើ>មានការដាក់ទណ្ឌកម្ម<លើលោកទេនៅពាក់កណ្ដាលឆ្នាំ៧៨ ដែលគេបញ្ជូនលោកទៅព្រៃសនោះ? តើគេដកលោកទៅក្រោមហេតុផល>អី <តើលោកដឹងទេ>?

**ឆ៖** បាទខ្ញុំសូមជម្រាបលោកថា គេចាប់ផ្ដើមដាក់ទណ្ឌកម្មខ្ញុំហើយ ព្រោះខ្ញុំចម្លើយរបស់ ណុប នួន ឆ្លើយថាខ្ញុំរៀបចំផែនការគាស់គុក។ អ៊ីចឹងគេអត់ទុក ឃើញទេ! ខ្ញុំបានជម្រាបថា កាំភ្លើងគេឲ្យនីរសារគេដកពីឃ្លាំង ដឹកឡានទៅសេនាធិការអស់ ហើយខ្ញុំក៏គេបញ្ជូនឲ្យធ្វើស្រូវ។ ក្រុមរបស់ខ្ញុំ មានខ្ញុំអ្នក១ដូច បងចឹក អ៊ីចឹង បងចឹក គាត់នៅក្រុមជាមួយខ្ញុំ ដល់គេនិយាយមិនស្ដាប់ ថាគាត់ចិត្តខ្លាំងៗ ខ្ញុំខំអង្វរតាហ៊ី សុំ តាហ៊ី ទុកថា ចាំខ្ញុំកសាងពីរបីថ្ងៃទៀតសិនបង ចាំមើលបើគាត់មិនកែប្រែទេ គឺធ្វើម៉េចគាត់ធ្វើទៅ ឲ្យទៅស្រែឲ្យទៅ។ នឹកឃើញថា ឲ្យធ្វើស្រែវាទំនេរ ធ្វើស្រូវវាទំនេរហើយ។ នឹកឃើញថា អាណិតគាត់ទុកហ្នឹង។ ក្រោយមកគាត់ទៅរកស្មៅឲ្យទន្សាយទៅច្រូតត្រកួន ច្រូតស្មៅ ទៅចងកងាប់បាត់ទៀតគាត់នឹកឃើញថា ប្រហែលគេចង់ចាប់គាត់ហើយ ព្រោះដឹងថា គេឲ្យទៅធ្វើស្រែហ្នឹងបាទ។ ហើយខ្ញុំក្រោយមកក៏ខ្ញុំគេដកទៅធ្វើស្រែហ្នឹងទៀត។ បាទទៅបីក្រុម នឹកឃើញថា ខ្ញុំជៀសពីចាប់មិនរួចទេព្រោះ

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

01297828


គេដឹងផែនការថា ខ្ញុំប្រឆាំងជាមួយគេហើយ។ គេនៅទើស កុំទើស តាហ៊ា ហ្នឹងហើយ ក៏គេត្រូវការចាប់ខ្ញុំបាត់តាំងនៅភ្នំពេញណោះបាទ។

**ស៖** នៅក្នុងសក្ខីកម្មរបស់លោក គឺនៅក្នុងឯកសារ E3/7462 <ដែលជាសក្ខីកម្មរបស់លោក នៅក្នុងសំណុំរឿង០០១> នៅ<ម៉ោងប្រហែល ១៤:៤៨> ក្នុងពេលរសៀលនោះ<> គេបានសួរ <ថា> "<>លោក ហ៊ឹម ហ៊ុយ <>ខ្ញុំ<កំពុងព្យាយាមធ្វើឲ្យប្រាកដ>ថាអង្គជំនុំជម្រះសាលាដំបូងបានជ្រាបច្បាស់។ នៅពេលដែលលោកត្រូវបានគេបញ្ជូនឲ្យទៅធ្វើស្រែ <តើ>នៅព្រៃស<ឬ?> គឺលោកឆ្លើយថា៖ <គេបានឲ្យខ្ញុំទៅធ្វើស្រែនៅភ្នំពេញ> ដោយសារ<គេប្រាប់ខ្ញុំថា>សមមិត្ត នួន <>បានឆ្លើយដាក់ខ្ញុំ<នៅក្នុងចម្លើយសារភាពរបស់គាត់>។ ហើយ នួន ហ្នឹងតើនួន ហ្នឹងជាអ្នកណា? ជា ហ៊ុយ ឬក៏ជាបុគ្គលមួយផ្សេងទៀត?

**ឆ៖** បាទ នួន ហ្នឹងគឺ ណុប នួន ឈ្មោះ ណុប នួន។ បាទឈ្មោះ ណុប នួន អតីតកាលនៅអង្គភាពកងទ័ព គឺជានីរសាររបស់កម្មាភិបាល។ គេចាប់កម្មាភិបាល ណុប នួន ក៏មក គេបញ្ជូនមកហ្នឹងដែរ មកធ្វើទួលស្លែងហ្នឹង។ យាមកាមជាមួយពួកខ្ញុំ នៅខាងនីរសារហ្នឹង។ ដល់ហើយក្រោយមកក៏គេឲ្យទៅសួរចម្លើយហ្នឹងទៅ ហើយកង វាក្រុមទាំងអស់ហ្នឹងវាសុទ្ធតែនីរសារ គេហៅកងនីរសារបណ្ដោយទៅបាទ។ ក្រោយមក ណុប នួន ត្រូវការចាប់ខ្លួនទៅ បានខ្ញុំនឹង គេឲ្យធ្វើស្រូវបណ្ដោយ។

[១៥:៥៩:០៤]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី *អូខេ*។

**លោក វ៉ិចទ័រ កូប៉េះ៖**

ខ្ញុំមានសំណួរមួយដើម្បីបញ្ចប់ប្រធានបទនេះលោកប្រធាន សូមអរគុណ។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** ឌុច ក៏បានបញ្ជាក់នៅក្នុងសវនាការនៅថ្ងៃនោះដែរ ថាលោក គឺជាកម្មាភិបាលដែលគេជឿជាក់ ហើយនៅធ្វើការនៅស-២១ នៅថ្ងៃទី០៧ មករា។ តើលោកមានប្រតិកម្មយ៉ាងណា ឬក៏ការយល់ឃើញយ៉ាងណាចំពោះអ្វីដែលលោក ឌុច បានលើកឡើងនេះ?

**លោក ហ៊ឹម ហ៊ុយ៖**

**ឆ៖** បាទ ខ្ញុំមិនជឿសម្ដីលោក ឌុច ទេ ព្រោះលោក ឌុច ជាមួយ តាហ៊ា ទាស់គ្នាបីដងហើយ

ប្រកាន់បក្សពួកគ្នា។ គេយកកម្លាំងពីបស្ចិមមក គេយកមកកសាងកម្លាំងហ្នឹង ហើយគេនឹងបំផ្លាញកម្លាំង៧០៣ចោល។ បាទ ឃើញទេ ដកកម្លាំងនេះចេញ ឲ្យបំបែកគ្នាទៅធ្វើស្រែ។ ទី១គឺចាប់ បងហ៊ុយ ថ្ងៃក្រោយទៅចាប់ បងហ៊ី។ ក្រោយមកទៀតទៅចាប់ខ្ញុំ។ ទៅចាប់ពួកអ្នកនៅស-២១ ចេញពី៧០៣ហ្នឹងទាំងអស់។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ហើយសវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី០៥ ខែឧសភា ឆ្នាំ២០១៦ ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី ហ៊ឹម ហ៊ុយ បញ្ចប់ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោក ហ៊ឹម ហ៊ុយ។ សវនាការស្ដាប់សក្ខីកម្មរបស់លោកក្នុងឋានៈសាក្សីនៅថ្ងៃនេះ មិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញឲ្យមកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត។ ហើយអង្គជំនុំជម្រះក៏សូមអរគុណលោកផងដែរ លោកមេធាវី ម៉ម រិទ្ធា មេធាវីប្រឹក្សាសាក្សី អង្គជំនុំជម្រះក៏អញ្ជើញលោកមកបន្តចូលរួមប្រឹក្សាសាក្សីរូបនេះ នៅថ្ងៃស្អែកទៀតដែរ។

ហើយបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនលោក ហ៊ឹម ហ៊ុយ វិលត្រឡប់ទៅកាន់កន្លែងគាត់ស្នាក់នៅ និងឲ្យអញ្ជើញគាត់ត្រឡប់ចូល បន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០១ នាទី)*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*